សាកលវិទ្យាល័យជាតិគ្រប់គ្រង
National University of Management

សៀវភៅសិក្សា

នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប

ទម្រង់ទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប



បណ្ឌិត ហោ ប៉ែត
ក្សាសិទ្ធិត្រប់យ៉ាង

បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមាន សហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាព ជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា “មូលនិធិ ស.គ.ន.” និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា “RCI Fund”។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.0 (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពវូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការ**រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា

២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់

៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលធាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

សេចក្តីបញ្ជាក់
នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តជាវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION, YOUTH AND SPORT
សាកលវិទ្យាល័យជាតិគ្រប់គ្រង
NATIONAL UNIVERSITY OF MANAGEMENT

លេខ:..០៧២/២១..... ស.ជ.ត.

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

លិខិតឧទ្ទេសនាម

មន្ត្រីរាជការ និងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគណៈកម្មការនិពន្ធ និងត្រួតពិនិត្យលើស្នាដៃនៃការចូលរួមការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅកម្រិតឧត្តមសិក្សា ដែលមានចំណងជើងថា "**នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប ទម្រង់ទ្រឹស្តីរដ្ឋធម្មនុញ្ញ ទំនើប**"៖

ក. គណៈកម្មការនិពន្ធ ឬអ្នកនិពន្ធ

១. ឯកឧត្តមបណ្ឌិត ហោ ម៉េង

ខ. គណៈកម្មការត្រួតពិនិត្យ៖

១. លោកបណ្ឌិត	សេង	ប៊ុនធឿន	ប្រធាន
២. លោកបណ្ឌិត	លី	សុខហេង	អនុប្រធាន
៣. លោកស្រី	ប៉ុក	ភារុន	សមាជិក

គ. ការអនុញ្ញាតឲ្យបោះពុម្ពផ្សាយ៖

ឯកឧត្តមបណ្ឌិត ហោ ម៉េង ជាសាកលវិទ្យាធិការ។

គណៈកម្មការ និងអ្នកនិពន្ធ ដូចមានរាយនាមខាងលើ មានភារកិច្ច និងអនុវត្តតាមលិខិតឧទ្ទេសនាមនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៨កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១

សាកលវិទ្យាធិការ

បណ្ឌិត ហោ ម៉េង

អាសយដ្ឋាន: ផ្លូវ៩៦ក្រីស្តូហ្វ័ហូវ្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥-១២) ៦៧៥ ៧៦៧/ ៨៩៣ ១៣១/ ៨៨៩ ៤៩៥
Address: St. 96 Christopher Howes, Sangkat Wat Phnom, Khan Daun Penh, Phnom Penh / Tel: (855-12) 675 767 / 893 131 / 889 495 Email: sengbunthoeun@num.edu.kh.

សៀវភៅសិក្សា

នីតរដ្ឋធម្មនុញ្ញប្រៀបធៀប

ទម្រង់ទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប

បណ្ឌិត ហោ ប៉ែច

មហាវិទ្យាល័យនីតិសាស្ត្រ
សាកលវិទ្យាល័យជាតិគ្រប់គ្រង
NUM Research Series 2021 រក្សាសិទ្ធិ

មាតិការ

អារម្ភកថា VI

ជំពូក១ 1

សេចក្តីផ្តើមសិក្សានីតិរដ្ឋធម្មនុញ្ញប្រៀបធៀប 1

១-នីតិប្រៀបធៀប 1

២-នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប 3

៣. សំនួរសិក្សាពិភាក្សា 4

ជំពូក២ 5

ប្រវត្តិកំណើតទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប 5

១. និយមន័យរដ្ឋធម្មនុញ្ញ 5

២ .ការកកើតទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប 6

២.១. ញត្តិទាមទារពីសិទ្ធិពលរដ្ឋ 7

២.២. ច្បាប់ស្តីពីសិទ្ធិពលរដ្ឋស៊ុំវិល (The Bill of Rights 1628) 8

៣. ទម្រង់ទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប (Theory of Modern Constitution) 10

៤ .ការបង្កើតរដ្ឋធម្មនុញ្ញទំនើប 11

៤.១. បដិវត្តន៍ដើម្បីឯករាជ្យតាពនៅអាមេរិកកាំង 11

៤.២. រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក និងការបំពេញបន្ថែមទ្រឹស្តីសេរីភាព 12

៥. កំណត់សំគាល់ទូទៅ 14

៦. សំនួរសិក្សាពិភ្សា 14

ជំពូក៣ 23

កំណែទម្រង់ទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើបនាសតវត្សទី២0 23

១. បញ្ហាសង្គមក្នុងប្រព័ន្ធមូលធននិយម 23

២. រដ្ឋធម្មនុញ្ញសហភាពសូវៀតឆ្នាំ១៩១៨ 24

៣. រដ្ឋធម្មនុញ្ញប្រទេសអាល្លឺម៉ង់ឆ្នាំ១៩១៩ 25

៤. រដ្ឋធម្មនុញ្ញប្រទេសជប៉ុនឆ្នាំ១៩៤៧ 27
៥. រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣....27
៦. សំឆរសិក្សាពិភាក្សា 28
ជំពូក៤ 29
ប្រវត្តិនីតិរដ្ឋធម្មនុញ្ញកម្ពុជា 29
១. ទម្រង់រដ្ឋធម្មនុញ្ញខ្មែរសម័យបុរាណ 29
១.១. រាជាធិបតេយ្យព្រហ្មញ្ញសាសនា....29
១.២. រាជាធិបតេយ្យពុទ្ធសាសនា....30
២. ទម្រង់រដ្ឋធម្មនុញ្ញខ្មែរសម័យទំនើប 32
២.១. រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ (**រាជាណាចក្រកម្ពុជា ១៩៤៧ - ១៩៧0**)....32
២.២. រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ (**សាធារណរដ្ឋខ្មែរ ១៩៧0 - ១៩៧៥**) 35
២.៣. រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦ (**កម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩**) 37
២.៤. រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ (**សាធារណរដ្ឋប្រជាមានិតកម្ពុជា ១៩៧៩ - ១៩៨៩**) 39
២.៥. រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ (**រដ្ឋកម្ពុជា ១៩៨៩-១៩៩៣**) 40
៣. កំណត់សំគាល់ចុងទៅ 40
ជំពូក៥ 41
ការរៀបចំបែងចែកអំណាចក្នុងទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប....41
១ .អំពីការបែងចែកអំណាច 41
១.១. ទ្រឹស្តីបែងចែកអំណាច (John Locke and Montesquieu) 42
១.២. រដ្ឋសភាសម័យបដិវត្តសុីវិល និងរដ្ឋសភាក្នុងប្រទេសសង្គមនិយម 43
១.៣. ការបែងចែកអំណាចនៅអាមេរិកកាំង (Separation of Powers in USA) 44
១.៤. ទម្រង់បែងចែកអំណាចក្នុងរដ្ឋធម្មនុញ្ញទំនើប....44
១.៥. ទម្រង់រៀបចំបែងចែកអំណាចក្នុងរដ្ឋធម្មនុញ្ញកម្ពុជា 45
២. អំណាចនីតិបញ្ញត្តិ (**រដ្ឋសភា និងព្រឹទ្ធសភា**)....46
២.១. ប្រព័ន្ធសហសភា (**ប្រពន្ធ័ទ្វេសភា**)....47

២.២. ហេតុផលបង្កើតព្រឹទ្ធសភា 47

២.៣. ទំនាក់ទំនងរវាងរដ្ឋសភា និងព្រឹទ្ធសភា 49

២.៤. មុខងាររដ្ឋសភា 49

២.៥. ការប្រជុំរដ្ឋសភា និងព្រឹទ្ធសភា 51

២.៦. ដំណើរការធ្វើច្បាប់ក្នុងរដ្ឋសភា និងព្រឹទ្ធសភា 52

២.៧. សមាជរដ្ឋសភា និងព្រឹទ្ធសភា 52

៣. អំណាចនីតិប្រតិបត្តិ (រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា) 53

៣.១. ការបង្កើតរាជរដ្ឋាភិបាល (ផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល) 53

៣.២. អំណាចត្រួតពិនិត្យគ្នារវាងព្រឹញ្ញវៅមករវាងរដ្ឋសភា និងរាជរដ្ឋាភិបាល 53

៤. អំណាចតុលាការ (តុលាការកំពូល និងក្រុមប្រឹក្សាធម្មនុញ្ញ) 54

៥-អាជ្ញាធរមូលដ្ឋាន (ថ្នាក់ក្រោមជាតិ) និងសិទ្ធិស្វ័យភាព 55

៦. សំនួរសិក្សាពិភាក្សា 56

ជំពូក៦ 57

ប្រព័ន្ធបោះឆ្នោតជ្រើសតាំង 57

១. ប្រព័ន្ធបោះឆ្នោតក្នុងប្រទេសប្រជាធិបតេយ្យ 57

២. ប្រព័ន្ធបោះឆ្នោតប្រទេសអង់គ្លេស 57

៣. ប្រព័ន្ធបោះឆ្នោតប្រទេសអាឡឺម៉ង់ 58

៤. ប្រព័ន្ធបោះឆ្នោតប្រទេសជប៉ុន 63

៥. ប្រព័ន្ធបោះឆ្នោតប្រទេសកម្ពុជា 67

ក- ប្រព័ន្ធបោះឆ្នោតតំណាងរាស្ត្ររដ្ឋសភា 67

ខ- ប្រព័ន្ធបោះឆ្នោតសមាជិកព្រឹទ្ធសភា 68

ជំពូក៧ 70

អំពីទ្រឹស្តីបកស្រាយគតិយុត្ត 70

១- និយមន័យបកស្រាយគតិយុត្ត 70

២ .ន័យច្បាប់ និងន័យតាសារអក្សរ 72

៣-វិធីសាស្ត្រ និងគោលការណ៍....73
៤. ព្រំដែននៃការបកស្រាយ....73
៥- បញ្ហាប្រឈម....74
ជំពូក៨....77
ទ្រឹស្តី និងវិធីសាស្ត្របកស្រាយគតិយុត្ត....77
១ .ទ្រឹស្តីបកស្រាយគតិយុត្ត....77
២-វិធីសាស្ត្របកស្រាយ (System of Interpretation in Law)....80
២.១ .វិធីសាស្ត្រអញ្ចាំថាពនិយម) ឆន្ទៈដើម/Intentionalism)....80
២.២ .វិធីសាស្ត្រយថាពនិយម (អត្ថបទនិយម/អក្សរនិយម)....82
២.៣. វិធីសាស្ត្រចេតនាពនិយម (ឆន្ទៈដើមនិយម/អត្ថបទដើមនិយម)....83
ជំពូក៩....84
គោលការណ៍បកស្រាយទម្រង់គតិយុត្ត....84
នៃមតកសាសន៍ និងកិច្ចសន្យា....84
១-គោលការណ៍បកស្រាយមតកសាសន៍....84
២ .គោលការណ៍បកស្រាយកិច្ចសន្យា....86
ឯកសារយោង....88
ឧបមសម្ព័ន្ធ១....89

អារម្ភកថា

សៀវភៅសិក្សា **នីតរដ្ឋធម្មនុញ្ញប្រៀបធៀប ទម្រង់ច្រឹស្តីរដ្ឋធម្មនុញ្ញចំនើម** ត្រូវបានរៀបចំក្នុងគោលបំណងបំរើកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ និងចូលរួមវិភាគទានក្នុងកិច្ចការស្រាវជ្រាវនីតិសាស្ត្រ។ សៀវភៅនេះ ខ្ញុំបានចាប់ផ្តើមសរសេរពីឆ្នាំ២០០៥ ក្រោយពីខ្ញុំបានបញ្ចប់ថ្នាក់បណ្ឌិតនីតិសាស្ត្រពីមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យណាហ្គោយ៉ាក្នុងប្រទេសជប៉ុន និងបានត្រលប់មកបំរើការងារជាសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE)។

ចំណេះដឹងទ្រឹស្តីក្នុងសៀវភៅនេះ ខ្ញុំបានសិក្សាក្នុងថ្នាក់លោកសាស្ត្រាចារ្យ Hidenori Moto ជំនាញនីតិរដ្ឋធម្មនុញ្ញ និងជាសាស្ត្រាចារ្យដឹងនាំការស្រាវជ្រាវសារណារបស់ខ្ញុំ និងចំណេះដឹងមួយផ្នែកទៀតបានដកស្រង់ចេញពីកិច្ចការស្រាវជ្រាវក្នុងសារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតរបស់ខ្ញុំ។ នៅប្រទេសជប៉ុន ការសិក្សាថ្នាក់បរិញ្ញបត្រជាន់ខ្ពស់នីតិសាស្ត្រ ត្រូវសិក្សាមេរៀនក្នុងថ្នាក់យ៉ាងតិច២២ក្រេឌីត និងត្រូវសរសេរកិច្ចការស្រាវជ្រាវសារណាបញ្ចប់ថ្នាក់ចំនួន៨ក្រេឌីត ដោយឡែកចំពោះការសិក្សាថ្នាក់បណ្ឌិតមិនតម្រូវឲ្យសិក្សាបន្ថែមក្នុងថ្នាក់ទៀតទេ តែត្រូវវិនិយោគពេលវេលាជាប់លាប់លើកិច្ចការស្រាវជ្រាវសរសេរសារណាបញ្ចប់ថ្នាក់ជាមួយសាស្ត្រាចារ្យដឹកនាំនៃជំនាញឯកទេសរយៈពេលយ៉ាងតិច៣ឆ្នាំ។

ដោយមានសំណូមពរពីអតីតនិស្សិត ខ្ញុំបានយកឯកសារនេះ មកពិនិត្យកែសម្រួលឡើងវិញឲ្យស្របទៅតាមនិន្នាការវិវត្តថ្មីៗ នៅក្នុងប្រទេសយើង ដើម្បីបោះពុម្ពសៀវភៅសិក្សាគោលមួយ។ មួយវិញទៀត ដើម្បីជាជំនួយបន្ថែមលើសៀវភៅនេះ ខ្ញុំបានរៀបរៀងនិពន្ធសៀវភៅសិក្សាទី២ ស្តីពី **នីតរដ្ឋធម្មនុញ្ញកម្ពុជា តម្លៃធម្មនុញ្ញប្រពៃណី និងចំនើម** ជាការសិក្សាស្រាវជ្រាវសង្ខេបបំពេញបន្ថែម។

សូមអរគុណ ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានបង្កើតនូវមូលនិធិគាំទ្រការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ “មូលនិធិ ស ”ន.គ.។

សូមអរគុណ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានផ្តល់ជូននូវអត្ថបទរដ្ឋធម្មនុញ្ញ ផ្សព្វផ្សាយឆ្នាំ២០២០ (profile updated) ដាក់ជាផ្នែកឧបសម្ព័ន្ធ។

សូមអរគុណ មជ្ឈមណ្ឌលឧត្តមភាព ដើម្បីកិច្ចការស្រាវជ្រាវ និងនវានុវត្តន៍នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ដែលបានសំរបសំរួលពេលវេលា និងបច្ចេកទេសបានរលូន ។

សូមអរគុណ ឧត្តមភរិយា ប៉ុក ចាន់រ៉ែត កូនស្រី ប៉ែង ម៉ាលីដា កូនប្រុស ប៉ែង ម៉ាលីនែវ៍ និងក្មួយប្រុស ហោ ជូឡង់ ដែលបានជួយគាំពារទាំងស្មារតីនិងទឹកចិត្តក្នុងដំណើរការសរសេររៀបរៀងនិពន្ធនេះឡើង។

ជំពូក១

សេចក្តីផ្តើមសិក្សានីតិរដ្ឋធម្មនុញ្ញប្រៀបធៀប

Introduction to Study of Comparative Constitutional Law[1]

ការសិក្សាច្បាប់ ត្រូវមានលក្ខណៈជាវិទ្យាសាស្ត្រ ពុំមែនរៀនថាតាមទេ។ សម័យបុរាណ ទ្រឹស្តីសាសនាគ្របសង្កត់លើមនុស្ស និងសង្គមទាំងមូល។ មនុស្សមានជំនឿលើសាសនា និងបានយល់ថា ច្បាប់ទាំងអស់កើតឡើងដោយសារព្រះអាទិទេព ពីព្រោះទ្រង់ជាអ្នកបង្កើតអ្វីៗទាំងអស់ និងដឹងអ្វីៗគ្រប់យ៉ាងទាំងអស់។ វិទ្យាសាស្ត្របង្រៀនមនុស្សឲ្យមានភាពជាម្ចាស់ កំណត់វាសនាដោយខ្លួនឯង។ ការសិក្សានីតិសាស្ត្រជាការសិក្សាអំពីវិធានសណ្តាប់ធ្នាប់សង្គម ទំនាក់ទំនងរវាងបុគ្គល និងបុគ្គល រវាងបុគ្គល និងរដ្ឋអំណាច។ល។

ការសិក្សាអំពីនីតិរដ្ឋធម្មនុញ្ញប្រៀបធៀប ជាឯកទេសមួយវិត្តចេញមកពីការសិក្សានីតិប្រៀបធៀប។ ដូច្នេះ នៅក្នុងសេចក្តីផ្តើមនេះ ខ្ញុំសូមលើកទស្សនទានប្រវត្តិសាស្ត្រនៃការសិក្សានីតិប្រៀបធៀប ៖

ទី១ អំពីការកកើត និងការវិវត្តនីតិប្រៀបធៀប (Comparative Law)
ទី២ អំពីនីតិរដ្ឋធម្មនុញ្ញប្រៀបធៀប (Comparative Constitutional Law)

១-នីតិប្រៀបធៀប (Comparative Law) ជាសីល្បៈសិក្សានីតិសាស្ត្រមួយដែលមានប្រវត្តិយូរលង់ណាស់មកហើយដែលកាលនោះ ត្រូវបានគេប្រើឡើងដើម្បីស្វែងយល់ចំណេះដឹងឲ្យបានទូលំទូលាយពីខាងក្រៅស្រុក ស្តីពីទស្សនៈគំនិត និងទ្រឹស្តី អំពីច្បាប់ សង្គម សេដ្ឋកិច្ច និងនយោបាយរបស់ប្រទេសនានា។

ជាឧទាហរណ៍ មានការសិក្សាស្រាវជ្រាវជាច្រើនស្តីពីច្បាប់ សង្គម នយោបាយ និងសេដ្ឋកិច្ច ដែលបានប្រើវិធីសាស្ត្រប្រៀបធៀប គឺមានតាំងពីសម័យបុរាណមកម្ល៉េះ គេសង្កេតឃើញមានស្នាដៃល្បីៗ ៖

-លោក **ប្លាតុង** [Plato] ក្នុងស្នាដៃរបស់លោក "The Republic, 380 B.C" បានសិក្សា

1 ភាសាបារាំង "Droit Constitutionelle Comparee" ។ មេរៀននេះត្រូវបានដាក់ឲ្យសិក្សានៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចសម្រាប់និស្សិតច្បាប់ឆ្នាំទី៤ថ្នាក់បរិញ្ញាប័ត្រនាឆ្នាំសិក្សា១៩៩៦ ប៉ុន្តែក្រោយមកត្រូវបានប្តូរមកដាក់នៅ ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ វិញនាឆ្នាំ២០០៥ ។ កាលនោះកម្មវិធីសិក្សានីតិសាស្ត្រ បានរៀបចំឡើងដោយជំនាញការបារាំងអមនៅ មហាវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE)។ អ្នកសិក្សាត្រូវមានមូលដ្ឋានយល់ដឹងពីមុនខ្លះពីទ្រឹស្តីរដ្ឋធម្មនុញ្ញ។

ប្រៀបធៀប និងពិភាក្សាយ៉ាងស៊ីជម្រៅអំពីទស្សនៈវិជ្ជាសណ្តាប់ធ្នាប់នយោបាយនិងរបប ។[2]

-លោក **អារីស្តូត** [Aristotle] ក្នុងស្នាដៃរបស់លោក "Polictics, 330 B.C" ក៏បានពិនិត្យសិក្សាប្រៀបធៀបចំណោម ១៥០ រដ្ឋធម្មនុញ្ញពីទីក្រុងតូចៗ របស់ប្រទេស។

ការសិក្សាប្រៀបធៀបនេះ ដើម្បីស្វែងយល់ និងអាចកំណត់ថា តើទម្រង់នៃរបបគ្រប់គ្រងណាមួយ ដែលមានភាពប្រសើរជាងគេ ។ ការគិតគូរបស់គាត់នាសម័យនោះ រដ្ឋធម្មនុញ្ញជាច្បាប់ទម្លាប់ជាក់ស្តែងដែលស្រុកនីមួយៗ គេអនុវត្តក្នុងការគ្រប់គ្រង ហើយវាពុំចាំបាច់តម្រូវឲ្យមានវិធានគតិយុត្តសរសេរនោះទេ។ ក្នុងការសិក្សាប្រៀបធៀបរដ្ឋធម្មនុញ្ញសម័យនោះ គាត់បានរៀបចំបែងចែងជា២ទម្រង់ រដ្ឋធម្មនុញ្ញពិតប្រាកដ [True Constitution] និងរដ្ឋធម្មនុញ្ញក្លែងក្លាយ [Perversion] ។ រដ្ឋធម្មនុញ្ញពិតប្រាកដ បើតាមគាត់ ត្រូវមានគោលដៅរក្សាការពារ និងលើកស្ទួយសុខុមាលភាពរបស់ប្រជាពលរដ្ឋ ចំណែករដ្ឋធម្មនុញ្ញក្លែងក្លាយវិញ មានគោលដៅរក្សាការពារ និងលើកស្ទួយត្រឹមតែក្រុមវណ្ណៈដឹកនាំកាន់អំណាចក្នុងប្រទេសតែប៉ុណ្ណោះ ។[3]

លោក **តូម៉ាស ហូប** (Thomas Hobbes) ក្នុងស្នាដៃរបស់គាត់ "Leviethan, 1651" លោក **ចន ឡុក** (John Locke) ក្នុងស្នាដៃរបស់គាត់ "Two Treatises on Civil Government, 1691" និង លោក **អាឡិច ស៊ីស ឌឺតុគឺវិល** (Alexis de Tocquevilles) ក្នុងស្នាដៃរបស់គាត់ "Democracy in America, 1835" ពួកគាត់បានសិក្សាបែបប្រៀបធ្រៀបស្តីពីទ្រឹស្តីនីតិសាស្ត្រ សង្គម និងនយោបាយ នាសម័យមុនៗ ។4

ក្រោយៗមក នីតិប្រៀបធៀបត្រូវបានគេយកចិត្តទុកដាក់ ដោយរៀបចំជាកម្មវិធីសិក្សាជំនាញតែម្តងនៅក្នុងប្រព័ន្ធច្បាប់ ឬច្បាប់សំខាន់ៗ ចាប់ពីឆ្នាំ១៨៦៩ មកនៅក្នុងទីក្រុងបារីស ប្រទេសបារាំង ដែលកាលនោះបានបង្កើតឲ្យមានជា " **សង្គមសិក្សានីតិប្រៀបធៀប** " (Societe de Legislation Comparee) ក្រោយមកទៀត សន្និសិទអន្តរជាតិស្តីពីនីតិប្រៀបធៀប ត្រូវបានប្រារព្ធធ្វើឡើងនាឆ្នាំ ១៩០០។[5]

---

2 ស្នាដៃលោក ប្លាតុង "The Republic, 380 B.C" ត្រូវបានបោះពុម្ពសារឡើងវិញនៅក្នុង "Great Books of the Western World" នៅឆ្នាំ ១៩៥២ ។ នៅកម្ពុជាស្នាដៃរបស់លោក ត្រូវបានប្រែសម្រួលភាសាខ្មែរដោយសង្ខេបនៅទសវត្ស ១៩៧០ ។

3 ស្នាដៃរបស់លោក Aristotle, Politics ត្រូវបានបោះពុម្ពឡើងវិញនៅក្នុង "Great Books of the Western World" សូមមើលពត៌មានបន្ថែមនៅក្នុងចំណុចសម្គាល់ លេខ២ ។

4 ស្នាដៃរបស់ពួកគាត់ក៏បានបោះពុម្ពឡើងវិញនៅក្នុង "Great Books of the Western World" ផងដែរ ។ ឬអាចសិក្សាបន្ថែម នៅក្នុងគេហទំព័រ www.wikipedia.org ដែលជា Free Encyclopedias ធំមួយក្នុងចំណោមគេហទំព័រសំខាន់នានាក្នុងប្រភព Internet បច្ចុប្បន្ននេះ។

5 សូមមើល K. Zweigert, H. Klotz, & Tony Weir, Introduction to Comparative Law 1998, p.1-31 ។

បច្ចុប្បន្ន សារប្រយោជន៍នៃការសិក្សានីតិប្រៀបធៀប មានភាពចាំបាច់សំរាប់អ្នកសិក្សានីតិសាស្ត្រ ត្បិតត្រូវបានគេមើលឃើញជាទូទៅថា ម៉្យាងផ្តល់ឲ្យមានចំណេះដឹង បទពិសោធន៍អំពីច្បាប់ និងការបកស្រាយគតិយុត្ត ឲ្យកាន់តែទូលំទូលាយ និងម៉្យាងទៀតអាចជួយដល់អ្នកនយោបាយ ឬអ្នកអនុវត្តច្បាប់ មានដូចជាចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ក្នុងកិច្ចការរៀបចំតាក់តែងទម្រង់ច្បាប់ ដើម្បីចូលរួមវិភាគទាននូវការពង្រឹង និងពង្រីកការស្ថាបនាសង្គមនីតិរដ្ឋឲ្យមានភាពកាន់តែរឹងមាំ និងចីរកាលនៅស្រុករបស់គេ ។6

២-នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប (Comparative Constitutional Law) ជាមុខវិជ្ជាសិក្សាចំណាស់មួយ។[7] ជាច្រើនសតវត្សកន្លងទៅ មានអ្នកសិក្សាស្រាវជ្រាវ និងអ្នកនយោបាយជាច្រើន ជាអាទិ៍មានលោក អារីស្តូត (Aristotle) មកដល់លោក ជែនម៉ាឌីសិន (James Madison) បានធ្វើការសិក្សាប្រៀបធៀប និងវិភាគពីទម្រង់ប្រព័ន្ធរដ្ឋជាច្រើន ដើម្បីស្វែងយល់ពីប្រសិទ្ធិភាព និងភាពប្រាកដនិយមនៃរបបរដ្ឋទំនើប។

ប៉ុន្តែទោះបីជាមកដល់សម័យបច្ចុប្បន្នហើយក៏ដោយ មានរដ្ឋតិចណាស់ ដែលអាចនៅរស់រានមានជីវិតក្នុងស្ថានភាពពុំមានការផ្លាស់ប្តូរ នាសម័យសាកលភាវូបនីយកម្មនៃយើងនេះ។ ដោយឡែកប្រទេសកម្ពុជាកន្លងទៅនាសម័យមុនៗ សម័យបដិវត្ត បានធ្វើការផ្លាស់ប្តូរទម្រង់របបនយោបាយជាញឹកញាប់ ហើយធ្វើឲ្យមានការចាប់អារម្មណ៍ពីសំណាក់អ្នកសិក្សាស្រាវជ្រាវនានាទៀតផង ។

ដូចនេះក្នុងសៀវភៅសិក្សានេះ ខ្ញុំសូមលើកចំណុចធំៗ៤ មកធ្វើការសិក្សាបង្ហាញ ព្រោះអាចមានប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវទូទៅ ទាំងអ្នកអនុវត្ត អ្នកនយោបាយ និងអ្នកច្បាប់៖

ទី១ ការវិវត្តទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើបបច្ចឹមប្រទេស - សិក្សាពីគោលការណ៍គន្លឹះ
ទី២ ការកកើតនិងការវិវត្តរដ្ឋធម្មនុញ្ញកម្ពុជា - សិក្សាអំពីទ្រឹស្តីប្រពៃណី និងទំនើប
ទី៣ ពិនិត្យសិក្សាបញ្ហានៅក្នុងប្រព័ន្ធបោះឆ្នោតប្រទេសប្រជាធិបតេយ្យមួយចំនួន
ទី៤ ពិនិត្យសិក្សា គោលការណ៍ និង វិធីសាស្ត្របកស្រាយច្បាប់

6 សូមមើល K. Zweigert & H. Kotz, An Introduction to Comparative Law (3rd ed. 1998), p.1-31. និងសូមមើលស្នាដៃលោក Werner Menski, Comparative Law in a Global Context (2nd ed. 2005),p.2581.

7 សូមមើលបន្ថែមក្នុងស្នាដៃ Vicki. Jackson & Mark Tushnet, Comparative Constitutional Law (1999, Preface-v.)

៣. សំឡេងសិក្សាពិភាក្សា

ឧទាហរណ៍ បើប្អូនៗត្រូវបានស្នើឲ្យរៀបចំតាក់តែងសេចក្តីព្រាងរដ្ឋធម្មនុញ្ញ
ផ្សំលក្ខណៈប្រពៃណី និងលក្ខណៈទំនើបជាមួយគ្នាដើម្បីធានានូវសុខដុម។
តើប្អូនៗត្រូវរៀបចំប្លង់សិក្សាពត៌មានបន្ថែមចាំបាច់អ្វីខ្លះ?

I. **Catherine Dupre,** *The Important of the law, A New Comparative Perspective and Hungarian Constitutional Court, in Harding,* Andrew and Esin (eds), *Comparative Law in 21st Century* (London, The Hague and New York: Kluwer, pp.267-79).

I suggest that in 1900, the approach of the comparative law was based on two understanding that were so obvious that they were never really spelled out. The first one was that law, as understood in the West, was a sign of civilization. At that time, only civilized societies were considered to have a legal system. The second understanding was that civilization was mainly European (with an extension to American, due to early European emigration and settlement). To make it simple, at the beginning of the twentieth century, civilization was considered as being mainly Western, white and Christian.

III. **Esin Orucu,** Critical Comparative Law: Considering Paradoxes for legal System in Transition (1990).

Globalization is already increasingly interest in localization. Both the local and those who study the local feel the need to assert it. The trend to integrate moves the focus to the different and their value. Thus comparative law will become indispensable in the globalization movement since in the effort to create Universalist standards, interest in localized exceptions will flourish. Also, as Twining says, “process of globalization stir up old nationalisms, exacerbate cultural conflict, and encourage post-modern skepticism about the Universality of the value and ideas”. Comparative law will be needed in the understanding of this diversity of facilitate co-existence and harmony.

II. **Emmanuel Melissaris,** *The More the Merrier? A new take on legal Pluralism Vol.13 No.1. Social and Legal Studies (2004.pp.57.79).*

The Study of the legal must be directed toward the discovery of alternative perceptions of the world and justice and of the different practices of solving practical problems by accommodating competing interest as well as meeting prerequisites of substantive justice. The question of the law and justice then become one concerning our whole way of life, how we perceive and place ourselves in our surroundings.

ជំពូក២

ប្រវត្តិអំណើតទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប

១. និយមន័យរដ្ឋធម្មនុញ្ញ

បើយើងពិនិត្យសិក្សាលើពាក្យខ្មែរ [រដ្ឋធម្មនុញ្ញ = "រដ្ឋ + ធម្មនុញ្ញ"] មានន័យថា ជាច្បាប់គោលរបស់រដ្ឋ ។[8] ក្នុងបរិបទនេះ ស្របទៅនឹងមាត្រា១៥២ នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ន ចែងថា រដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ហើយច្បាប់ និងសេចក្តីសម្រេចទាំងឡាយណារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាជាច់ខាត ។[9] តើហេតុអ្វីបានជារដ្ឋធម្មនុញ្ញ ត្រូវបានកំណត់ ជាច្បាប់កំពូល?

ម្យ៉ាងទៀត បើយើងពិនិត្យមើលត្រឹមតែទិដ្ឋភាពទូទៅវិញ នៅគ្រប់ប្រទេសទាំងអស់លើពិភពលោកនេះ ការគ្រប់គ្រងរដ្ឋសម័យទំនើបគេយករដ្ឋធម្មនុញ្ញជាច្បាប់គោល ។ នៅក្នុងមូលបទនេះ ពាក្យថា "រដ្ឋធម្មនុញ្ញ" មានន័យជាទម្រង់ "គ្រប់គ្រងរដ្ឋ" ឬ "ប្រព័ន្ធរដ្ឋាភិបាល" ឬ "របបនយោបាយ" ទៅវិញ ។ ឧទាហរណ៍៖

- របបរាជានិយម (Constiutional Monarchy Sustem of Government)
- របបប្រធានាធិបតីនិយម (Presidential System of Government)
- របបសភានិយម (Parliamentary System of Government)

ក៏ប៉ុន្តែ បើយើងពិនិត្យឲ្យបានស៊ីជម្រៅក្នុងទិដ្ឋភាពខ្លឹមសារគតិយុត្តវិញនោះ រដ្ឋធម្មនុញ្ញជាច្បាប់គោលមិនត្រឹមតែកំណត់អំពីទម្រង់ប្រព័ន្ធរដ្ឋាភិបាលប៉ុណ្ណោះទេ តែជាធម្មនុញ្ញប្រកាសទទួលស្គាល់ គោរពនិងការពារ សិទ្ធិសេរីភាពនៃប្រជាពលរដ្ឋ ។ នៅក្នុងមាត្រា១៦ នៃសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សរបស់ប្រទេសបារាំងក្នុងឆ្នាំ១៧៨៩ (The Declaration of the Rights of Man and the Citizen 1789) បានកំណត់ចេញនូវនិយ័តកម្មនេះ ដែលត្រូវបានអ្នកសិក្សានីតិរដ្ឋធម្មនុញ្ញ មើលឃើញថាជា ទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប ។

---

8 សូមមើល វចនានុក្រមសម្តេច ជួន ណាត បោះពុម្ពឆ្នាំ១៩៣៨ នៅទំព័រទី១០០៦ ។ បើយោងតាមឯកសារនេះ រដ្ឋធម្មនុញ្ញ មានន័យថាជាច្បាប់បញ្ជាតិសម្រាប់ប្រទេសនីមួយៗ ឬជាច្បាប់ទុកជាគោលចរឹក ក្នុងការគ្រប់គ្រងរដ្ឋនីមួយៗ ដែលសភាបានបញ្ជាតិតែងតាំងឡើង ។
9 រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣, មាត្រា ១៥២ ។ មាត្រានេះត្រូវបានគេមើលឃើញថា បង្កើតទ្រឹស្តីអធិបតេយ្យភាពនៃរដ្ឋធម្មនុញ្ញ ។

La declaration des droits de l'homme et du citoyen, France 1789

Articale 16: "*Toute societe dans laquelle la garantie des droits n'est pas assuree, ni la separation des pouvoirs determines, n'a point de constitution*"

ប្រែជាភាសាអង់គ្លេស "*Any society in which no pervision is made for guaranteeing rights or for the separation of powers, has no constitution*"

ប្រែជាភាសាខ្មែរ "*សង្គមមួយ ដែលគ្មានបទប្បញ្ញត្តិ សម្រាប់ផ្តល់ឲ្យមានការធានាការគោរព និងការពារ សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ឬធានានូវការបែងចែកអំណាចនោះទេ សង្គមនោះគ្មានរដ្ឋធម្មនុញ្ញទេ*"

ក្នុងបរិបទនេះ រដ្ឋធម្មនុញ្ញមិនត្រឹមផ្តោតលើ **"ទម្រង់"** ប៉ុន្តែ **"ខ្លឹមសារ"** ។ ចំណុចនេះ បង្ហាញនូវការវិវត្តទស្សនៈថ្មីនៃទ្រឹស្តីរដ្ឋធម្មនុញ្ញ ។ បើផ្អែកលើទស្សនទានថ្មីនេះ រដ្ឋបូរាណដែលពុំមានការប្រកាសជានានូវការគោរពសិទ្ធិសេរីភាព គ្មានរដ្ឋធម្មនុញ្ញទេ ទោះបីជាប្រទេសនោះ មានរដ្ឋធម្មនុញ្ញក៏ដោយ ពីព្រោះពុំមានការជានានូវសិទ្ធិសេរីភាព ការគោរពសិទ្ធិមនុស្ស និងការបែងចែកអំណាចនោះទេ ។ នៅក្នុងរបបសក្តិភូមិ អំណាចទាំងអស់ជារបស់ព្រះរាជា ទ្រង់ជាម្ចាស់ប្រទេស និងពុំមានការបែងចែកអំណាចទេ។

រដ្ឋធម្មនុញ្ញក្នុងទស្សនៈទំនើប ជាច្បាប់គោល (កំពូល) របស់ប្រទេស ប្រកាសទទួលស្គាល់ គោរព និងការពារនូវសិទ្ធិសេរីភាពរបស់ពលរដ្ឋ (ហៅថា សិទ្ធិមនុស្ស/Human Rights) និងកំណត់នូវគោលការណ៍បែងចែកអំណាច (Separation of Powers) ជាមូលដ្ឋានសំខាន់ក្នុងយន្តការនីតិរដ្ឋ ។ គោលការណ៍បែងចែកអំណាចមានសារសំខាន់ណាស់ នៅក្នុងការទប់ ឬការបង្កាប់ ឬការកម្រិតព្រំដែននៃអំណាចរដ្ឋសម្រាប់រក្សាការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ បច្ចុប្បន្ននេះ ទ្រឹស្តីរដ្ឋធម្មនុញ្ញបានវិវត្ត និងពង្រីកខ្លួន ពីទម្រង់គតិយុត្តិ មកជា ខ្លឹមសារគតិយុត្តសំខាន់ៗ រួមមានបញ្ចូលនូវគោលការណ៍មូលដ្ឋានយ៉ាងតិច៣៖

១-ភាពស្របច្បាប់នៃរដ្ឋាភិបាលប្រជាធិបតេយ្យ (Legitimate Government – Democracy)
២-នីតិរដ្ឋ និងការបែងចែកអំណាច (Rule of Law + Separation of Power)
៣-ការទទួលស្គាល់ គោរព និងការពារសិទ្ធិសេរីភាព (Guarantee of Freedom: Human Rights)

២ការ .កកើតទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប (The Birth of Modern Contitution)

ទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប ប្រសូត្រឡើងនៅរដ្ឋបស្ចឹមប្រទេស សម័យបដិវត្តគហបតី (Western Bourgeois Revolution) ។ ព្រឹត្តិការណ៍សំខាន់ៗនាសម័យនោះ គេឃើញមានជាអាទិ៍៖

- បដិវត្តអង់គ្លេសក្នុងទសវត្សទី១៧ (Era of English Revolution in 17th Century)
- បដិវត្តអាមេរិកដើម្បីឯករាជ្យក្នុងសតវត្សទី១៨ (American Independence, 1776)
- បដិវត្តបារាំងក្នុងសតវត្សទី១៨ (French Revolution in 1789) ជាដើម ។

អ្នកសិក្សានីតិរដ្ឋធម្មនុញ្ញ បានកំណត់យកសម័យបដិវត្តអង់គ្លេសក្នុងសតវត្សទី១៧ ជាព្រឹត្តិការណ៍សំខាន់បំផុត នៃការកកើតនូវទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប ដោយមានកើតព្រឹត្តិការណ៍សំខាន់ៗ ដូចជា៖

- ញត្តិទាមទារសិទ្ធិអនុម័តដោយរដ្ឋសភាអង់គ្លេស (The petition of Right 1628) ។
- សម័យបដិវត្តពូរីតង់អង់គ្លេស ១៦៤២-៦០ (Puritan Revolution 1642-60) ។
- ច្បាប់ស្តីពីសិទ្ធិមនុស្សដំបូង ១៦៨៩ (Bill of Rights 1689) ។

២.១. ញត្តិទាមទារពីសិទ្ធិពលរដ្ឋ (The Petition of Rights 1628)

សតវត្សទី១៧ នៅប្រទេសអង់គ្លេស ជាសតវត្សតស៊ូដើម្បីបដិវត្តស៊ីវិល (ការផ្លាស់ប្តូរថ្មី)។ សម័យនោះ ស្តេច Charle I (1660-49) បានបង្គាប់ឲ្យដំឡើងពន្ធពីប្រជាពលរដ្ឋ ដើម្បីយកមកធ្វើសង្គ្រាម ។ អ្នកណាដែលបដិសេដមិនព្រមបង់ពន្ធជូនរដ្ឋ ត្រូវអាជ្ញាធរចាប់ដាក់គុក ពីព្រោះ ទង្វើនេះជាការប្រឆាំងនឹងបទបញ្ជាស្តេច។ ដូច្នេះហើយ សភាគហបតី (The House of Commons) ដែលកាលនោះគ្រាន់តែជាក្រុមតំណាងឲ្យពួកគហបតី (មហាសេដ្ឋី/ឧកញ៉ា) បានធ្វើការជំទាស់មួយតាមរយៈការដាក់ស្នើឡើងនូវអ្វីដែលហៅថា The Petition of Rights[10] និងបានបង្ខំស្តេច Charle I ឲ្យទទួលយកនិងប្រតិបត្តិតាម។ The Petition of Rights បានដាក់ចេញនូវគោលការណ៍សំខាន់ៗបួនចំណុច និយ័តកម្មអំណាចរដ្ឋ ដើម្បីធានាការពារនូវសិទ្ធិសេរីភាព (សិទ្ធិមនុស្ស) ដល់ប្រជាពលរដ្ឋអង់គ្លេសនាសម័យនោះទាមទារនូវ៖

> ១- ការកំណត់គោលនយោបាយលើពន្ធ ត្រូវមានការយល់ព្រមពីរដ្ឋសភាមុខដាក់ឲ្យអនុវត្ត (no taxes would be given without consent of Parliament)។
> ២- ការចាប់ឃុំឃាំងប្រជាពលរដ្ឋត្រូវបានហាមឃាត់ លុះត្រាតែមានការបំពានច្បាប់ (no imprisonment without a show of legal cause)
> ៣- មិនអនុញ្ញាតឲ្យដាក់ទាហាននៅក្នុងគេហដ្ឋានឯកជនឡើយ។ (soldiers cannot be put in private house)

10 មើលបន្ថែមឯកសារដើមដែលមានភ្ជាប់នូវឧបសម្ព័ន១ ។

៤- មិនអនុញ្ញាតឲ្យប្រើច្បាប់អាជ្ញាសឹក ក្នុងពេលមានសន្តិភាពបានឡើយ ។ (martial law cannot be used in time of Peace) ។

២.២. ច្បាប់ស្តីពីសិទ្ធិពលរដ្ឋស៊ីវិល (The Bill of Rights 1628)

កាលនោះ The Petition of Rights ត្រូវបានរំពឹងទុកជាគោលការណ៍គតិយុត្តិជានាការពារសិទ្ធិរបស់ប្រជាពលរដ្ឋពីការជិះជាន់សង្កត់សង្កិនរបស់អាជ្ញាធររដ្ឋ ប៉ុន្តែបន្តិចក្រោយមក ត្រូវបានបំពានដោយ ស្តេច Charle I ដែលទ្រង់ជាបុគ្គលតែម្នាក់ទើបតែបានសន្យាទទួលប្រតិបត្តិគោលការណ៍នោះ ។

ស្តេច Charle ទី១ នៅតែបន្តការដំឡើងពន្ធជាបន្តទៀតដោយពុំសុំយោបល់យល់ព្រមពីរដ្ឋសភាគហបតីរបស់ទ្រង់ឡើយ។ ដូច្នេះហើយ ការប្រឈមមុខរវាងព្រះអង្គ និងរដ្ឋសភាបានប្រែក្លាយ កាន់តែតានតឹងទៅៗ ហើយបានបង្កឲ្យមានសង្គ្រាមស៊ីវិល បដិវត្ត និងការបង្រួមបង្រួមរក្សារាជានិយមឡើងវិញ។

បន្ទាប់ពីឆ្លងកាត់បដិវត្តន៍ទាំងពីរ គឺបដិវត្តន៍ Puritant (1642-60) និងបដិវត្តន៍ Glorious (1688) នៅឆ្នាំ ១៦៨៩[11] រដ្ឋសភាគហបតី បានបង្ខំព្រះមហាក្សត្រ និងព្រះមហាក្សត្រយានី យល់ព្រមទទួលស្គាល់គោរពនិងប្រតិបត្តិតាមស្មារតីច្បាប់របស់រដ្ឋសភាចែងពីសិទ្ធិពលរដ្ឋ (Bill of Rights, 1689) ។ The Bill of Rights នេះត្រូវបានរៀបចំតាក់តែងឡើងដោយរដ្ឋសភា ដើម្បីឲ្យរដ្ឋគោរព និងការពារសិទ្ធិពលរដ្ឋទូទៅ ម្យ៉ាង និងម្យ៉ាងទៀតដើម្បីបន្ថយអំណាចព្រះមហាក្សត្រឲ្យងាកមកគោរពច្បាប់អនុម័តរបស់រដ្ឋសភាវិញ។

ច្បាប់ស្តីពីសិទ្ធិពលរដ្ឋបានកំណត់គោលការណ៍សំខាន់ៗ រួម មាន១៣ចំណុច ក្នុងនោះរួមមានដូចជាហាមប្រាមមិនឲ្យព្យួរ ឬលប់ច្បាប់ទាំងឡាយណាដោយគ្មានការយល់ព្រមពីរដ្ឋសភាជាមុននោះទៀតទេ ហាមប្រាមការដំឡើងពន្ធបន្ថែមដោយគ្មានការយល់ព្រមពីរដ្ឋសភា ពង្រីកឲ្យមានសេរីភាពពលរដ្ឋបន្ថែមទៀត នៅក្នុងការបោះឆ្នោតជ្រើសរើសសមាជិកភាពរដ្ឋសភា និងការហាមប្រាមមិនឲ្យធ្វើទារុណកម្ម ឃោរឃៅ អមនុស្សធម៌នូវគ្រប់ទម្រង់រូបភាព និងការដាក់ទុក្ខទោសមិនប្រក្រតីលើអ្នកទោសជាដើម។[12]

វិធីតស៊ូធ្វើបដិវត្តន៍ ដើម្បីបង្កើតឲ្យមានរដ្ឋធម្មនុញ្ញទំនើបនៅប្រទេសអង់គ្លេស ពុំមានភាពដាច់ខាតណាស់ទេ (មិនជ្រុលនិយម) ប៉ុន្តែផ្ទុយមកវិញ បានប្រព្រឹត្តទៅដោយការសម្របសម្រួលសន្សឹមៗ និងជាជំហានៗ ដោយទទួលនូវការគាំទ្រពីមហាជននិងក្លាយជាផ្លូវការពេញលេញនិងជាស្ថាពរ សម្រាប់ការទទួល

11 បដិវត្តស៊ីវិលទាំងពីរនេះ មានសរសេរនៅគ្រប់សៀវភៅប្រវត្តិសាស្ត្ររបស់ប្រទេសអង់គ្លេស ។

12 មើលបន្ថែមនូវឯកសារដើម The Bill of Rights 1689 ដែលមានភ្ជាប់នូវឧបសម្ព័ន១ ។

ស្គាល់និងការធានាការគោរពនិងការពារសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋានរបស់ពលរដ្ឋ។ The Petition of Rights ជានាការគោរពសិទ្ធិសេរីភាព ដែលបានប្រកាសនៅក្នុងរដ្ឋធម្មនុញ្ញ Magna Carta (1215) ។[13]

រដ្ឋសភាអង់គ្លេស បានរឹបយកអំណាចជាសន្សឹមៗ ពីព្រះមហាក្សត្រ ហើយតាមរយៈនេះ សិទ្ធិមនុស្ស និងសេរីភាព ត្រូវបានពង្រីកទូលំទូលាយនៅក្នុងរដ្ឋធម្មនុញ្ញរៀងដរាបមក ។ នៅទីបំផុត ក្នុងពាក់កណ្តាលសតវត្សទី១៩ គោលការណ៍ធម្មនុញ្ញមូលដ្ឋានសំខាន់ៗដែលតម្រូវឲ្យព្រះមហាក្សត្រ ត្រឹមតែគ្រងរាជសម្បត្តិតែមិនកាន់អំណាច ត្រូវបានកំណត់យកជាស្ថាពរ។ អំណាចត្រូវបានបែងចែកជាផ្នែកៗ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ បច្ចុប្បន្នភាពនេះ ប្រទេសអង់គ្លេស មានព្រះមហាក្សត្រីយានីគ្រងរាជសម្បត្តិតែមិនកាន់អំណាចទេ ហើយប្រទេសនេះ គ្មានក្រមរដ្ឋធម្មនុញ្ញសរសេរ ដូចនៅអាមេរិកកាំងនោះទេ ប៉ុន្តែមានរដ្ឋធម្មនុញ្ញទំនើប ។ របៀបធ្វើរដ្ឋធម្មនុញ្ញទំនើប របស់អង់គ្លេសមានលក្ខណៈប្រពៃណីអនុវត្តបន្តគ្នា មិនមកអង្គុយជុំគ្នាសរសេររដ្ឋធម្មនុញ្ញ តែជាទម្រង់មិនរៀបរយនិងបានប្រព្រឹត្តទៅជាដំហានៗ

តាមព្រឹត្តិការប្រវត្តិសាស្ត្រ ជាដំណោះស្រាយព្រមព្រៀងនយោបាយលើបញ្ហាអ្វីមួយ។ រដ្ឋធម្មនុញ្ញទំនើបអង់គ្លេសមានទម្រង់ជាប្រពៃណី មិនរៀបរយ (មិនសរសេរ) ប៉ុន្តែក្លាយជាច្បាប់គោល ក្នុងនោះរួមមានច្បាប់សំខាន់ៗ អនុម័តដោយរដ្ឋសភាជាតិ (Acts of Parliament) កិច្ចព្រមព្រៀងដំណោះស្រាយនយោបាយ (Constitutional Conventions) និងសាលក្រមតុលាការ (Judicial Precedents) ជាដើម។

Source of the UK Constitution

1. The Magna Carta 1215
2. The Petition of Right 1628
3. The Bill of Rights 1686
4. The Act of Settlement 1700
5. The Treaty of Union 1706
6. The Euopean Communities Act 1972
7. The Royal Prerogative
8. Acts Establishing Devolution
9. The Human Rights Act 1998
10. Further Illustrations …

13 Magna Carta 1215 ចែងកំណត់

គោលការណ៍សិទ្ធិសំខាន់ៗ ជាធម្មនុញ្ញភាពដំបូងបំផុតក្នុងប្រវត្តិសាស្ត្រអង់គ្លេស ។

៣. ទម្រង់ទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប (Theory of Modern Constitution)

ទស្សនសិទ្ធិមនុស្ស និងទស្សន:ស្តីពីរដ្ឋាភិបាលអាស្រ័យតាមកិច្ចសន្យាសង្គម (Social Contract) របស់លោក John Locke (1632-1704) មានភាពល្បីល្បាញបំផុត នៅក្នុងទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប។ លោក John Locke ជាទស្សនវិទូនយោបាយ និងសង្គមជាតិអង់គ្លេស ដែលនៅក្នុងសៀវភៅដ៏ល្បីល្បាញមួយរបស់លោក "Two Treaties of Civil Government (1690)" បានធ្វើការសិក្សាស៊ីជម្រៅពីបដិវត្តនៅប្រទេសអង់គ្លេស និងព្យាយាមបង្កើតទ្រឹស្តីដំបូងមួយ ដែលបានដាក់ចេញនូវការសម្រុះសម្រួលមួយរវាងសេរីភាពប្រជាពលរដ្ឋ (Freedom of Citizens) ជាមួយនឹងបទបញ្ជានយោបាយសង្គម (Social Political Orders)។ ចំណុចស្នូលនៃទ្រឹស្តីរបស់គាត់ គឺឈរលើទស្សនឯករាជ្យភាពរបស់បុគ្គលម្នាក់ៗ (Individual Liberalism)។ គាត់រកឃើញថាមនុស្សកើតមកត្រូវមានសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ និងសមភាពដូចៗគ្នា ហើយពួកគេមានសិទ្ធិពេញលេញក្នុងការកាន់កាប់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន។[14] ដើម្បីការពារទ្រព្យសម្បត្តិពួកគេឲ្យបានគង់វង្សល្អ មនុស្សត្រូវរួបរួមគ្នានៅក្នុងសង្គមមួយ (A Community) ហើយឯកភាពរវាងគ្នានិងគ្នាបង្កើតឲ្យមានរដ្ឋាភិបាល (A Government) មួយសម្រាប់ធ្វើអភិបាលកិច្ចល្អ អនុវត្តឲ្យបានប្រសើរនូវកិច្ចការអភិបាលច្បាប់ (Administration of Law)។ តាមរយៈនេះពួកគេត្រូវព្រមព្រៀងគ្នា ធ្វើប្រតិភូកម្មនៃអំណាចទាំងនេះ ទៅឲ្យមន្ត្រីជាក់លាក់ទាំងឡាយនៅក្នុងរដ្ឋាភិបាលរបស់ពួកគេ។ គំនិតនេះ លោក John Locke ហៅថាជាទ្រឹស្តីកិច្ចសន្យាសង្គម (Theory of Social Contract)។ នៅក្នុងទ្រឹស្តីនេះ អំណាចរបស់រដ្ឋាភិបាលតំណាង មានព្រំដែនជាក់លាក់ តាមបំណង និងឆន្ទៈរបស់ពលរដ្ឋ ហើយអំណាចនេះអាចរំលាយចោលវិញនៅគ្រប់កាលៈទេសៈ ក្រោមសិទ្ធិនៃការធ្វើបដិវត្តរបស់ប្រជាជន (The Rights of Revolution)។

ទ្រឹស្តីរបស់លោក John Locke បានក្លាយជាគោលការណ៍ដ៏សំខាន់មួយសម្រាប់ធ្វើការបណ្តុះគំនិតជាមូលដ្ឋានស្តីពីសិទ្ធិសេរីភាព (Freedom)។ វាត្រូវបានកើតឡើងក្នុងការអនុវត្តជាក់ស្តែង ដំបូងនៅប្រទេសអង់គ្លេស ក្នុងសតវត្សទី១៧ ហើយត្រូវបានធ្វើសាកលភាវូបនីយកម្ម និងមានឥទ្ធិពលសម្បើមណាស់កាលនោះ ហើយក្រោយមក គំនិតនេះបានជម្រុញឲ្យមានគំនិតតស៊ូធ្វើបដិវត្តដើម្បីឯករាជ្យនៅអាមេរិកកាំងក្នុងឆ្នាំ១៧៧៦ ហើយនិងបដិវត្តផ្តួលរលំសក្តិភូមិនៅប្រទេសបារាំង ឆ្នាំ១៧៨៩។

ទ្រឹស្តីលោក John Locke បានកែប្រែទំលាប់នៃការគ្រប់គ្រងចាស់របស់ពិភពលោក (Old Order) ចូលទៅកាន់សណ្តាប់ធ្នាប់ថ្មីមួយ (New Order) ដោយបានប្តូរទំលាប់ដែលទុកដាក់ព្រះមហាក្សត្រជាតួអង្គស្នូលនៃអំណាចកំពូលរបស់រដ្ឋ ទៅកាន់របៀបរបបថ្មីដែលទុកដាក់ពលរដ្ឋ បុគ្គលម្នាក់ៗ ជាចំណុចស្នូលនៃប្រភពអំណាចរបស់ពិភពលោកវិញ ជាសកលភាពនៃសិទ្ធិមនុស្ស។ ក្នុងនោះបុគ្គលម្នាក់ៗ មានសិទ្ធិចំពោះ

14 "Man are born free and equal in rights, and they have the rights to protect their own property"

សេរីភាពពីកំណើត (Natural Rights to Freedom) ហើយរដ្ឋាភិបាលជារបស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ និងសម្រាប់ប្រជាពលរដ្ឋមានភាតព្វកិច្ចថែរក្សាការពារនូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។

៤ .ការបង្កើតរដ្ឋធម្មនុញ្ញទំនើប (The Establishment of Modern Constitution)

៤.១. បដិវត្តន៍ដើម្បីឯករាជ្យភាពនៅអាមេរិកកាំង

មកដល់ដើមសតវត្សទី១៨ អាមេរិកកាំងជារដ្ឋនៅក្រោមអាណានិគមរបស់អង់គ្លេស ។ ក្រោយមកនៅជាងពាក់កណ្តាលសតវត្សទី១៨ បណ្តារដ្ឋអាណានិគមនៅអាមេរិកកាំង បានជំទាស់ប្រឆាំងទៅនឹងប្រទេសអង់គ្លេស ពីព្រោះកាលនោះប្រទេសអង់គ្លេស បានលូកដៃអន្តរគមន៍ក្នុងកិច្ចការផ្ទៃក្នុងរបស់ពួកគេដោយបានដកហូតយកប្រាក់តាមរយៈពន្ធពីអាមេរិកកាំង ដើម្បីយកទៅធ្វើសង្គ្រាម បង្ក្រាបការងើបបះបោលនៅក្នុងរដ្ឋរបស់ផងគេ ។ ជនជាតិអាមេរិកបានសំអាងថា "ការដកហូតយកពន្ធណាមួយដោយមិនបានឆ្លងកាត់ការយល់ព្រមពីសភាតំណាងរដ្ឋអាមេរិកកាំង គឺជាការគំរាមកំហែងដល់សិទ្ធិសេរីភាពផ្ទាល់របស់ប្រជាពលរដ្ឋអាមេរិកកាំង" (taxation without represent- tation was a threat to America liberties) ហើយនៅឆ្នាំ ១៧៧៥ សង្គ្រាមក្នុងស្រុក (Civil War) ទាមទារឯករាជ្យពីអង់គ្លេសបានឆាបឆេះឡើង នៅស្ទើគ្រប់រដ្ឋ ។ ក្រោយមក ១ រដ្ឋដំបូងបានឈ្នះសង្គ្រាម និងទទួលបានឯករាជ្យពេញលេញ ហើយឯកសារសំខាន់ៗ ជាច្រើនស្តីពីការប្រកាសទទួលស្គាល់សិទ្ធិសេរីភាព ត្រូវបានបង្កើតឡើង ក្នុងនោះមានជាអាទិ៍៖

-Virginia Bill of Rights ក្នុងឆ្នាំ 1776
-Declaration of American Independence ក្នុងឆ្នាំ 1776
-Constitution of the United States ក្នុងឆ្នាំ 1788
-Bill of Rights (1790) (Amendments Article 1-10) ជាដើម ។

បើយើងពិនិត្យឯកសារដើមនៃ The Virginia Bill Rights (1776) និង The Declaration of Independence (1776) យើងអាចដឹងបានភ្លាមនូវឥទ្ធិពលទ្រឹស្តីរបស់លោក John Locke ដែលបានសំដែងយ៉ាងច្បាស់តាមទស្សនទាននៃច្បាប់ធម្មជាតិ (Natural Law) ដូចជាមានចែងពីសិទ្ធិធម្មជាតិ (Natural Rights), ពីទ្រឹស្តីកិច្ចសន្យាសង្គម (Social Contract), ពីអធិបតេយ្យភាពរបស់ប្រជាពលរដ្ឋ (Popular Sovereignty), និងពីសិទ្ធិនៃការជំទាស់ (Rights of Resistance) ជាដើម ។[15]

15 សូមមើលបន្ថែមក្នុងឯកសារយោងដែលមានភ្ជាប់នៅផ្នែកខាងក្រោយ។ ជាឧទាហរណ៍នៅក្នុង The Declaration of Independence 1776: "life, liberty, and the pursuit of happiness" ect. ទាំងនេះច្បាស់ណាស់ជាគំនិត ចងក្រងដោយលោក John Locke ដូចដែលខ្ញុំបានជំរាបជូននៅក្នុងទំព័រមុនៗ ។

ទស្សនៈគំនិតទាំងនោះ ជាសម្បត្តិបញ្ញារបស់លោក John Locke ។ នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាយើងវិញ ទ្រឹស្តី John Locke ត្រូវបានយកមកអនុវត្តតាំងពីនាសម័យទំនើបកម្មឆ្នាំ១៩៤៧ ផងដែរដែលកាលនោះ ទ្រឹស្តីនេះ ត្រូវបានដកស្រង់តាមតាមរយៈបដិវត្តបារាំង -សេចក្តីប្រកាសសិទ្ធិមនុស្សរបស់បារាំង។

៤.២. រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក និងការបំពេញបន្ថែមទ្រឹស្តីសេរីភាព

រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកជារដ្ឋធម្មនុញ្ញដំបូងគេបំផុតដែលអនុម័តឡើងក្នុងឆ្នាំ១៧៨៨ ។ ច្បាប់នេះដំបូងឡើយពុំមានចែងពីសិទ្ធិសេរីភាពពលរដ្ឋទេ ប៉ុន្តែបន្តិចក្រោយមកបានធ្វើវិសោធនកម្មបន្ថែមចំនួន ១០ មាត្រាទៀត ដែលកំណត់លំអិតអំពីសិទ្ធិសេរីភាព ឬសិទ្ធិមនុស្សដែលនៅស្រុកអាមេរិកគេដឹងជាទូទៅថាជាច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១ (The Bill of Rights 1791) ។ ដូច្នេះហើយនៅអាមេរិក ទម្រង់រដ្ឋធម្មនុញ្ញដែលមានចែងពីសិទ្ធិសេរីភាព (Catalogue of Human Rights) ត្រូវបានដោះស្រាយបញ្ចប់ជាស្ថាពរ។ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញតាមបែបអាមេរិក ជាទំលាប់អាចធ្វើទៅបានតែតាមរយៈការអនុម័តដាក់បន្ថែមមាត្រាថ្មីប៉ុណ្ណោះ ។ The Bill of Rights 1791 ជាច្បាប់ធម្មនុញ្ញបន្ថែម រួមមាន ១០មាត្រា៖

មាត្រា១ សិទ្ធិសេរីភាពបញ្ចេញមតិ សិទ្ធិសេរីភាពសារព័ត៌មាន សិទ្ធិសេរីភាពសាសនា និងសិទ្ធិសេរីភាពស្នើញត្តិ (freedom of speech,press, religion, and petition)។
មាត្រា២ សិទ្ធិនៃការកាន់ និងរក្សាទុកអាវុធ (rights to keep and bear arms) ។
មាត្រា៣ កំណត់ដែនល្បាតរបស់យោធា (condition for quarters of soldiers) ។
មាត្រា៤ និយាតសិទ្ធិឆែកឆេរ និងរឹបអូស (rights of search and seizure regulated) ។
មាត្រា៥ បទប្បញ្ញត្តិពីការចោទប្រកាន់ (previsions concerning prosecution) ។
មាត្រា៦ សិទ្ធិពន្លឿនដំណើរការក្តី/សិទ្ធិសាក្សី (righys to speedy trail, withness, ect.) ។
មាត្រា៧ សិទ្ធិទទួលការដម្រះក្តីតាមគណៈវិនិច្ឆ័យ (rights to a trail by jury) ។
មាត្រា៨ ហាមការបង់ប្រាក់ធានាលើស/ការធ្វើទារុណកម្ម (excessive bail, cruel punishment)
មាត្រា៩ កំណត់វិធាននៃការបង្កើតច្បាប់រដ្ឋធម្មនុញ្ញ (rule of construction of constitution) ។
មាត្រា១០ សិទ្ធិរបស់រដ្ឋក្នុងសហព័ន្ធក្រោមក្របខណ្ឌរដ្ឋធម្មនុញ្ញ(rights of state)។

៤.៣. បដិវត្តប្រទេសបារាំង (French Revolution in 18th Century)

ឯកសារគតិយុត្តគ្រឹះសំខាន់ៗ ក្នុងសម័យនោះមានជាអាទិ៍៖

- សេចក្តីប្រកាសសិទ្ធិមនុស្ស (Delaration of the Rights of Man and of the Citizen 1789)
- រដ្ឋធម្មនុញ្ញបារាំងឆ្នាំ១៧៩១ (French Constitution) ជាដើម ។

សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស១៧៨៩ របស់ប្រទេសបារាំងបានស្រូបបញ្ចូលនូវទស្សនទានសំខាន់ៗ ពីសេចក្តីប្រកាសឯករាជ្យភាពរបស់អាមេរិក[16] វាជាឯកសារប្រវត្តិសាស្ត្រ និងល្បីល្បាញក្នុងដំណើរការវិវត្តនៃទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប ដែលមានចែងពីទស្សនសិទ្ធិមនុស្សហើយ ដែលបានបន្តស្ថិតនៅជាមូលដ្ឋានគ្រឹៈគតិយុត្តជាក់ស្តែងក្នុងច្បាប់រដ្ឋធម្មនុញ្ញបារាំងបច្ចុប្បន្ននេះទៀតផង។

ជាឧទាហរណ៍នៅក្នុង Preamble of the French Constitution of the 5th Republic ចែងថាៈ

> *"The French people solemnly proclaim their attachment to the Rights of man the Principles of National Sovereignty as defined by the Declaration of 1789, confirmed and complemented by the preamble to the Constitution of 1946"*

សេចក្តីប្រកាសសិទ្ធិមនុស្សប្រទេសបារាំងឆ្នាំ១៧៨៩នេះ បើកនូវទំព័រសេករាជថ្មីសម្រាប់ការគ្រប់គ្រងតាមធម្មនុញ្ញទំនើប - ប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស ការបែងចែកអំណាច និងនីតិរដ្ឋ ។ ជនជាតិបារាំង បានបះបោលប្រឆាំងទៅនឹងការគ្រប់គ្រងផ្តាច់ការរបស់ស្តេចលីទី១៦ ហើយបាននាំមកនូវបដិវត្ត។ The Declaration of the Rights of Man and of the Citizen ត្រូវបានពង្រាងភ្លាមៗ និងជាក់ឲ្យមានការពិភាក្សានៅក្នុងរដ្ឋសភាបារាំង ហើយត្រូវបានអនុម័តនៅថ្ងៃទី ២៦ សីហា ១៧៨៩ ។ វារួមមានបុព្វកថា និងមាត្រាដែលបទបញ្ញត្តិផ្សេងៗ ទាក់ទងរវាងរដ្ឋ/ជាតិជាមួយនឹងសិទ្ធិបុគ្គលម្នាក់ៗ។ សេចក្តីប្រកាសនេះបានបង្កើតឲ្យមាននូវសិទ្ធិមូលដ្ឋាន (Natural Rights) មានជាអាទិ៍ សិទ្ធិមានទ្រព្យសម្បត្តិ (Rights to Property) សិទ្ធិមានសន្តិសុខផ្ទាល់ខ្លួន (Rights to Personal Security) សិទ្ធិមានសេរីភាព (Rights to Liberty) និងសិទ្ធិជំទាស់ (Rights to Resistance) ជាដើម ។ សេចក្តីប្រកាសនេះ បានទទួលស្គាល់ផងដែរនូវគោលការណ៍ស្មើភាពចំពោះមុខច្បាប់ (Equality before the law) និងជាពិសេសបានដាក់បញ្ចូលនូវគោលការណ៍បែងចែកអំណាចទៀតផង (Separation of Powers)។ ស្តេចលីទី១៦ បានពន្យាពេលអនុម័តរហូតមកដល់ថ្ងៃទី៥ ខែតុលាទើបឲ្យសច្ចាប័នក្រោមសំពាធបង្ខំរបស់រដ្ឋាភិបាលជាតិ និងប្រជាជនបារាំងតាមការដង្ហែក្បួនបាតុកម្មនៅទីក្រុង Versailles និងទីក្រុង Paris អស់ពេលជាច្រើនថ្ងៃមក។

សេចក្តីប្រកាសសិទ្ធិមនុស្សឆ្នាំ១៧៨៩ បានបំរើជាគោលការណ៍គ្រឹៈនៅក្នុងប្រវត្តិច្បាប់ប្រទេសបារាំង។ ខ្លឹមសារត្រូវបានដាក់បញ្ចូលក្នុងបុព្វកថារដ្ឋធម្មនុញ្ញឆ្នាំ ១៧៩១, ១៨៥២, ១៩៤៦, និង ១៩៥៨ ជាដើម។ ក្នុងសតវត្សទី១៩ ខ្លឹមសារបានជ្រាបចូលក្នុងឯកសារសំខាន់ៗរបស់ប្រទេសនៅអឺរុប និងអាហ្វ្រិកឡាទីន

16 បើមើលនៅក្នុងសេចក្តីប្រកាសទាំងពីរ យើងនឹងរកឃើញគំនិតស្រដៀងគ្នា។ ឯកសារទាំងពីរនេះមានភ្ជាប់នៅឧបសម្ព័ន១។

មួយចំនួន ហើយបានដះឥទ្ធិពលមកអាស៊ីយើងមានប្រទេសឥណ្ឌូនេស៊ី និងជប៉ុនជាដើម ។ មួយវិញទៀត ទស្សនទានបដិវត្តបារាំងនេះក៏បានជួយជម្រុញឲ្យមានសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនាឆ្នាំ ១៩៤៨, កាតិកាសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្សដែលបានចុះហត្ថាលេខានៅទីក្រុងរ៉ូមនាឆ្នាំ១៩៥០ និងក៏មានបញ្ចូលក្នុងរដ្ឋធម្មនុញ្ញារបស់អាស៊ាន ឆ្នាំ២០០៨ ទៀតផង ។

៥. កំណត់សំគាល់ទូទៅ

យើងបានពិនិត្យសិក្សាឃើញថា សិទ្ធិសេរីភាព (សិទ្ធិមនុស្ស) និងរដ្ឋធម្មនុញ្ញទំនើបមានទំនាក់ទំនងដើមចេញពីប្រទេសអង់គ្លេស ហើយបានរីករាលដាលចូលមកប្រទេសអាមេរិក និងបារាំងតាមទស្សនទានសិក្សារបស់លោក John Locke ។ នៅក្នុងប្រទេសនីមួយៗ ប្រជាពលរដ្ឋបានធ្វើការតស៊ូប្រឆាំងនឹងការគ្រប់គ្រងរបបសក្តិភូមិដោយបានផ្តួលរំលាយចោលនូវរបៀបគ្រប់គ្រងចាស់ និងបាននាំមកនូវរបៀបគ្រប់គ្រងទំនើបដោយតម្រូវឲ្យរដ្ឋទទួលស្គាល់ គោរព និងការពារនូវសិទ្ធិមនុស្សជាមូលដ្ឋាន។ រដ្ឋធម្មនុញ្ញទំនើបរបស់រដ្ឋបស្ចឹមប្រទេស ជាឧបករណ៍គតិយុត្តសំខាន់សម្រាប់កំណត់ព្រំដែនអំណាចរដ្ឋដើម្បីរក្សាការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ កាលនោះសិទ្ធិបុគ្គលជាសេរីភាពក្រៅពីរដ្ឋ (Freedom from State) ហើយដើម្បីមានសិទ្ធិសេរីភាពទូលំទូលាយ ប្រព័ន្ធនយោបាយល្អប្រសើរជាងគេ គឺលទ្ធិប្រជាធិបតេយ្យ (Democracy) ដែលកំណត់នូវគោលការណ៍នីតិរដ្ឋ (Rule of Law) ការបែងចែកអំណាច (Separation of Power) និងការប្រកាសទទួលស្គាល់ និងគោរពគោលការណ៍សិទ្ធិមនុស្ស (Freedom of Human-Rights) ។

៦. សំនួរសិក្សាពិភ្សា

(១) Thomas Paine (1737-1809) said: "*A constitution is not the act of government, but of a people constituting a government, and a government without a constitution is power without right*". What is the legal base of the concept? If possible, please explain legitimistic source of its authority. (CF. Charles Howards McIL Wain, Constitutionalism: Ancient and Modern, 1947, p.3)។ <u>ប្រែខ្មែរ:</u> លោកសាស្ត្រាចារ្យ Thomas Paine បានពន្យល់អះអាងថា " រដ្ឋធម្មនុញ្ញមិនមែនជាច្បាប់របស់រដ្ឋទេ ប៉ុន្តែវាជាឆន្ទៈប្រជាពលរដ្ឋបង្កើតនូវរដ្ឋាភិបាល, ហើយបើការប្រើប្រាស់អំណាចណាមួយដែលមិនមានចែងក្នុងរដ្ឋធម្មនុញ្ញគឺជាការប្រើអំណាចដែលគ្មានសិទ្ធិ "(អំណាចមិនស្របច្បាប់) ។ តើទស្សនទាននេះឈរលើមូលដ្ឋានទ្រឹស្តីអ្វី? ចូលបំភ្លឺពីប្រភពស្របច្បាប់នៃអំណាចក្នុងទ្រឹស្តីទំនើប។

(២) លោកសាស្ត្រាចារ្យ គង់ កិរុន *"កាលណាយើងសិក្សាអំពីនីតិធម្មនុញ្ញ (le droit constitutionnel) គឺមានន័យថាយើងសិក្សាអំពីស្ថាប័ននយោបាយរបស់រដ្ឋក្នុងផ្នែកច្បាប់ ។ ដូច្នេះនីតិរដ្ឋធម្មនុញ្ញ គឺជាផ្នែកមួយ*

នៃច្បាប់ដែលបញ្ញត្តិទៅលើស្ថាប័ននយោបាយ ។ គេឲ្យឈ្មោះនីតិរដ្ឋធម្មនុញ្ញនេះ តាំងពីសតវត្សទី១៩ ។ ... នៅក្នុងបណ្តាប្រទេសដែលគ្មានរដ្ឋធម្មនុញ្ញក៏ដូចទាំងនេះ នៅតែមាននីតិរដ្ឋធម្មនុញ្ញមួយដែរក្នុងពេលស្ថាប័នទាំងឡាយបានទទួលជាកម្មវត្ថុនៃបទបញ្ញត្តិគតិយុត្តិ" ។ តើអ្នកមានទស្សនៈយ៉ាងណាចំពោះទឡ្ហីករណ៍នេះ? (គង់ភិរុន <u>នីតិរដ្ឋធម្មនុញ្ញ និងស្ថាប័ននយោបាយ</u> ក្បាលទី១ បោះពុម្ពឆ្នាំ ១៩៩៧, ទំព័រ ២-៣) ។

(៣) សិក្សាលើសេចក្តីប្រកាសឯករាជ្យភាពរបស់ប្រទេសវៀតណាម ១៩៤៥។ តើប្រទេសវៀតណាមកាលនោះគេរៀបចំធ្វើបដិវត្តដើម្បីអ្វី? តើបដិវត្តប្រទេសវៀតណាមរងឥទ្ធិពលពីទ្រឹស្តីបដិវត្តណាខ្លះ?

Declaration of Independence of the Republic of Vietnam (September 2, 1945)

"All men are created equal. They are endowed by their Create with certain Unalienable rights, among these are life, Liberty and the pursuit of happiness." This immortal statement was made in Declaration of Independence of the United State of America in 1776, now if we enlarge the sphere of our thoughts, this statement conveys another meaning: All the peoples on the earth are equal from birth, all the peoples have a right to live, be happy and free. The Declaration of the Rights of Man and of the Citizen of the French Revolution in 1791 also states: "All men are born free and with equal Rights, and must always be free and have equal rights." Those are undeniable truths.

Nevertheless, for more than 80 years, the French imperialists, deceitfully raising the standards of liberty, equality and fraternity, have violated our fatherland and oppressed our fellow- citizens. They have acted centrality to the ideals of humanity and justice. In the province of politics, they have deprived our people of every liberty. They have enforced inhuman laws, to ruin our unity and national consciousness, they have carried out three different policies in the north, the center, and the south of Vietnam.

ជំពូក៣

កំណែទម្រង់ទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើបនាសតវត្សទី២០

១. បញ្ហាសង្គមក្នុងប្រព័ន្ធមូលធននិយម

នៅសតវត្សទី២០ ទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើបត្រូវបានរៀបចំធ្វើកំណែទម្រង់ជាថ្មីឡើង។ ពាក់កណ្តាលសតវត្សទី១៩ ប្រព័ន្ធសេដ្ឋកិច្ចមូលធននិយម (Capitalist Economic System) នៅក្នុងប្រទេសកំពុងអភិវឌ្ឍ បានបង្កើតឲ្យមាននូវបញ្ហាសង្គមជាច្រើន ។ ប្រព័ន្ធនេះផ្តល់ឲ្យមានសេរីភាពសេដ្ឋកិច្ច (Economic Freedom) និងសិទ្ធិកម្មសិទ្ធិ (Property Rights) ដែលក្នុងនោះបុគ្គលម្នាក់ៗ អាចធ្វើការប្រកួតប្រជែងដោយសេរី (Free Competition) នៅក្នុងវិស័យជំនួញរបស់ខ្លួន ក្រោមគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ (Equality under the Law) ។ នៅក្នុងការអនុវត្តជាក់ស្តែង ការប្រកួតប្រជែងសេរីដែលបានធ្វើឡើងនាសម័យបដិវត្តឧស្សាហកម្ម ធ្វើឲ្យមានការអភិវឌ្ឍខ្លាំងក្លាមួយ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចមូលធននិយមក៏ពិតមែន ប៉ុន្តែគោលការណ៍ប្រកួតប្រជែងសេរីរបស់វាបានបង្កើតឲ្យមានអសមភាព (Inequality) ក្នុងសង្គម ។

គោលការណ៍ស្មើចំពោះមុខច្បាប់ ត្រូវបានទទួលស្គាល់ជាផ្លូវការណ៍ ហើយគោលការណ៍នេះមានន័យថា រដ្ឋត្រូវតែធ្វើអ្វីមួយបានតែក្នុងលក្ខណៈស្មើភាពគ្នាជាទូទៅដោយ មិនមានការរើសអើង។ ដូច្នេះគោលការណ៍នេះ តម្រូវឲ្យរដ្ឋមិនគួរធ្វើការផ្លាស់ប្តូរស្ថានភាពជាក់ស្តែងណាមួយសម្រាប់តែក្រុមជនណាមួយនោះទេ នេះជាទស្សនាទាន "រដ្ឋក្នុងភាពអវិជ្ជមាន" (State in Negative)។ នៅក្នុងការអនុវត្តជាក់ស្តែង ប្រព័ន្ធមូលធននិយម បានធ្វើឲ្យមានភាពមិនស្មើគ្នាក្នុងផលសេដ្ឋកិច្ច នៃជីវភាពសង្គមរបស់ប្រជាពលរដ្ឋកាន់តែខ្លាំងទៅៗ ត្បិតកាលនោះ គេមើលឃើញថាប្រព័ន្ធនេះបានបំរើតែប្រយោជន៍ឲ្យអ្នកមានធំៗ ដែលមានទុនច្រើន និងធ្វើឲ្យបាត់បង់ប្រយោជន៍ចំពោះអ្នកក្រ ពិសេសកម្មករ កសិករដែលមានតែកំលាំងពលកម្មនោះ ។

គោលការណ៍ស្មើភាពចំពោះមុខច្បាប់ (Equality under Law) ក្នុងន័យផ្លូវការណ៍ ពុំបានដោះស្រាយនូវបិតិ្តស្មើភាពនៃសេដ្ឋកិច្ចបានឡើយ (inequality in economic situation among people) ។ ប្រជាពលរដ្ឋបានត្រូវការបែងចែកជាវណ្ណៈ គឺវណ្ណៈអ្នកមាន (នាយទន់) និងវណ្ណៈអ្នកក្រ (កម្មករ/កសិករ) ។ កម្មករប្រកាន់យកនូវគោលជំហរម៉ឺងម៉ាត់មួយ ដោយចោទថា សេរីភាពខាងសេដ្ឋកិច្ច (Economic Freedom) ជាការពិត គឺគ្រាន់តែជាសេរីភាពទៅរកភាពក្រីក្រតែប៉ុណ្ណោះ (= Freedom to Poverty) ហេតុនេះហើយពួកគេបានចូលរួមគ្នារៀបចាត់តាំងឲ្យមាននូវសហជីពការងារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងបានដាក់ការទាមទារនូវសិទ្ធិផ្នែកសេដ្ឋកិច្ចរបស់ពួកគេ (ជីវភាពរស់នៅប្រចាំថ្ងៃឲ្យបានប្រសើរឡើង) នៅក្នុងរដ្ឋដែល

គ្រប់គ្រងដោយក្រុមវណ្ណៈមូលធន។ ការប្រឈមមុខរវាងរដ្ឋ និងក្រុមកម្មករ - កសិករនៅអឺរ៉ុប បានឈានទៅដល់ដំណោះស្រាយជាវិជ្ជមាន នៅក្នុងក្របខណ្ឌសន្និសិទថ្នាក់កំពូលៗ របស់ពិភពលោក ។

២. រដ្ឋធម្មនុញ្ញសហភាពសូវៀតឆ្នាំ១៩១៨

នៅក្នុងប្រទេសរុស្ស៊ី ការរីកចំរើនខ្លាំងរបស់ចលនាកម្មករ និងកសិករបានវិវត្តទៅជាបដិវត្តសង្គមមួយ (Socialist Revolution) ហើយប្រទេសនេះ បានប្រែក្លាយជារដ្ឋសង្គមនិយមទី១មុនគេ ។ រដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋសង្គមនិយមសហភាពសូវៀត ឆ្នាំ១៩១៨ កាលនោះបានបង្កើត ឲ្យមាននូវសិទ្ធិថ្មីៗមួយចំនួនដែលមានទម្រង់ខុសពីទ្រឹស្តីបស្ចឹមប្រទេស ។ នៅក្នុងមាត្រា១ បង្ហាញឲ្យឃើញថា រដ្ឋសង្គមនិយមសូវៀតមានទម្រង់រដ្ឋាភិបាលខុសពីរដ្ឋាភិបាលសភានិយមរបស់បស្ចឹមប្រទេស ហើយមានបទប្បញ្ញត្តិមួយចំនួនបាននិយាយពីសិទ្ធិសេរីភាពផងដែរ ។ សាស្ត្រាចារ្យឯកទេសខាងនីតិរដ្ឋធម្មនុញ្ញនៅបស្ចឹមប្រទេសបានកត់សម្គាល់នូវភាពខុសគ្នារវាងទ្រឹស្តីសូវៀត និងទ្រឹស្តីបស្ចឹមប្រទេសលើគោលការណ៍ធំៗ៤ចំណុចៈ

<u>ចំណុចទី១:</u> ទ្រឹស្តីសូវៀតមិនផ្តោតសំខាន់ទៅលើសិទ្ធិមនុស្សទេ ប៉ុន្តែបង្កើតសិទ្ធិរបស់វណ្ណៈកម្មករ និងកសិករតែប៉ុណ្ណោះ ។ នៅក្នុងទ្រឹស្តីសង្គមនិយមសូវៀត សិទ្ធិមនុស្ស (Human Rights) ដែលបង្កើតឡើងនៅក្នុងប្រព័ន្ធមូលធននិយម គឺគ្រាន់តែជាសិទ្ធិប្រឌិតដើម្បីបំភ័ន្ត (Human Rights are regard as only fiction or illusion) ។ ដូច្នេះ នៅក្នុងប្រព័ន្ធមូលធននិយម ជាក់ស្តែងវាមានតែសិទ្ធិរបស់វណ្ណៈអ្នកមាន ហើយវណ្ណៈកម្មករ និងកសិករក្រីក្រគ្មានសិទ្ធិអីទេ ។ ហេតុនេះហើយក្នុងទ្រឹស្តីសង្គមនិយមសូវៀត វណ្ណៈសង្គមត្រូវបានលុបបំបាត់ចោល ហើយសិទ្ធិមិនត្រូវបានជានាសម្រាប់មនុស្សទូទៅទេ ប៉ុន្តែជានាការពារសម្រាប់តែកម្មករ និងកសិករតែប៉ុណ្ណោះ។

<u>ចំណុចទី២:</u> ទ្រឹស្តីសូវៀតមិនទទួលស្គាល់លើសិទ្ធិកម្មសិទ្ធិលើទ្រព្យសម្បត្តិឯកជនទេ (Private Property Rights) ប៉ុន្តែបានបង្កើតឲ្យមានសង្គមការបូណីយកម្មវិញ (Socialization) ។ នៅក្នុងប្រព័ន្ធទំនើបបស្ចឹមប្រទេស កម្មសិទ្ធិឯកជនគឺជាសិទ្ធិសំខាន់បំផុត ។ ប៉ុន្តែនៅក្នុងប្រវត្តិសាស្ត្រនៃការអភិវឌ្ឍ ទ្រឹស្តីស្មើភាពចំពោះមុខច្បាប់ក្នុងបរិបទសេដ្ឋកិច្ច បានបង្កើតឲ្យមាននូវបញ្ហាសង្គមជាច្រើន ។ ដូច្នេះហើយ នៅក្នុងរដ្ឋសង្គមនិយម កម្មសិទ្ធិទ្រព្យសម្បត្តិឯកជន ត្រូវបានលុបបំបាត់ចោល ហើយត្រូវបានរឹបអូសមកជាក់ជាសម្បត្តិរបស់រដ្ឋតាមស្មារតីសង្គមការបូណីយកម្មវិញ។

<u>ចំណុចទី៣:</u> ទ្រឹស្តីសូវៀតមិនជានាសិទ្ធិនៅលើតែក្រដាសទេ ប៉ុន្តែធ្វើឲ្យមានជាក់ស្តែងតែម្តង។ រដ្ឋធម្មនុញ្ញរបស់បស្ចឹមប្រទេស ជានាឲ្យមានសិទ្ធិតែនៅក្នុងច្បាប់ ជាសិទ្ធិលើក្រដាស ប៉ុន្តែមិនបានធ្វើឲ្យមាននៅភាពជាក់ស្តែងណាមួយនៅឡើយ ។ ឧទាហរណ៍ នៅក្នុងទ្រឹស្តីរដ្ឋសង្គមនិយម សេរីភាព

ក្នុងការបញ្ចេញមតិពិតប្រាកដណាមួយ វាតម្រូវឲ្យមានឧបករណ៍សម្ភារៈសម្រាប់បំរើឲ្យការសម្តែងមតិរបស់បុគ្គលនោះ មានដូចជា ក្រដាសស្នាម ប៊ិចសរសេរ ម៉ាស៊ីនបោះពុម្ពជាដើម ។ ដូច្នេះហើយកាលនោះនៅក្នុងរដ្ឋសង្គមនិយមរបស់សូវៀត ប្រជាជនត្រូវបានផ្តល់ឲ្យមានសម្ភារៈ សម្រាប់ធ្វើឲ្យរីករាយនូវការប្រើប្រាស់ សិទ្ធិសេរីភាពពិតៗ របស់ពួកគេ ជាពិសេសកម្មករ និងកសិករ ។

<u>ចំណុចទី៤:</u> ទ្រឹស្តីសូវៀត មិនបានបង្កើតឲ្យមានសេរីភាពផ្តាច់ពីរដ្ឋទេ ប៉ុន្តែសេរីភាពត្រូវធ្វើឲ្យមានឡើងដោយរដ្ឋ ។ សេរីភាពពីរដ្ឋ នៅក្នុងទស្សនៈរបស់សូវៀត មិនបានធ្វើឲ្យមាននូវសិទ្ធិពិតប្រាកដទេ ។ ប៉ុន្តែសេរីភាពត្រូវទទួលបានតាមរយៈរដ្ឋ ប្រសិនជារដ្ឋត្រូវបានគ្រប់គ្រងដោយវណ្ណៈកម្មករ និងកសិករក្រីក្រ ដែលជាតំណាងភាគច្រើនលើសលប់នៅក្នុងសង្គម ។

៣. រដ្ឋធម្មនុញ្ញប្រទេសអាឡឺម៉ង់ឆ្នាំ១៩១៩

ក្រោយសង្គ្រាមលោកទី១ (១៩១៩-១៨) ប្រទេសអាឡឺម៉ង់បានប្តូររបបនយោបាយ។ សាធារណរដ្ឋវៀមារ (Weimar Republic) ជារបបសាធារណរដ្ឋទី១ នៅក្នុងប្រវត្តិសាស្ត្រនយោបាយរបស់អាឡឺម៉ង់ ត្រូវបានបង្កើតឡើងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩១៨ នៅក្រោមស្ថានភាពនៃការចាញ់សង្គ្រាមផង និងក្រោមសំពាតចលនាបដិវត្តសង្គមផង (Social Revolution) បដិវត្តសង្គមនៅប្រទេសអាឡឺម៉ង់ មិនដូចគ្នាជាមួយនឹងបដិវត្តសង្គមនៅសូវៀតទេ ប៉ុន្តែវាជាការសំរុះសំរួលរវាងក្រុមនិន្នាការប្រជាធិបតេយ្យសេរី និងក្រុមនិន្នាការសង្គមនិយម អាឡឺម៉ង់ខ្លួនឯងហៅថាជារបបប្រជាធិបតេយ្យសង្គម (Social Democracy)។

រដ្ឋធម្មនុញ្ញថ្មីមួយរបស់របបសាធារណរដ្ឋនេះ ត្រូវបានអនុម័តប្រកាសឲ្យប្រើ នៅខែសីហា ឆ្នាំ១៩១៩ ដែលអាឡឺម៉ង់ហៅថារដ្ឋធម្មនុញ្ញវៀមារ (Weimar Constitution)[២] ។ កាលនោះ រដ្ឋធម្មនុញ្ញវៀមារនេះត្រូវបានគេចាត់ទុកថាមានលក្ខណៈប្រជាធិបតេយ្យល្អបំផុត ពីព្រោះបានឆ្លុះបញ្ចាំងពីការសម្របសម្រួលរវាងចលនាបដិវត្តទាំងពីរ។ ម៉្យាងបានបង្កើតឲ្យមាននូវប្រព័ន្ធប្រជាធិបតេយ្យសេរី ជំនួសឲ្យប្រជាធិបតេយ្យក្លែងក្លាយ ដែលបានដឹកនាំដោយព្រះចៅអធិរាជ្យ Kaiser និងម៉្យាងទៀត បានបង្កើតនូវទស្សនទានថ្មីស្តីពីសិទ្ធិមនុស្សក្នុងបរិបទថ្មីនៃសិទ្ធិសង្គម (Social Rights) ដើម្បីធ្វើឲ្យមានប្រៀបលើប្រព័ន្ធសង្គមនិយមថ្មីរបស់សហភាពសូវៀត ។ នៅក្នុងរដ្ឋធម្មនុញ្ញវៀមារ ១៩១៩ មានចំនុចចែងពីសិទ្ធិសង្គម៖

មាត្រា១៥១ កំណត់ព្រំដែនសេរីភាពសេដ្ឋកិច្ច (Economic Freedom) ត្បិតសេរីភាពសេដ្ឋកិច្ចដែលគ្មានព្រំដែនបង្កើតឲ្យមានវិបត្តិសង្គមច្រើន ជាពិសេសការប្រឈមមុខគ្នារវាងអ្នកមាន និងអ្នកក្រ។ សេរីភាពសេដ្ឋកិច្ចរបស់អាឡឺម៉ង់ ចងភ្ជាប់នឹងគោលការណ៍យុត្តិធម៌ (Principle of Justice)

និងសេចក្តីថ្លៃថ្នូរក្នុងជីវិត (Life in Dignity) ពីព្រោះអាឡឺម៉ង់ ដឹងថាសេដ្ឋកិច្ចមូលធន បានបំពានទៅលើគោលការណ៍ទាំងពីរនេះ ប្រសិនបើគ្មានការធានា និងធ្វើអន្តរាគមន៍ពីរដ្ឋនោះទេ ។

មាត្រា១៥៣ (៣) កំណត់ព្រំដែនសេរីភាពសេដ្ឋកិច្ច ក្នុងនោះទ្រព្យសម្បត្តិឯកជន ពុំមែនជាសិទ្ធិពិសិដ្ឋទេប្រសិនបើផលប្រយោជន៍រួមរបស់ប្រជាជនបានតម្រូវនោះ។ មាត្រា១៥៦ (១) ព្រំដែនសេរីភាពសេដ្ឋកិច្ច និងសង្គមការិបនីយកម្ម, ទំនាក់ទំនងកម្មសិទ្ធិឯកជន និងភាពចាំបាច់របស់រដ្ឋ។

មាត្រា១៥៧ (១) ទទួលស្គាល់និងបង្កើតសិទ្ធិសង្គមដោយជាក់ឲ្យមាននូវស្ថេរភាពនៅក្នុងទំនាក់ទំនងរវាងកម្មករ និងនិយោជិក ប៉ុន្តែតម្រូវឲ្យរដ្ឋការពារ អ្នកទន់ខ្សោយដែលជាកម្មករ ឬអ្នកក្រីក្រ ។

មាត្រា ១៥៩ សេរីភាពនៃការរៀបចំប្រមូលផ្តុំ (Freedom to Unite or Rights to Organize) ជាផ្នែកមួយនៃសិទ្ធិសង្គម។ កម្មករមានសិទ្ធិរៀបចំអង្គការសហជីពរបស់ខ្លួន ដើម្បីឲ្យមានទម្ងន់ក្នុងការទាមទារនូវស្ថានភាពប្រសើរក្នុងការងារ និងក្នុងសេដ្ឋកិច្ចជីវភាពរបស់ពួកគេ ។

មាត្រា១៦១ អំពីសិទ្ធិសង្គម។ រដ្ឋត្រូវបង្កើតប្រព័ន្ធធានាសង្គមទូលំទូលាយ១ (Comprehensive System of Social Insurance) សម្រាប់ការពារអ្នកទន់ខ្សោយ ក្នុងនោះមានកម្មករ និងអ្នកក្រីក្រជាដើម។ មាត្រា១៦៣ (៣) ចែងពីសិទ្ធិសង្គមសម្រាប់ពលរដ្ឋអាឡឺម៉ង់មានឱកាសស្មើភាពគ្នាក្នុងការរកស៊ីចិញ្ចឹមជីវិត តាមរយៈកម្លាំងពលកម្មរបស់ពួកគេ ហើយត្រូវបានទទួលនូវមូលនិធិពីរដ្ឋទៀតផងនៅពេលដែលពួកគេគ្មានការងារធ្វើ ។ មាត្រា ១៦៥ (១) ផ្តល់សិទ្ធិដល់កម្មករក្នុងការចូលរួមធ្វើសេចក្តីសម្រេចទាក់ទងនឹងស្ថានភាពរបស់ពួកគេ (Rights to Cooperate Decision) ។

ក្នុងការកត់សំគាស់ រដ្ឋធម្មនុញ្ញវៀមារអាឡឺម៉ង់ បានកែប្រែទស្សនទានទំនើបនៃសិទ្ធិមនុស្ស និងតួនាទីរបស់រដ្ឋដែលបានអនុវត្តនៅក្នុងប្រទេសមូលធននិយម តាមការកំណត់ព្រំដែនលើសេរីភាពសេដ្ឋកិច្ច លើកម្មសិទ្ធិឯកជន និងបង្កើតឲ្យមានសិទ្ធិសង្គមជានាគាំពារឡើងដោយរដ្ឋទៀតផង។ អ្នកសិក្សារដ្ឋធម្មនុញ្ញបានធ្វើការកត់សំគាល់ពីការសើរើកែប្រែនេះ ជាការចាប់ផ្តើមនៃរដ្ឋធម្មនុញ្ញទាន់សម័យមួយទៀត (The Contemporary Modern Constitution) ។ រដ្ឋប្តូរតួនាទីពីរដ្ឋក្នុងភាពអវិជ្ជមាន (Negative State) រដ្ឋអសកម្ម មកជារដ្ឋក្នុងភាពវិជ្ជមាន (Positive State) រដ្ឋសកម្ម ដែលតម្រូវឲ្យមានជាកាតព្វកិច្ចការពារគាំពារបម្រើរក្សាសុខុមាលភាពរបស់សង្គម (Welfare State) តាមការកំណត់ដោយរដ្ឋធម្មនុញ្ញ ក្នុងនោះមានដាក់បន្ថែមនូវសិទ្ធិរបស់រដ្ឋមួយចំនួនទៅក្នុងទ្រឹស្តីមានពីមុនស្រាប់ទស្សនទានសេរីភាពពីរដ្ឋ ។ នៅក្នុងទ្រឹស្តីថ្មីនេះ ម៉្យាងតម្រូវឲ្យរដ្ឋ មិនត្រូវបំពានលើសិទ្ធិពិសិដ្ឋរបស់ពលរដ្ឋណាម្នាក់ឡើយ ហើយម៉្យាងទៀតក៏

បានផ្តល់ឲ្យរដ្ឋនូវអំណាចអន្តរាគមន៍ជាលក្ខណៈវិជ្ជមាន (Positive Intervention) ដើម្បីធានាឲ្យមានការទទួលស្គាល់ទាំងអស់គ្នានូវសិទ្ធិពលរដ្ឋផង និងដើម្បីដោះស្រាយបញ្ហាសង្គមដែលកើតមានផង។

៤. រដ្ឋធម្មនុញ្ញប្រទេសជប៉ុនឆ្នាំ១៩៤៧

ក្រោយសង្គ្រាមលោកលើកទី២មក ប្រទេសជប៉ុន បានរៀបចំរដ្ឋធម្មនុញ្ញរបស់ខ្លួនជាថ្មី ក្រោមសំពាតរបស់អាមេរិកកាំង ដោយបានទទួលយកទ្រឹស្តីរដ្ឋធ្មនុញ្ញទំនើប និងទាន់សម័យ ។ មាត្រា១៣ តម្រូវឲ្យមានការគោរពសិទ្ធិបុគ្គល (Respect for Individuals) ជាសិទ្ធិមូលដ្ឋានរបស់ទ្រឹស្តីទំនើបបស្ចឹមប្រទេស ។ រដ្ឋធម្មនុញ្ញជប៉ុន បានស្រូបយកទ្រឹស្តីទំនើប។ ពីសេចក្តីប្រកាសឯករាជ្យភាពរបស់អាមេរិកកាំងដែលបានឈរលើទស្សនទានរបស់ John Locke ។ មាត្រា១៤ ផ្តល់ឲ្យមានសមភាពទូទៅចំពោះមុខច្បាប់ ។ មាត្រា១៩ ផ្តល់ឲ្យមានសិទ្ធិសេរីភាពក្នុងការគិតស្របតាមសតិសម្បជញ្ញៈផ្ទាល់ខ្លួន (Freedom of Thought and Conscience) ។ មាត្រា២0 ផ្តល់ឲ្យមានសេរីភាពខាងសាសនា (Freedom of Religion) ។ មាត្រា២១ ផ្តល់ឲ្យមានសេរីភាពខាងបញ្ចេញមតិ និងមាត្រា២៩ សិទ្ធិលើកម្មសិទ្ធិឯកជន ។ ល។ សិទ្ធិទាំងអស់នេះជប៉ុនហៅថាជាសិទ្ធិចំពោះសេរីភាព (Rights of Freedom) ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ។

ម៉្យាងវិញទៀត មាត្រា២២ និង២៩ ផ្តល់ឲ្យមានសេរីភាពសេដ្ឋកិច្ច ដែលផ្តោតលើកម្មសិទ្ធិឯកជន និងសេរីភាពខាងអាជីព ក៏ប៉ុន្តែសេរីភាពសេដ្ឋកិច្ចនេះ ត្រូវស្ថិតក្នុងក្របខណ្ឌសុខុមាលភាពសង្គម (Public Welfare) ។ បន្ថែមពីនេះទៀត មាត្រា២៥ ផ្តល់ឲ្យមាននូវសិទ្ធិទទួលការសង្គ្រោះ (Rights to Welfare) ដែលជប៉ុនហៅថា សិទ្ធិដើម្បីរស់រាន (Rights to Existence) ដែលបានទទួលឥទ្ធិពលពីទ្រឹស្តីរដ្ឋធម្មនុញ្ញវៀមាររបស់អាឡឺម៉ង់។ មាត្រា២៦ ផ្តល់ឲ្យមានសិទ្ធិសង្គម/សិទ្ធិទទួលបានការអប់រំ (Rights to Receive Education) ។ មាត្រា២៧ ផ្តល់សិទ្ធិសង្គម/សិទ្ធិធ្វើការងារ (Rights to Work) និងមាត្រា២៨ សិទ្ធិសង្គម/សិទ្ធិរៀបចំការតវ៉ា (Worker´s Rights to Organize and Bargain) ។ល។ ដូច្នេះជារួមមក យើងឃើញថា រដ្ឋធម្មនុញ្ញជប៉ុន ១៩៤៧ ក្នុងទ្រឹស្តីមានលក្ខណៈទំនើប ទាន់សម័យ និងទូលំទូលាយ។

៥. រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

រដ្ឋធម្មនុញ្ញកម្ពុជានៅបច្ចុប្បន្ននេះ ដែលបានអនុម័ត និងប្រកាសដាក់ឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ មានចរឹកទ្រឹស្តីជា រដ្ឋធម្មនុញ្ញទំនើប ទាន់សម័យ និងទូលំទូលាយ ដោយបានស្រូបទាញយកនូវទស្សនទានជឿនលឿនរបស់រដ្ឋបស្ចឹមប្រទេស និងបទពិសោធន៍នៃទ្រឹស្តីរដ្ឋធម្មនុញ្ញមុនៗ ដែលកម្ពុជាបានឆ្លងកាត់ ផ្សំបន្សុំគ្នាតាមលំនាំប្រជាធិបតេយ្យសង្គមរបស់អាឡឺម៉ង់ដែលរដ្ឋត្រូវគាំពារសង្គមជួយអ្នកក្រីក្រ។

មាត្រា៥១ និងមាត្រា ៥៦ កំណត់ពីរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។ មាត្រា៣១ ដល់៤៥ ប្រកាសទទួលស្គាល់និងគោរពសិទ្ធិមនុស្ស, សិទ្ធិស្មើភាពចំពោះមុខច្បាប់, សិទ្ធិក្នុងការរស់រានមានជីវិត និងមានសុវត្ថិភាពផ្ទាល់ខ្លួន សេរីភាពក្នុងការសម្តែងមតិ សិទ្ធិសេរីភាពក្នុងការ

ធ្វើកូដកម្ម និងបាតុកម្ម សិទ្ធិសេរីភាពក្នុងការប្រជុំ និងសិទ្ធិសេរីភាពក្នុងការចូលរួមជីវភាពនយោបាយជាដើម ដែលការប្រើប្រាស់សិទ្ធិសេរីភាពទាំងនេះ ត្រូវធានាការពារដោយច្បាប់។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានបង្កើតរដ្ឋវិជ្ជមាន និងសិទ្ធិសង្គម ដើម្បីធានាឲ្យមាននូវប្រព័ន្ធគាំពារសង្គម។ រដ្ឋត្រូវការពារ លើកស្ទួយសិទ្ធិទទួលបានការអប់រំ សេរីភាពសិក្សា និងស្មើភាពក្នុងការអប់រំ (មាត្រា៦៥)។ រដ្ឋធានាសុខភាពរបស់ប្រជាពលរដ្ឋ និងរដ្ឋត្រូវបង្កើតមន្ទីរពេទ្យទៅដល់ជនបទ (មាត្រា៧២)។ រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងស្ត្រី ជួយស្ត្រីមានកូនច្រើនក្នុងបន្ទុកហើយឥតទីពឹង (មាត្រា៧៣), រដ្ឋជួយឧបត្ថម្ភជនពិការ (មាត្រា៧៤), រដ្ឋចាត់ចែងឲ្យមានរបបសន្តិសុខសង្គមដល់កម្មករ និងនិយោជិត (មាត្រា៧៥)។

នេះជាទ្រឹស្តីសិទ្ធិទាន់សម័យ (សេរីនិយម និងសង្គមនិយម) ដែលមាននៅក្នុងរដ្ឋធម្មនុញ្ញរបស់យើង តម្រូវឲ្យរដ្ឋធ្វើអន្តរាគមន៍ជាលក្ខណៈវិជ្ជមាន ដើម្បីធ្វើឲ្យមានការទទួលស្គាល់នូវសិទ្ធិរបស់ពលរដ្ឋពេញលេញផង និងដើម្បីដោះស្រាយរាល់បញ្ហាសង្គមដែលកើតមានសម្រាប់រក្សាសុខុមាលភាពសង្គមផង ។ នេះជាបដិវត្តធម្មនុញ្ញមួយមិនធ្លាប់មានពីមុន ដោយបានស្រូបទាញនូវទស្សនៈជឿនលឿនពេញលេញ។

៦. សំឆ្លុះសិក្សាពិភាក្សា

(១) ឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញកម្ពុជាបានទទួលយកទ្រឹស្តីសង្គមនិយមបែបរដ្ឋសង្គមនិយមសូវៀត/វៀតណាម ។ តាមទស្សនៈលោក តើទ្រឹស្តីសង្គមនិយមសូវៀត/វៀតណាម អាចចាត់ថាជាទស្សនទានរដ្ឋធម្មនុញ្ញទំនើបដែរឬទេ? សូមផ្តល់ហេតុផលឲ្យបានច្បាស់លាស់ប្រសិនជាអាចធ្វើបាន ។

(២) រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ ជារដ្ឋធម្មនុញ្ញទំនើបទាន់សម័យ ពីព្រោះមានការទទួលស្គាល់ គោរព និងធានានូវសិទ្ធិសេរីភាព (Rights to Freedom) អធិបតេយ្យភាពប្រជារាស្ត្រ (Popular Sovereignty) និងបង្កើតឲ្យមានសិទ្ធិសង្គម (Social Rights) ជាច្រើន ។ ទស្សនទានសិទ្ធិសង្គម (Concept of Social Rights) តម្រូវឲ្យរដ្ឋត្រូវរៀបចំប្រព័ន្ធធានារ៉ាប់រងសង្គមមួយ (Comprehensive System of Insurance) ដ៏មានប្រសិទ្ធភាពសម្រាប់គាំពារ និងលើកស្ទួយស្ថានភាពសេដ្ឋកិច្ចអ្នកទន់ខ្សោយមានដូចជា កុមារ ស្ត្រីមេម៉ាយ ជនពិការភាព ជនក្រីក្រទុគ៌ត និងចាស់ជរា ជាដើមដើម្បីអាចរួមរស់ក្នុងសង្គមដូចគេដូចឯង។ចូរអ្នកសាកល្បងពិនិត្យមើលនៅក្នុងបរិបទជាក់ស្តែងកម្ពុជា តើសិទ្ធិសង្គមសម្រាប់អ្នកទន់ខ្សោយ ត្រូវបានបង្កើតដោយរដ្ឋហើយឬនៅ? សូមលើកឧទាហរណ៍ជាក់លាក់ណាមួយមកបញ្ជាក់ឲ្យបានច្បាស់លាស់ ។

ជំពូក៤

ប្រវត្តិនីតិរដ្ឋធម្មនុញ្ញកម្ពុជា

១. ទម្រង់រដ្ឋធម្មនុញ្ញខ្មែរសម័យបូរាណ

តាមប្រវត្តិសាស្ត្រ ប្រទេសកម្ពុជា ជារដ្ឋចំណាស់ឃ្លេងង់មួយ។ ប្រទេសនេះ បានឆ្លងកាត់បទពិសោធន៍ជាង២០០០ឆ្នាំ ក្នុងដំណើរការគ្រប់គ្រងរដ្ឋរបស់ខ្លួន គឺតាំងពីកំឡុងដើមសតវត្សទី១ ដែលមានឈ្មោះថា " **អាណាចក្រភ្នំ/ហ្វូណន/គោកធ្លក** " ក្រោមការគ្រប់គ្រងរបស់ព្រះចៅ **ហ៊ុន ទៀន** និង ព្រះនាង **លីវ យី** ដែលជាបុព្វវីរៈក្សត្រដើម។17 នេះជាមោទនភាពជាតិរបស់កម្ពុជា ។ ប៉ុន្តែសំនួរថា តើក្នុងសម័យកាលបុរាណនោះជាពិសេសមុនសម័យអាណានិគមបារាំងឆ្នាំ១៨៦៣ កម្ពុជាមានបានកសាងនូវប្បធម៌ធម្មនុញ្ញភាពរបស់ខ្លួនដែរឬទេ? បើអត្ថន័យធម្មនុញ្ញភាព (Constitutionalism) នេះគ្រាន់តែសំដៅតែលើទំនៀមទំលាប់ ឬជាវប្បធម៌ប្រពៃណីណាមួយ ដែលអាចទប់អំណាចរដ្ឋបានខ្លះ ឬធ្វើឲ្យព្រះមហាក្សត្រគោរពប្រតិបត្តិតាមនោះ គេអាចមើលឃើញភ្លាមថា ប្រទេសខ្មែរសម័យបុរាណ មានរដ្ឋធម្មនុញ្ញភាពរបស់ខ្លួន ។

១.១. រាជាធិបតេយ្យព្រហ្មញ្ញសាសនា

លិទ្ធិធម្មនុញ្ញភាពនាសម័យនោះគឺ ស្ថាបនាលើលិទ្ធិសាសនាជាគោល ។ លិទ្ធិសាសនាសំខាន់ៗ ដែលខ្មែរគោរពប្រតិបត្តិតាមនាសម័យនោះគឺ **ព្រហ្មញ្ញសាសនា** និង **ពុទ្ធសាសនា** ។18 តាមប្រវត្តិសាស្ត្រ នៅក្នុងសម័យលទ្ធិព្រាហ្មណ៍ ដែលមានឥទ្ធិពលខ្លាំងជាពិសេសនៅដើមសម័យអង្គរ រាជាណាចក្រខ្មែរបានកសាងវប្បធម៌ធម្មនុញ្ញភាពមួយឈរលើ " **លិទ្ធិទេវរាជ - គម្ពីត្រៃវេទ** " ក្នុងនោះព្រះមហាក្សត្រជាតំណាងឲ្យអាទិទេពហៅថា " **ស្តេចទេវរាជ** " ដែលតំណាងឲ្យសភាវល្អ ។ ក្នុងលទ្ធិនេះអំណាចស្តេច ធំមហិមារក៏ពិតមែន ប៉ុន្តែអំណាចនេះក្នុងភាពជាក់ស្តែងត្រូវបានទប់ដោយច្បាប់គម្ពីវេទ ដែលតម្រូវឲ្យស្តេចត្រូវតែគោរព និងអនុវត្តតាមដោយខានពុំបាន ។ ច្បាប់គម្ពីទេវនេះ ត្រូវបានឃ្លាំមើលយ៉ាងជិតដល់ពីសំណាក់ក្រុមព្រាហ្មបុរោហិត

---

17 មើល ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ បោះពុម្ពនៅឆ្នាំ ១៩៧២ ក្នុងជំពូកទី១ អំពីការកកើតនៃរាជាណាចក្រខ្មែរ ។ ឬមើល អាដេម៉ារលើក្លែរ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា បោះពុម្ពនៅឆ្នាំ ១៩១៤ នៅក្នុងជំពូកទី១ ១៧-១៨ ។

18 បើតាមលោកសាស្ត្រាចារ្យ កេងវ៉ាន់ សាក់ ខ្មែរគោរពជំនឿផ្ទាល់ខ្លួនមួយទៀត ដែលគាត់ហៅថា **<u>សាសនាជី</u>** ។ សាសនាជី របស់ខ្មែរគោរព លើធាតុ ៥ គឺ **ព្រះ + តា + មេ + បា + ចៅ** និងរួមផ្សំជាមួយធាតុផ្សេងៗទៀតមានដូចជា ពពួកអារក្ស ធ្មប់ អាប និងម្រេញកង្វាល ដែលប្រព័ន្ធ ជំនឿនេះស្ថិតថា សាសនាបរទេស - ព្រាហ្មសាសនា និង ពុទ្ធសាសនា- គ្មានធាតុនៃជំនឿនោះទេ ។ ដកស្រង់ពីកិច្ចសំភាសន៍ក្នុងវិទ្យុអាស៊ីសេរី នាឆ្នាំ ២០០៥ ។ ស្របគ្នានេះដែរ លោកបណ្ឌិត មីសែល ត្រាណេ ក៏មានលើកយកបង្ហាញខ្លះៗក្នុងសៀវភៅរបស់លោកស្តីពីប្រវត្តិសាស្ត្រនៃ កម្ពុជាការបង្កើតរដ្ឋ ២០០២ ទំ ១០៦ ។

ល្បីកំពូល។ ដែលជាទីប្រឹក្សាឬព្រះគ្រូរបស់ព្រះអង្គផ្ទាល់ ។19 គម្ពីវេទកំណត់នូវករណីកិច្ចផ្នែកសីលធម៌មួយចំនួនដល់ស្តេចខ្មែរឲ្យអនុវត្តតាម ក្នុងនោះតម្រូវឲ្យស្តេច ត្រូវកសាងការពារ និងលើកកំពស់អ្នកធ្វើទង្វើល្អ តំណាងសភាវល្អ និងទប់ស្កាត់ទង្វើអាក្រក់ សភាវអាក្រក់ ។20 ទ្រឹស្តីទេវរាជ បានបង្កើតទ្រឹស្តីធម្មនុញ្ញភាពជាទម្រង់ទេវកថា ដែលនិយ័តកម្មអង្គព្រះមហាក្សត្រជានិមិត្តរូបអាទិទេពនៃសភាវល្អ មានឫទ្ធីបារមីជេស្តា (អំណាច) និងជាអ្នកការពារ (វ៉ែន) នគរប្រឆាំង នឹងមារសត្រូវដែលជាអង្គសភាវអាក្រក់ ដែលប្រជានុរាស្ត្រក្នុងនគរត្រូវការជាចាំបាច់ដើម្បីសេចក្តីសុខ។21 បើយើងសិក្សារឿងទេវកថា ក្នុងគម្ពីត្រៃវេទ ឬត្រីយុត្ត ឃើញមានអង្គអាទិទេពបីសំខាន់នៃតួអង្គសភាវល្អ ព្រះឥសូរ ព្រះនារយណ៍ (ព្រះវិស្ណុ) និងព្រះព្រហ្ម ហើយអង្គព្រះមហាក្សត្រជាតួអង្គអាទិទេពនៃព្រះនារយណ៍ដែលចាប់ជាតិជាស្តេច ព្រះរាមធ្វើសង្គ្រាមផ្ទាញ់សភាវ អាក្រក់តំណាងដោយពពួកយក្សាដើម្បីការពារប្រជានុសាស្ត្រស្លូតត្រង់ ។ បើនិយាយឲ្យខ្លី ធម្មនុញ្ញភាពនៃលិទ្ធិព្រាហ្មនាសម័យនោះ អង្គព្រះមហាក្សត្យជាអាទិទេព តំណាងសភាវល្អ ជាអ្នកការពារសេរីភាព ។ល។

១.២. រាជាធិបតេយ្យពុទ្ធសាសនា

ចាប់ពីចុងសម័យអង្គរមក លទ្ធិទេវរាជតាមព្រហ្មញ្ញសាសនាបានសាបរលាបថយចុះបន្តិចម្តងៗ រហូតមកដល់សតវត្សទី១៤ ព្រះពុទ្ធសាសនាក្លាយជាសាសនារបស់រដ្ឋនៅក្នុងសង្គមខ្មែររហូតដល់បច្ចុប្បន្ននេះ។ នៅក្នុងលទ្ធិពុទ្ធនិយមខ្មែរ ព្រះមហាក្សត្រតំណាងឲ្យតួអង្គព្រះពោធិសាធ៍ ជាអ្នកមានបុណ្យបារមី និងតម្រូវឲ្យប្រកាន់ " ទសពិធរាជធម៌ " និង " ព្រហ្មវិហារធម៌ " នៅក្នុងការដឹកនាំរដ្ឋតាមពុទ្ធឱវាទ។ " ទសពិធរាជធម៌ " និង " ព្រហ្មវិហារធម៌ " ជាធម្មនុញ្ញភាពនៃលទ្ធិពុទ្ធនិយម ពីព្រោះបានដាក់កំហិតជាបទប្បញ្ញត្តិជាក្រមសីលធម៌សម្រាប់ស្តេច និងប្រជារាស្ត្រឲ្យប្រតិបត្តិតាមជាប់លាប់ដើម្បីធានាឲ្យព្រះនគរមានសន្តិភាពយូរអង្វែង ។

ព្រហ្មវិហារធម៌ ៤ ប្រការ : 22

១- មេត្តា = ការមានចិត្តអាណិតស្រឡាញ់ចង់ឲ្យអ្នកដទៃបានក្តីសុខ ។
២- ករុណា = ការមានចិត្តសន្តោសជួយអ្នកដទៃប្រាស់ចាករួចពីទុក្ខ ។
៣- មុទិតា = ការមានចិត្តត្រេកអរពេលដែលអ្នកដទៃបានសុខ ឬមានកិត្តិយស ។

---

19 មើល ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២ ៩៤៤-៩៦៨ ។

20 មើល អាដេម៉ារ ឡឺក្លែរ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា បោះពុម្ពនៅឆ្នាំ ១៩១៤ នៅក្នុងជំពូកទី១ ៦៣ និង ១១៩ ។

21 ទ្រឹស្តីព្រាហ្មសាសនា បកស្រាយក្នុងគម្ពីរត្រៃវេទបែបទេវកថា ។ សូមមើល បណ្ឌិត **មីសែលត្រាណេ** ប្រវត្តិសាស្ត្រ នៃប្រទេសកម្ពុជា ការបង្កើតរដ្ឋថ្មី បោះពុម្ពនាឆ្នាំ ២០០២ ទំព័រ ៤៨-១២០ និង ប្រព័ន្ធគំនិតខ្មែរ ភាគ២ មាននិយាយ លំអិតអំពីត្រៃវេទ ។

22 ដកស្រង់ចេញពីសន្ទរកថាស្វាគមន៍របស់ឯកឧត្តមបណ្ឌិត ជាម យៀប ប្រធានគណៈកម្មការរៀបចំជួសជុល និងសាងសង់វិមាននៃរដ្ឋសភា ថ្លែងក្នុងការសម្ពោធន៍វិមានរដ្ឋសភា ថ្ងៃទី ០៧ កក្កដា ឆ្នាំ ២០០៧ ។

៤- ឧបេក្ខា = ការដាក់ចិត្តនៅកណ្តាលដើម្បីប្រាស់ចាកនូវការភ័យខ្លាចនានា និង
ភាពមិនលម្អៀងដោយការស្រឡាញ់ ការច្រណែន ឬ ការស្អប់ខ្ពើម ។

ទសពិធរាជធម៌ ១០ ប្រការ : 23

១- ទាន	ការឲ្យអំណាចដើម្បីដោះស្រាយបញ្ហាជីវភាពទន់ខ្សោយរបស់ប្រជារាស្ត្រ
២- សីល	ការកាន់អំណាចយុត្តិធម៌ដោយបើកឲ្យមានសេរីភាពដល់ប្រជារាស្ត្រ
៣- បរិច្ចាគ	ការបដិសេធចោលអស្មិមាន: អាត្មានិយមឲ្យអស់ចេញពីសន្តានរបស់ខ្លួន
៤- អាជ្ជវ	ការប្រកាន់សច្ចៈទៀងត្រង់
៥- មទ្ទវ	ការមានឥរិយាបទស្លូតបូតសុភាពរាបសាដោយកាយសោយវាចារ
៦- តប	ការរក្សាសីល៥ ចាំសីល៨
៧- អក្កោធន	ការមិនធ្វើឲ្យអ្នកផងក្តៅក្រហាយដោយសារខ្លួន
៨- អវិហិង្សា	ការមិនបៀតបៀនព្យាបាទអ្នកដទៃឲ្យវិនាសដោយសារកំហឹងរបស់ខ្លួន
៩- ខន្តី	ការមានចិត្តធំណត់អត់ធន់
១០- អវិរោធ	ការមិនជិះជាន់ច្បាប់ គឺមិនយកច្បាប់មកទ្រាប់អង្គុយ ។

សរុបមកយើងឃើញថា ប្រទេសកម្ពុជាក្នុងសម័យបុរាណ បានស្ថាបនាទ្រឹស្តីធម្មនុញ្ញភាពរបស់ខ្លួនតាមរយៈ " ក្រមទេវរាជ " និង " ទសពិធរាជធម៌ " ដែលឈរលើលទ្ធិសាសនាជាគោល ។ ក្រមសាសនាទាំងនោះ បានផ្តល់ជាឱវាទឲ្យព្រះមហាក្សត្រខ្មែរ ដែលជាតួអង្គនៃអំណាចរដ្ឋ គួរទទួលយក និងប្រតិបត្តិតាមគោលការណ៍មនុស្សធម៌ និងយុត្តិធម៌ សម្រាប់ឲ្យមានសន្តិភាពក្នុងព្រះនគរ ។ ព្រះមហាក្សត្រខ្មែរ ជាទេវរាជ និងជាព្រះពោធិក្សត្រិយ៍ និងជាស្នូលអំណាចកំពូលរបស់រដ្ឋ គឺជាលទ្ធិរាជាធិបតេយ្យ (Absolute Monarchy) ហើយសិទ្ធិ និងសេរីភាពរបស់ប្រជារាស្ត្រ ជាសិទ្ធិសេរីភាពសមទានពីព្រះមហាក្សត្រតាមព្រះឱវាទនៃក្រមទេវរាជ ឬទសពិធរាជធម៌ និងព្រហ្មវិហារធម៌។ សំឡេកព្រះបាទវរ្ម័នទី៧ "ទុក្ខរបស់ប្រជារាស្ត្រជាទុក្ខផ្ទាល់របស់ព្រះមហាក្សត្រ" ជាការប្រតិបត្តិតាមគោលការណ៍ ទសពិធរាជធម៌ និង ព្រហ្មវិហារធម៌ នៅសម័យអង្គរដែលលេចចេញនៅពន្លកទស្សនមួយផ្នែកនៃលទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលដើម្បីប្រជារាស្ត្រ ។

ម៉្យាងវិញទៀត បើន័យធម្មនុញ្ញភាពសំដៅលើការកំណត់ព្រំដែនអំណាចរដ្ឋដោយឆន្ទៈរបស់សហគមន៍ដោយ ឈរលើគោលការណ៍ជានាអះអាងឲ្យមានសិទ្ធិមនុស្ស អធិបតេយ្យភាពពលរដ្ឋ និងការបែងចែងអំណាចជាមូលដ្ឋានវិញនោះ រដ្ឋបុរាណរបស់ខ្មែរពុំមានរដ្ឋធម្មនុញ្ញទេ។ ទស្សនទានរដ្ឋធម្មនុញ្ញទំនើប ដែល

23 ដក់ស្រង់ចេញពីសេចក្តីប្រកាសសាធារណៈរដ្ឋខ្មែរ ថ្លែងដោយលោក អ៊ិន តាំ ប្រធានរដ្ឋសភាក្នុងនាមប្រជាជាតិខ្មែរ ថ្ងៃ៩ តុលា ឆ្នាំ១៩៧០។

ឈរលើគោលការណ៍សសិទ្ធិមនុស្ស (សេរីភាព) ប្រជាធិបតេយ្យសេរី មិនមែនជាវប្បធម៌ធម្មនុញ្ញភាពដើមរបស់រដ្ឋខ្មែរបុរាណទេ ប៉ុន្តែវាជាវប្បធម៌ធម្មនុញ្ញភាពរបស់រដ្ឋបស្ចឹមប្រទេស ។ គំនិតទំនើបទាំងនោះជ្រាបចូលមកកម្ពុជាសន្សឹមៗ តាមរយៈការគ្រប់គ្រងនាសម័យអាណានិគមនិយមបារាំងផង និងតាមរយៈបញ្ញាជនខ្មែរដែលបានរៀនសូត្រជ្រៅជ្រះនៅស្រុកបារាំងផង និងក្រោយមកត្រូវបានធ្វើឲ្យទៅជាការអនុវត្តជាក់ស្តែង តាមរយៈព្រះរាជបូជនីកិច្ច និងព្រះរាជពលិកម្មពីព្រះមហាក្សត្រខ្មែរ និងបញ្ញាវន្តរបស់ទ្រង់ទាំងនោះ ។

២. ទម្រង់រដ្ឋធម្មនុញ្ញខ្មែរសម័យទំនើប

តាមប្រវត្តិសាស្ត្រ កម្ពុជាទទួលបានយកទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើបមកអនុវត្តតាំងពីឆ្នាំ១៩៤៧ និងបើគិតមកដល់ត្រឹមឆ្នាំ១៩៩៣ មានរយៈពេលជិតកន្លះសតវត្ស កម្ពុជាបានដោះដូរទម្រង់រដ្ឋធម្មនុញ្ញញឹកញាប់រត់តាមនិន្នាការមនោគមន៍វិជ្ជារវាង រាជានិយម និងសាធារណរដ្ឋ និងរវាងប្រជាធិបតេយ្យ និងសង្គមនិយម ។ បញ្ហានេះ បើពិនិត្យមើល និងធ្វើការវិភាគខ្លះៗ ឈរលើទស្សនទំនើបជាមូលដ្ឋាន សិក្សាមើលពីចរឹក និងលក្ខណៈនៃរដ្ឋធម្មនុញ្ញខ្មែរនៅក្នុងទម្រង់នីមួយៗ ធ្វើឲ្យយើងអាចយល់ដឹងបានកាន់តែទូលំទូលាយ។

២.១. រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ (រាជាណាចក្រកម្ពុជា ១៩៤៧ - ១៩៧0)

បន្ទាប់ពីចប់សង្គ្រាមលោកលើកទី២ រួមផ្សំជាមួយការកៀបសង្កត់ពីចលនាបដិវត្តក្នុងស្រុក ដើម្បីឯករាជ្យនិង ប្រជាធិបតេយ្យ ប្រទេសបារាំងបានយល់ព្រមទទួលស្គាល់អធិបតេយ្យភាពផ្ទៃក្នុងខ្លះរបស់កម្ពុជា ។ កាលនោះ បារាំងបានជំរុញឲ្យប្រទេសកម្ពុជា រៀបចំច្បាប់រដ្ឋធម្មនុញ្ញមួយ ហើយព្រះមហាក្សត្រខ្មែរក៏បានទទួលយល់ព្រម។24 ពង្រាងដំបូងដែលរៀបចំដោយគណៈកម្មការចំរុះបារាំង-ខ្មែរ បានស្នើឲ្យមានទម្រង់រដ្ឋតាមគំរូរាជានិយមដូចនៅបណ្តាប្រទេសអារ៉ាប់ ដែលមានលក្ខណៈប្រជាធិបតេយ្យតិចតួច។25 ប៉ុន្តែព្រះមហាក្សត្រខ្មែរបានស្នើឲ្យបង្កើតសភាតំណាងប្រជារាស្ត្រមួយដើម្បីពិគ្រោះយោបល់បន្ថែមលើសេចក្តីព្រាងនេះ ។ សភាតំណាងប្រជារាស្ត្រ ត្រូវបានបង្កើតភ្លាមតាមរយៈការបោះឆ្នោតប្រជាធិបតេយ្យដំបូង ដោយមានការចូលរួមពីគណៈបក្សនយោបាយខ្មែរជាច្រើន ជាពុហបក្ស។ ក្នុងការឃោសនាបោះឆ្នោត គេឃើញមានគណបក្សពីរមានជំហរនយោបាយផ្ទុយគ្នាលើទម្រង់រដ្ឋធម្មនុញ្ញ។26 គណបក្សប្រជាធិបតេយ្យដែលរួមមានសមាជិកភាគច្រើនជាគ្រូបង្រៀន មន្ត្រីរដ្ឋតូចតាច និងក្រុមចលនាខ្មែរឥស្សរៈ ពេញចិត្តឲ្យមានការផ្លាស់ប្តូរមួយ (Status Change) ដោយប្រាថ្នាចង់ឲ្យមានរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញប្រជាធិបតេយ្យដែលព្រះមហាក្សត្រគ្រងរាជសម្បត្តិ ស្របតាមគំរូរដ្ឋធម្មនុញ្ញសាធារណរដ្ឋទី៤របស់បារាំង និងជារដ្ឋមានឯករាជ

24 មើល ឃឹម អ៊ី ច្បាប់រដ្ឋធម្មនុញ្ញខ្មែរ ក្បាលទី១ អត្ថបទ រដ្ឋធម្មនុញ្ញខ្មែរ បោះពុម្ពលើកទី១ ឆ្នាំ១៩៩៧ ទំព័រទី២ ។

25 See David Chadler, A History of Cambodia, 2000 (3rd edition), p. 173-189.

26 មើលកំណត់ខាងលើ David Chadler ។ គណៈបក្សឈ្នះឆ្នោតទី១ គឺគណៈបក្សប្រជាធិបតេយ្យដែលដឹកនាំដោយ ព្រះអង្គម្ចាស់ ស៊ីសុវត្ថ យុទ្ធវង្ស និង គណៈបក្សឈ្នះឆ្នោតទី២ គឺគណៈបក្សសេរីនិយម ដឹកនាំដោយព្រះអង្គម្ចាស់នរត្តម នរិន្ទដេត ។

លេញលេញមួយ ។ ដោយឡែក គណបក្សសេរីដែលគាំទ្រដោយបារាំង និងមានសមាជិកសភាគច្រើនជាមន្ត្រីតុលាការ មន្ត្រីថ្នាក់ធំៗ ក្នុងរាជរដ្ឋាភិបាល និងពួកអ្នកមានជាឧកញ៉ា បានពេញចិត្តឲ្យរក្សានូវស្ថានភាពដដែល (Status Quo) គឺជារបបរាជានិយមមានព្រះមហាក្សត្រកាន់អំណាច ដូចក្នុងសេចក្តីព្រាងដើម។

កម្មវិធីនយោបាយរបស់គណបក្សនយោបាយប្រជាធិបតេយ្យ បានទទួលការគាំទ្រច្រើនលើសលប់ ពីប្រជាពលរដ្ឋខ្មែរដោយឈ្នះអាសនៈក្នុងសភាធម្មនុញ្ញដំបូងឆ្នាំ១៩៤៦។ សភាតំណាងរាស្ត្របានប្រកាសជំហររៀបចំសេចក្តីព្រាងរដ្ឋធម្មនុញ្ញទំនើបមួយថ្មីដោយអង្គឯង និងដាក់ពិភាក្សាអនុម័ត និងប្រកាសឲ្យប្រើនៅឆ្នាំ ១៩៤៧ ក្រោមការសម្រុះសម្រួលមួយរវាងនិន្នាការអ្នករាជានិយម និងអ្នកប្រជាធិបតេយ្យនិយម ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ បង្កើតឲ្យមាននូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញនិងប្រតិបត្តិតាមលទ្ធិប្រជាធិបតេយ្យពហុបក្ស ជាទម្រង់រដ្ឋាភិបាលសភានិយម (Parliamentary Government) ។ បើយើងពិនិត្យសិក្សាលើរដ្ឋធម្មនុញ្ញនេះ មានលក្ខណៈជាទម្រង់ហាយប្រឹតផ្សំប្រពៃណី និងទំនើប ដោយម្យ៉ាងរក្សាស្ថានភាពដើមដែលកំណត់ព្រះមហាក្សត្រជាម្ចាស់អំណាច និងម្យ៉ាងទៀតប្រជាធិបតេយ្យតំណាងយកលំនាំតាមរដ្ឋធម្មនុញ្ញសាធារណរដ្ឋទី៤របស់ប្រទេសបារាំងជាទម្រង់រដ្ឋាភិបាលអាស្រ័យសភាពហុបក្ស។ រដ្ឋធម្មនុញ្ញក៏បានប្រកាសទទួលស្គាល់និងគោរពសិទ្ធិសេរីភាពពលរដ្ឋមួយចំនួន ជាស្មារតីពាក់កណ្តាលទំនើប។


(១) អំណាចរដ្ឋទាំងអស់ជារបស់ព្រះមហាក្សត្រ ពុំមែនរបស់ប្រជារាស្ត្រទេ (មាត្រា២១ & បុព្វកថា) ក៏ប៉ុន្តែអំណាចទាំងនោះត្រូវប្រើទៅតាមបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញ។ ក្នុងន័យនេះមិនមានការបែងចែកអំណាចក្នុងរាជរដ្ឋាភិបាលទេ ប៉ុន្តែគ្រាន់តែជាការបែងចែកសមត្ថកិច្ចរវាងគ្នានិងគ្នា ក្នុងនោះមានព្រះមហាក្សត្រជាម្ចាស់នៃអំណាច ។ ក្នុងនាមព្រះមហាក្សត្ររដ្ឋសភា ជាអ្នកប្រើអំណាចនីតិប្បញ្ញត្តិ (មាត្រា២២) គណៈរដ្ឋមន្ត្រីជាអ្នកប្រើអំណាចនីតិប្រតិបត្តិ (មាត្រា២៣) និងសាលាជំរះក្តីជាអ្នកប្រើអំណាចតុលាការ (មាត្រា ២៤) ។ មួយវិញទៀតរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ បានប្រទានឋានៈរដ្ឋកំពូលៗ ដល់ព្រះមហាក្សត្រដែលនៅក្នុងនោះព្រះអង្គទ្រង់ជាអគ្គប្រមុខរដ្ឋ និងជាទីសក្ការៈដែលគ្មាននរណាល្មើសបាន (មាត្រា៣៥) ហើយព្រះអង្គក៏ទ្រង់ជាអគ្គសេនាប្រមុខលើកងកម្លាំងយោធាទាំងមូល (មាត្រា៤៥) ក៏ប៉ុន្តែការប្រើប្រាស់នូវរាជសិទ្ធិធំៗមួយចំនួន តម្រូវឲ្យស្របទៅតាមបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញ ។ ព្រះរាជបុព្វសិទ្ធិជ្រើសរើស និងតែងតាំងនាយករដ្ឋមន្ត្រី តម្រូវឲ្យមានការពិគ្រោះយោបល់ជាមួយប្រធានសភាទាំងពីរ និងប្រធានគណបក្សនានា (មាត្រា ៨០) ។ ព្រះរាជសិទ្ធិប្រទានសច្ចាប័នដល់សន្ធិសញ្ញាឬក៏ច្បាប់គឺអាស្រ័យតាមការអនុម័តនៃរដ្ឋសភា។ល។

ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែងវិញ អំណាចព្រះមហាក្សត្រត្រូវបានរួមតូចជានិមិត្តរូប ហើយរដ្ឋសភាជាតិដែលជាតំណាងប្រជារាស្ត្រតាមការបោះឆ្នោតដោយផ្ទាល់ បានដើរតួនាទីជាម្ចាស់នៃអំណាចពិត នៅក្នុងដំណើរប្រជាធិបតេយ្យ ដែលនេះជាលំនាំតាមរដ្ឋសភាជាតិបារាំង ឆ្នាំ១៩៤៦-១៩៥៨ ។

(២) រដ្ឋធម្មនុញ្ញ១៩៤៧ បានធានានូវសិទ្ធិមនុស្សមួយចំនួន ប៉ុន្តែសិទ្ធិនិងសេរីភាពទាំងនោះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមអំណាចច្បាប់ដែលធ្វើឡើងដោយរដ្ឋសភា គោលការណ៍ស្មើភាពចំពោះមុខច្បាប់នៅមានភាពមិនច្បាស់លាស់ (មាត្រា៤៨-៤៩) និងសិទ្ធិជំទាស់ពីលើព្រះមហាក្សត្រត្រូវបានដកហូត (មាត្រា ១៦-៣៦) ។ មួយវិញទៀតរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ មានចែងពីសិទ្ធិសង្គមតិចតួច ប៉ុន្តែបានបង្កើតនូវកាតព្វកិច្ចគោរពព្រះមហាក្សត្រ គោរពច្បាប់ និងបង់ពន្ធជូនរដ្ឋ (មាត្រា១៦) ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋធម្មនុញ្ញនេះបានទទួលស្គាល់នូវ គោលការណ៍សេរីភាព និងការគោរពសិទ្ធិមនុស្ស (មាត្រា៣-១៦) ។

ឆ្លងកាត់ការអនុវត្ត រដ្ឋធម្មនុញ្ញនេះត្រូវបានធ្វើវិសោធនកម្មជារយៈរយៈ ក្នុងនោះសិទ្ធិសេរីភាពប្រជាពលរដ្ឋខ្មែរត្រូវបានពង្រីក ផ្តល់ឲ្យស្ត្រីភេទមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោត ប្រជារាស្ត្រមានសិទ្ធិដកហូតអ្នកតំណាងខ្លួនបាន បង្កើតសភាតំណាងរាស្ត្រប្រចាំខេត្តក្រុង បង្កើតឲ្យមានសមាជជាតិ និងបង្កើតឲ្យមានការធ្វើមតិលើបញ្ហាសំខាន់ៗរបស់ជាតិជាដើម ។ នៅក្នុងបរិបទនេះ អធិបតេយ្យប្រជារាស្ត្រត្រូវបានបង្កើតឲ្យមាននៅក្នុងភាពជាក់ស្តែង (De Facto) ទោះជាច្បាប់ (De Jure) គ្មានចែងក៏ដោយ ។

រចនាសម្ព័ន្ធស្ថាប័នធម្មនុញ្ញរាជាណាចក្រកម្ពុជា (១៩៤៧-១៩៧0)



២.២. រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ (សាធារណរដ្ឋខ្មែរ ១៩៧០ - ១៩៧៥)

ព្រឹត្តិការណ៍ថ្ងៃទី ១៨ ខែមិនា ឆ្នាំ១៩៧០ ជារដ្ឋប្រហារដើម្បីប្រកាសដួរបបនយោបាយ។ រដ្ឋប្រហារយោធាបានរំលាយរបបរាជានិយមដោយជំនួសមកវិញនូវរបបសាធារណរដ្ឋខ្មែរ ហើយទម្រង់រដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានប្រកាសដាក់ឲ្យប្រើនៅថ្ងៃទី ១០ ឧសភា ១៩៧២ បន្ទាប់ពីដាក់ធ្វើប្រជាមតិរួចមក ។27 រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ បានបង្កើតរបបសាធារណរដ្ឋខ្មែរយកតាមទម្រង់រដ្ឋបស្ចឹមប្រទេស ទម្រង់ទ្រឹស្តីរដ្ឋធម្មនុញ្ញបារាំង និងអារិកាំង ប៉ុន្តែមានលក្ខណៈជាប្រជាធិបតេយ្យនិយមសង្គម ឬសាធារណរដ្ឋនិយមសង្គម ។

(១) រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ ប្រកាសទទួលស្គាល់អធិបតេយ្យប្រជារាស្ត្រ។ អំណាចគ្រប់យ៉ាងចេញមកពីប្រជារាស្ត្រ (មាត្រា៣) ។ មាត្រាទី១ ចែងអំពីគោលការណ៍សំខាន់ៗ របស់សាធារណរដ្ឋខ្មែរ ដូចជា តម្រូវឲ្យកម្ពុជា ជាសាធារណរដ្ឋឯករាជ្យ ប្រជាធិបតេយ្យ និងនិយមប្រយោជន៍សង្គម ដែលឈរលើស្មារតីរដ្ឋាភិបាលរបស់ប្រជារាស្ត្រ ដោយប្រជារាស្ត្រ និងដើម្បីប្រជារាស្ត្រ ស្របជាមួយនឹងបាវចនាដើម្បីសេរីភាព សមភាព ភាតរភាព វឌ្ឍនភាព និង សុភមង្គល ។ ក្នុងបុព្វកថា ប្រកាសអំពីការប្តេជ្ញាចិត្តជម្រុញឲ្យមានប្រជាធិបតេយ្យការរួនីកម្មទាំងក្នុងផ្នែកនយោបាយនិងផ្នែកសង្គម ។ នេះជាការវិវត្តវិជ្ជមានក្នុងទ្រឹស្តីរដ្ឋធម្មនុញ្ញខ្មែរ ដោយនាំមកនូវការផ្លាស់ប្តូរទាំងស្រុងពីទ្រឹស្តីមុនៗ ដែលព្រះមហាក្សត្រជាម្ចាស់នៃអំណាចទាំងអស់ ។

(២) ទទួលស្គាល់ការគោរពសិទ្ធិមនុស្សកំណត់ដោយច្បាប់និងចងក្ខាប់ជាមួយសន្តិសុខជាតិ។ មាត្រាទី៥ ជានាសិទ្ធិសេរីភាពកំណត់ក្នុងច្បាប់។ ផ្តល់ឲ្យមានសេរីភាពខាងនយោបាយ ប៉ុន្តែជម្រុញឲ្យរដ្ឋយកចិត្តទុកដាក់តែក្នុងក្របខណ្ឌបក្សពីរ និងប្រកាន់តាមគោលការណ៍សាធារណរដ្ឋ (មាត្រា៩ ៤ & ៨៨) ។ ទទួលស្គាល់សេរីភាពរួបរួមជាសមាគមន៍ និងសិទ្ធិរួមប្រជុំ ប៉ុន្តែការប្រើសេរីភាព និងសិទ្ធិទាំងនេះ អាចកាត់បន្ថយបាន បើបះពាល់ទៅដល់សិទ្ធិអ្នកដទៃទៀត (មាត្រា៨) ។ មាត្រា២ ផ្តល់ឲ្យមានសេរីភាពខាងជំនឿ និងខាងប្រតិបត្តិខាងផ្លូវសាសនា ប៉ុន្តែអាចកាត់បន្ថយដោយរដ្ឋមកវិញ ប្រសិនជាកិច្ចការរក្សារបៀបរៀបរយសាធារណៈតម្រូវឲ្យធ្វើ ។ មាត្រា៧ ផ្តល់ឲ្យមានសេរីភាពខាងបញ្ចេញមតិ និងសេរីភាពខាងសារព័ត៌មាន ប៉ុន្តែការប្រើប្រាស់សិទ្ធិទាំងនេះ មិនត្រូវឲ្យខូចរបៀបរៀបរយសាធារណៈ ឬបះពាល់ដល់សន្តិសុខជាតិទេ ។ ទោសប្រហារជីវិតត្រូវបំបាត់ចោល លើកលែងតែក្នុងករណីប្រទេសជាតិប្រកាសថាស្ថិតក្នុងភ័យន្តរាយ ។ ប៉ុន្តែឃើញមានចំនុចជឿនលឿន ការពង្រីកសិទ្ធិបោះឆ្នោត ដោយបន្ថយអាយុពី២០ឆ្នាំ មក១៨ឆ្នាំ ។

27 អំពីការតាក់តែងរដ្ឋធម្មនុញ្ញនេះ មានការបើកចំហឲ្យមានការចូលរួមយ៉ាងទូលំទូលាយមួយពីប្រជាជន និងសង្គម ស៊ីវិល ដោយយកគំរូតាមរបៀបអាមេរិកកាំង គឺពង្រាងដំបូង បានបើកឲ្យមានការពិគ្រោះជាមួយសង្គមស៊ីវិល និង និស្សិតហើយនៅចុង ក្រោយបានដាក់ជូន ប្រជាជនធ្វើប្រជាមតិ ។ សូមមើលបន្ថែម លោកសាស្ត្រាចារ្យ ឃឹម អ៊ី នៅ កំណត់សម្គាល់ទី៥ ។


(៣) កំណត់ព្រំដែនលើសេរីភាពសេដ្ឋកិច្ច ។ សេរីភាពខាងសេដ្ឋកិច្ចនៅក្នុងសម័យនោះ ឈរលើគោលការណ៍ផលប្រយោជន៍សង្គម ។ មាត្រា១៤ ទទួលស្គាល់កម្មសិទ្ធិឯកជន ។ មាត្រា២-(៣) ធានាអះអាងឲ្យមានសមភាពចំពោះមុខច្បាប់ ។ ប៉ុន្តែមាត្រា១៦-(២) តម្រូវឲ្យរដ្ឋមានករណីកិច្ច សម្របសម្រួលសេដ្ឋកិច្ចជាតិសំដៅទៅរកប្រយោជន៍សង្គម និងរារាំងមិនឲ្យមានផ្តាច់មុខក្នុងពាណិជ្ជកម្ម ឬឧស្សាហកម្ម ។

(៤) ផ្តល់ឲ្យមានសិទ្ធិសង្គម ។ ពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលការងារ សិទ្ធិទទួលការអប់រំ សិទ្ធិទទួលការព្យាបាលរោង និងអត្ថប្រយោជន៍ខាងសង្គមកិច្ច (មាត្រា១៧ & ១៩) ។ ជនពិការដែលពុំអាចធ្វើការបាន ឬអ្នកក្រខ្សត់ដែលខ្វះមធ្យោបាយ មានសិទ្ធិទទួលប្រជាសង្គ្រោះ (មាត្រា១៩)។ ក្រៅពីសិទ្ធិសង្គម រដ្ឋធម្មនុញ្ញ ១៩៧២ បានតម្រូវឲ្យប្រជាពលរដ្ឋគ្រប់រូបមានករណីកិច្ច គោរពច្បាប់ ការពារមាតុភូមិ និងជួយរដ្ឋផងដែរ ។

(៥) រចនាសម្ព័ន្ធរដ្ឋាភិបាល យកលំនាំតាមសាធារណរដ្ឋទី៥ បារាំងនាឆ្នាំ១៩៥៨ ។ ប្រធានាធិបតីជ្រើសរើសតាមការបោះឆ្នោតដោយផ្ទាល់ពីប្រជារាស្ត្រ សម្រាប់អាណត្តិ៥ឆ្នាំ កាន់អំណាចនីតិបត្តិ (មាត្រា ២៣ & ២៤) ។ រដ្ឋមន្ត្រីទី១ និងសមាជិករដ្ឋាភិបាលជ្រើសរើស និងតែងតាំងដោយប្រធានាធិបតី ដែលក្នុងនោះរដ្ឋមន្ត្រីទី១ ដឹកនាំរដ្ឋាភិបាល និងទទួលខុសត្រូវចំពោះមុខប្រធានាធិបតី (មាត្រា៣៣,៣៤,៤៣)។ ផ្តល់ឲ្យមានការរៀបចំជាសហសភា ដោយសភាជាតិជ្រើសតាំងតាមការបោះឆ្នោតដោយផ្ទាល់ពីប្រជារាស្ត្រ សម្រាប់អាណាត្តិ៤ឆ្នាំ និងមានព្រឹទ្ធសភាជាអង្គការតំណាងភូមិភាគ សម្រាប់អាណាត្តិ ៦ឆ្នាំ និងសហសភានេះកាន់អំណាចនីតិបញ្ញត្តិ (មាត្រា៤៧, ៤៨, ៦៤) ។ សភាជាតិមានអំណាចទម្លាក់សមាជិករដ្ឋាភិបាល ឬ រដ្ឋាភិបាលទាំងមូលបាន តាមអនុសាសន៍សម្តែងការមិនពេញចិត្ត ប៉ុន្តែសិទ្ធិនោះអាចប្រឈមជាមួយសិទ្ធិជំទាស់របស់ប្រធានាធិបតី Right of Veto (មាត្រា ៧៥-៧៨) ក្នុងករណីដែលលោកមិនយល់ព្រម។

(6) ផ្តល់ឲ្យមានការបង្កើតតុលាការច្រើនប្រភេទ មានសមត្ថកិច្ចដោយឡែកៗពីគ្នា ដើម្បីធានានូវការពារសិទ្ធិ និងសេរីភាពពលរដ្ឋ ដែលយកគំរូតាមតុលាការប្រទេសបារាំង។ តុលាការ និងតុលាការកំពូលជំរះក្តីក្នុងវិាទ ផ្នែកស៊ីវិល និងព្រហ្មទណ្ឌ (មាត្រា៨០-៩២) ។ តុលាការធម្មនុញ្ញមើលធម្មនុញ្ញភាពនៃច្បាប់មុននឹងប្រកាសឲ្យប្រើ និងជំរះក្តីវិាទបោះឆ្នោតជាតិ (មាត្រា៩៣, ៩៦) ។ តុលាការជាន់ខ្ពស់ជំរះក្តីប្រធានាធិបតី អនុប្រធានាធិបតី សមាជិករដ្ឋាភិបាល សមាជិកតុលាការធម្មនុញ្ញ និងសមាជិកតុលាការកំពូល ពីបទឧក្រិដ្ឋ និងមជ្ឈឹមដែលបានប្រព្រឹត្តិក្នុងពេលបំពេញមុខងាររដ្ឋ (មាត្រា៩៧) ។ ដូច្នេះរចនាសម្ព័ន្ធសាធារណរដ្ឋ នៅក្រោមរដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ ក្នុងទ្រឹស្តីបានបញ្ជាក់ពីការបែងចែកអំណាច ។

រចនាសម្ព័ន្ធស្ថាប័នធម្មនុញ្ញសាធារណរដ្ឋខ្មែរ (១៩៧0-១៩៧៥)



២.៣. រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦ (កម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩)

ថ្ងៃ១៧ មេសា ១៩៧៥ កម្ពុជាបានចូលមកដល់បដិវត្តន៍មួយទៀត គឺការប្តូររបបគ្រប់គ្រងរដ្ឋពីរបបប្រជាធិបតេយ្យសេរីតាមទ្រឹស្តីបស្ចឹមប្រទេសមកយកតាមទម្រង់រដ្ឋកុម្មុយនីសនិយម។ រដ្ឋធម្មនុញ្ញថ្មីមួយទៀត មានឈ្មោះថា " រដ្ឋធម្មនុញ្ញប្រទេសកម្ពុជាប្រជាធិបតេយ្យ " ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ៥ មករា ១៩៧៦ ប្រកាសប្រទេសកម្ពុជា ជារដ្ឋរបស់ប្រជាជន កម្មករ និង កសិករ ហើយអនុវត្តរបបសមូហភាព ក្នុងការដឹកនាំ និងធ្វើការងារ (មាត្រា១ & ៤) ដែលនេះជាទម្រង់រដ្ឋកម្មុយនីស្តនៅក្នុងទ្រឹស្តីចិន/សូវៀត ។28


(១) លុបបំបាត់សិទ្ធិ និងសេរីភាពខាងសេដ្ឋកិច្ច (កម្មសិទ្ធិឯកជន និងការប្រកួតប្រជែងសេរី) ប៉ុន្តែដាក់ឲ្យមានតែកម្មសិទ្ធិរួមរបស់ប្រជាជនសមូហភាព (មាត្រា២) ។ ជានាអះអាងឲ្យមានជីភាពទាំងអស់គ្នា ឲ្យមានសមភាពស្មើភាព និងយុត្តិធម៌ (មាត្រា១២ & ១៣) ។ ហាមប្រាមសាសនាប្រតិកិរិយា (មាត្រា២) ។ តម្រូវឲ្យប្រជាជនមានករណីកិច្ចការពារប្រទេស និងកសាងប្រទេសទាំងអស់គ្នា (មាត្រា១៤) ។ កំណត់

28 ការរៀបចំធ្វើរដ្ឋធម្មនុញ្ញនេះ មិនបើកចំហរ និង ក៏មិនមានការសួរប្រជារាស្ត្រដែរ គឺរៀបចំ និងអនុម័តដោយ ក្រុមយោធា ។

នូវភាព គ្មានការងារធ្វើមិនមានជាប់ខាត (មាត្រា១២) ។ ទាំងនេះជាទ្រឹស្តីនៃរដ្ឋផ្តាច់ការវណ្ណៈអធន (Maxism, Leninism, and Maoist) ហើយទ្រឹស្តីនេះ មិនមែនជាសិទ្ធិ ឬសេរីភាពទេ ប៉ុន្តែជាកាតព្វកិច្ច ។ (២) រចនាសម្ព័ន្ធរដ្ឋាភិបាល ក្នុងទ្រឹស្តីបង្កើតឲ្យមានសភាតំណាងប្រជាជន (កសិករ កម្មករ និងយោធា) កាន់អំណាចធ្វើច្បាប់ (មាត្រា៥) ។ មានចែងពីអង្គការអនុវត្តច្បាប់ (រដ្ឋាភិបាល/អង្គការ) ដែលមានភារកិច្ច អនុវត្តច្បាប់ និងអនុវត្តមាគ៌ានយោបាយរបស់សភាតំណាងប្រជាជន ហើយអង្គការនេះបង្កើត ដោយសភាតំណាងប្រជាជន និងតម្រូវឲ្យទទួលខុសត្រូវទាំងស្រុងចំពោះមុខសភា (មាត្រា៨)។ មានចែងពីអង្គការតុលាការរបស់ប្រជាជន ដែលតម្រូវឲ្យជ្រើសរើស និងតែងតាំងដោយសភាតំណាងប្រជាជន (មាត្រា៩) ។

យើងឃើញថារបបខ្មែរក្រហម ប៉ុល ពត បានបង្កើតឲ្យមានរដ្ឋធម្មនុញ្ញដូចគេឯងចឹង ប៉ុន្តែភាពជាក់ស្តែង ពួកនេះអត់បានយកមកអនុវត្តទេ និងថែមទាំងបានដាក់ប្រទេសជាតិ និងប្រជាជនកម្ពុជា ឲ្យស្ថិតក្នុងស្ថានភាពមហាភយ័ន្តរាយ ដោយការបង្កើតឲ្យមាន មហាពិឃាត មហាអត់ឃ្លាន និងមហាផ្តាច់ការ ជារបបប្រល័យពូជសាសន៍។ បើកាលណារដ្ឋមួយមានការគ្រប់គ្រងកាន់តែផ្តាច់ការ កាន់តែធាប់រលំទៅវិញ។

រចនាសម្ព័ន្ធស្ថាប័នធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ




២.៤. រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ (សាធារណរដ្ឋប្រជាមានិតកម្ពុជា ១៩៧៩ - ១៩៨៩)

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហម ប៉ុលពត ត្រូវបានវាយរំលំដោយកងទ័ពរណសិរ្ស សាមគ្គីសង្គ្រោះជាតិកម្ពុជាក្រោមការជួយអន្តរាគមន៍ពីកងទ័ពប្រជាជនបដិវត្តវៀតណាម ប្រជាជនកម្ពុជាត្រូវបានរំដោះជាស្ថាពរ។ កម្ពុជាចូលមកដល់សករាជថ្មីមួយទៀត រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ ប្រកាសបង្កើតនូវរបបថ្មីជាសាធារណរដ្ឋប្រជាមានិតកម្ពុជាយកតាមលំនាំប្រទេសសង្គមនិយមសូវៀត/វៀតណាម។

រដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការនៅថ្ងៃទី២៥ មិថុនា ឆ្នាំ ១៩៨១ ដោយកំណត់យកលទ្ធិសង្គមនិយមជាជម្រើសនៃប្រព័ន្ធនយោបាយថ្មី។ ប្រជាជនកម្ពុជាជាម្ចាស់វាសនានៃប្រទេសរបស់ខ្លួន ជាម្ចាស់នៃអំណាចទាំងអស់ប៉ុន្តែការប្រើសិទ្ធិទាំងនោះតាមរយៈស្ថាប័នតំណាង (មាត្រា២) ។ កំណត់ឲ្យរដ្ឋាភិបាលត្រូវបំពេញការកិច្ច ការពារឯករាជ្យជាតិ ការពារសេរីភាពរបស់ប្រជាជន និងសមិទ្ធផលរបស់បដិវត្តទាំងអស់ ស្តារនិងពង្រីកផលិតកម្ម ពង្រឹងវប្បធម៌ យកចិត្តទុកដាក់ដោះស្រាយ និងលើកតម្កើងជីវភាពរស់នៅរបស់ប្រជាជនទាំងខាងសម្ភារៈ និងទាំងខាងស្មារតី (មាត្រា២) ។

រចនាសម្ព័ន្ធស្ថាប័នធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា



២.៥. រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ (រដ្ឋកម្ពុជា ១៩៨៩-១៩៩៣)

ក្នុងឆ្នាំ១៩៨៩, កម្ពុជាបានរៀបចំធ្វើកំណែទម្រង់រដ្ឋដ៏ធំមួយដើម្បីបញ្ចប់សង្គ្រាម និងបង្រួបបង្រួមជាតិ បើកចំហរប្រទេសទៅរកពិភពលោកសេរី។ ច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវបានអនុម័តនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៨៩ និងក្លាយជារដ្ឋធម្មនុញ្ញថ្មី (រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩) ប្រកាសដូរឈ្មោះប្រទេសមកជា រដ្ឋកម្ពុជា អនុវត្តរបបនយោបាយពហុបក្ស (មាត្រា៤) និងសេដ្ឋកិច្ចឯកជន/សេដ្ឋកិច្ចទីផ្សារ (មាត្រា១២)។ រដ្ឋទទួលស្គាល់និងគោរពសិទ្ធិមនុស្ស (មាត្រា៣០), សិទ្ធិកម្មសិទ្ធិឯកជនលើដីធ្លី (មាត្រា១៧,១៨), សិទ្ធិធ្វើការងារ/ជ្រើសរើសមុខរបរ (មាត្រា៣៣), សិទ្ធិទទួលបានការអប់រំ (មាត្រា២២), សិទ្ធិទទួលបានការថែទាំសុខភាព(មាត្រា២៦), និងរដ្ឋបង្កើតនូវរបបធានារ៉ាប់រងសង្គម (មាត្រា២៩), រដ្ឋយកចិត្តទុកដាក់ចំពោះកុមារនិងមាតា (មាត្រា២៧)។ល។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ មានចរឹកទ្រឹស្តីទំនើប ហើយបានក្លាយជាឯកសារគតិយុត្តិគោលសំខាន់ទៅក្នុងការរៀបចំរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន។

៣. អំណាត់សំគាល់ទូទៅ

ប្រទេសកម្ពុជាសម័យបូរាណ កាន់លទ្ធិរាជាធិបតេយ្យអាស្រ័យសាសនា (ព្រហ្មញ្ញ និងពុទ្ធិសាសនា)។ នៅសម័យទំនើប រៀបចំតាមទ្រឹស្តីរដ្ឋទំនើបបស្ចឹមប្រទេស និងទ្រឹស្តីរដ្ឋកុំមុយនីស្ត ម៉ាក្សលេនីនសូវៀត។ ប៉ុន្តែយើងបានពិនិត្យឃើញថា ទ្រឹស្តីរដ្ឋទំនើបបស្ចឹមប្រទេស ប្រសូត្រពីទស្សនសេរីភាព ប្រជាធិបតេយ្យ និងសិទ្ធិសង្គម ក្លាយជាស្មារតីយល់ដឹងទូលំទូលាយនៅក្នុងបដិវត្តស៊ីវិលរបស់កម្ពុជានាសម័យទំនើប។ ការដោះដូរទម្រង់រដ្ឋធម្មនុញ្ញញឹកញាប់ រវាងរាជានិយម និងសាធារណរដ្ឋ និងរវាងប្រជាធិបតេយ្យ និងសង្គមនិយម ធ្វើតាមរយៈបដិវត្តធម្មនុញ្ញ (រដ្ឋប្រហារ/សង្គ្រាម) កន្លងទៅជាទុក្ខសោកមួយជូរចត់សម្រាប់ប្រជាពលរដ្ឋខ្មែរ។

ជំពូក៥

ការរៀបចំបែងចែកអំណាចក្នុងទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប

១ .**អំពីការបែងចែកអំណាច** (Separation of Powers)

នៅក្នុងជំពូក២ យើងបានដឹងថាទស្សនៈរដ្ឋធម្មនុញ្ញទំនើបដែលឈរលើទ្រឹស្តី John Locke (សិទ្ធិមនុស្ស និង Social Contract) មានដើមកំណើតនាសម័យបដិវត្តអង់គ្លេស ជាពិសេសក្នុងឆ្នាំ១៦៨៨ ប៉ុន្តែទម្រង់រដ្ឋធម្មនុញ្ញទំនើប ដែលរៀបចំសរសេរចងក្រងជាក្រមរួមមួយ (a written Constitution) ទើបតែកើតមាននាសម័យបដិវត្តឯករាជ្យអាមេរិកកាំង ១៧៨៨ និងសម័យបដិវត្តបារាំងឆ្នាំ១៧៨៩ ។

រដ្ឋធម្មនុញ្ញអាមេរិកឆ្នាំ១៧៨៨ បង្កើតនូវទស្សនទានរដ្ឋទំនើប *(Conception of Government of Rule by "We the People of the United State ˝ with limits on Government to protect freedom)* និងដាក់កំណត់ការបែងចែកអំណាចជាក់លាក់ ។29 ស្របគ្នានៅក្នុងមាត្រា XVI de la Declaration des droits de l´homme et du citoyen, France ១៧៨៩ ក៏បានបង្កើតនូវស្មារតីនៃបទប្បញ្ញត្តិនេះផងដែរថា " *Toute societe dans laquelle la garantie des droits n´est pas assuree, ni la separation des pouvoirs determines, n´a point de constitution.* ˝ ។ល។

នៅក្នុងស្មារតីរួម គេឃើញមានការជានាទទួលស្គាល់ការគោរពសិទ្ធិសេរីភាព សិទ្ធិមនុស្ស បានងើបឡើងជាគោលការណ៍សាកលមួយនៅក្នុងលិទ្ធិធម្មនុញ្ញទំនើប ទោះបីនៅកាលនោះ ទស្សនៈអំពីសិទ្ធិសំដៅតែលើបុរសក៏ដោយចុះ ប៉ុន្តែគោលការណ៍នៃការបែងចែកអំណាច នៅមិនទាន់ទទួលស្គាល់ជាគោលការណ៍សាកលនៅឡើយ ។ ឧទាហរណ៍: នៅប្រទេសអង់គ្លេសដែលជាប្រទេសបង្កើតឲ្យមានទ្រឹស្តីរដ្ឋធម្មនុញ្ញភាពទំនើបមុនគេ (The Fatherland of Modern Constitution) ក្នុងផ្លូវច្បាប់ (*De Jure*) ពុំទាន់ទទួលយកនូវគោលការណ៍ទាំងស្រុងនោះនៅឡើយទេ ពីព្រោះនៅប្រទេសអង់គ្លេស គេនៅប្រកាន់គោលការណ៍គ្រឹៈសំខាន់ៗនៃ *អធិបតេយ្យរដ្ឋសភា* "Sovereignty of Parliament" ។ ដូច្នេះហើយគោលការណ៍នៃការរៀបចំ

---

29 Preamble of US Contitution " We the People of the United State, in order to form a more perfect Union, Establsih justice, insure domestic Tranquility, provide for the common defence, promote the general welfare, and secure the Blessings of Liberty to ourselves and our posterity, do ordain and establish this Constitution for the United State of America.˝ Article. I. Section 1. All legislative Powers herein granted shall be vested in a Congress of the United States which shall consist of a senate and House of Representatives. Article. II. Section 1. The executive power shall be vested in a President of the United State of America. … Article. III. Section 1. The Judicial power of the United States, shall be vested in one Supreme Court, and in such inferior court as the congress may from time to time ordain and establish. …

បែងចែកអំណាច ដែលកំណត់ឲ្យមាននៅក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងទំនើប បន្តវិវត្តចេញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនាសម័យបដិវត្តនៅក្នុងប្រទេសអាមេរិកកាំង និងប្រទេសបារាំង ។

១.១. ទ្រឹស្តីបែងចែកអំណាច (John Locke and Montesquieu)

ទស្សនទានដែលថា អំណាចនិងមុខងាររបស់រដ្ឋ គួរតែចែកឲ្យមានជាផ្នែកៗ ដើម្បីជៀសវាងនូវការគ្រប់គ្រងបំពានណាមួយ បានលើកឡើងតាំងពីសម័យអារីស្តូត ប៉ុន្តែគេបានមើលឃើញ Locke និង Montesquieu ជាអ្នកស្ថាបនិកក្នុងគំនិតរដ្ឋទំនើប ។ តាម John Locke អំណាចរដ្ឋ គួរបំបែកឲ្យមានជាពីរផ្នែកដោយមួយផ្នែកជាអំណាចធ្វើច្បាប់ (Legislative Power) ដែលកាន់កាប់ដោយសភាទាំងពីរ និងមួយផ្នែកទៀតជាអំណាចនីតិប្រតិបត្តិ (Executive Power) ដែលកាន់កាប់ដោយព្រះមហាក្សត្រ ។30 ទ្រឹស្តីរបស់គាត់ត្រូវបានវិនិយោគដើម្បីធ្វើយុត្តិកម្មលើការលេចឡើងនូវអំណាចរដ្ឋពីរត្រួតលើគ្នា រវាងព្រះមហាក្សត្រ និងរដ្ឋសភា ។ កាលនោះ John Locke មិនបានទទួលស្គាល់ឲ្យមានអំណាចតុលាការ ជាអំណាចបំបែកទី៣ទេ ពីព្រោះគាត់ចាត់ទុកតុលាការគ្រាន់តែជាផ្នែកមួយរបស់អំណាចនីតិប្រតិបត្តិតែប៉ុណ្ណោះ ប៉ុន្តែគាត់បានកំណត់ថាចៅក្រមកាត់ក្តីត្រូវមានស្មារតីឯករាជ្យ។ ប៉ុន្តែក្រោយមក Montesquieu បានរៀបចំធ្វើនិយាតកម្មបន្តែមទ្រឹស្តីរបស់ Locke ឲ្យកាន់តែមានភាពច្បាស់លាស់ និងសុក្រឹត ដោយបានពង្រីកនូវការបែងចែកអំណាចជាក់ឲ្យមានជាបីផ្នែកគឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ក្នុងអ្វីដែលគាត់បានអះអាងថា ការធ្វើបែបនេះអាចធានា ឲ្យមានរដ្ឋទំនើបមួយដែលមិនមានការបំពានអំណាចបំពានសិទ្ធិសេរីភាពរបស់ពលរដ្ឋ និងការពារកុំឲ្យអំណាចនៅរួមផ្តុំតែមួយដែលធ្វើឲ្យមានភាពផ្តាច់ការ។31

កាលនោះ Montesquieu ពុំមានជំនឿលើចរិកធម្មជាតិរបស់មនុស្សទេ ពីព្រោះគាត់មើលឃើញថាមនុស្សជាទូទៅតែងមាននិន្នាការទៅរកអំពើអាក្រក់ គឺលោភលន់ និងឈ្នានីស ក្នុងការស្វះស្វែងរកនូវអំណាចផ្ទាល់ខ្លួន ក៏ប៉ុន្តែគាត់បានអះអាងថានិន្នាការអាក្រក់ទាំងនោះកាត់បន្ថយមកវិញបាន បើអំណាចរដ្ឋទាំងអស់មិនផ្តុំតែលើបុគ្គលម្នាក់ ឬទៅលើតែស្ថាប័នណាមួយនោះទេ ។

---

30 សម្រាប់ John Locke នៅកាលនោះ អំណាចនីតិប្រតិបត្តិរបស់ព្រះមហាក្សត្រមួមានអំណាចសហព័ន្ធ ឬ អំណាច ការទូត (Federative or Diplomatic Power) ។ អំណាចការទូត របស់ព្រះមហាក្សត្រ គឺរួមមានអំណាចប្រកាស សង្គ្រាម អំណាចធ្វើសន្តិភាព និងអំណាច ធ្វើសន្ធិសញ្ញាអន្តរជាតិនានាជាដើម ។

31 មើល Montesquieu "De l'Esprit des Loix" 1748 (In English "The Spirit of Laws") ។ គាត់បានមើលឃើញថា "When the legislative and executive powers are united in the same person, or in the same body of magistrates, there can be no liberty... Again, there is no liberty if the judiciary power be not separated from the legislative and executive".

១.២. រដ្ឋសភាសម័យបដិវត្តស៊ីវិល និងរដ្ឋសភាក្នុងប្រទេសសង្គមនិយម

Locke និង Montesquieu បានផ្តោតលើការបែងចែកអំណាច (Separation of Powers) ដើម្បីបង្ការ និងទប់ស្កាត់ការបំពាន ប៉ុន្តែជាក់ស្តែងទ្រឹស្តីបដិវត្តន៍ក្នុងសម័យបដិវត្តស៊ីវិល (Civil Revolution) មិនទទួលយកទ្រឹស្តីបែងចែកអំណាចទេ តែជំនួសមកដោយការធ្វើសមាហរណកម្មអំណាច (Integration of Powers) ទៅវិញទេ ។ រាល់ពេលធ្វើបដិវត្តស៊ីវិល អំណាចរដ្ឋទាំងអស់បានរួមក្តាបនៅក្នុងរដ្ឋសភាតំណាងប្រជាពលរដ្ឋ និងបានធ្វើឲ្យអំណាចស្របច្បាប់ឡើងវិញដោយរដ្ឋសភាតំណាងទាំងនោះ។ ជាក់ស្តែងនៅប្រទេសអង់គ្លេសគេបង្កើតនូវ *Convention Parliament,* នៅប្រទេសបារាំងបង្កើតនូវ *La Convention Nationale* និងនៅអាមេរិកកាំងបង្កើតឲ្យមាននូវ *The Constitutional Convention* ។

ដូច្នេះ *រដ្ឋសភាមជ្ឈការនិយម* "Parliamentary Centralism" ជាទ្រឹស្តីបដិវត្តស៊ីវិល ។ នៅប្រទេសអង់គ្លេស គោលការណ៍សំខាន់ក្នុងការរៀបចំអំណាចរដ្ឋនាសម័យបដិវត្តស៊ីវិលរបស់គេ ទោះជាមកដល់សព្វថ្ងៃនេះក៏ដោយចុះ ពុំមែនការបែងចែកអំណាចទេ ប៉ុន្តែជាការបង្កើតឲ្យមាននូវ *រដ្ឋសភាធិបតេយ្យ* ឬ *អធិបតេយ្យភាពនៃរដ្ឋសភាតំណាង* "Sovereignty of Parliament" ។ ទស្សនៈនេះនៅស្រុកខ្លះគេហៅថាជាទស្សនៈ *រដ្ឋសភានិយម* ឬ *រដ្ឋសភាមជ្ឈការនិយម* ។ ក្រោយមកគំរូបដិវត្តសហគមន៍ដែលបានធ្វើនៅប្រទេសបារាំងឆ្នាំ ១៨៧១ ដែលជាបដិវត្តលើកទី១ ដឹកនាំដោយកម្មករ បានចំឡងយកទ្រឹស្តីនេះមកប្រើ ។ លោក Karl Marx ក្នុងសៀវភៅល្បីល្បាញរបស់គាត់ "The Civil War of France" គាត់បានកត់សំគាល់ថា "*the Commune was to be not a parliamentary but a working body to execute and legislate at the same time*" ។ ពាក្យថា Commune (ឃុំ/សង្កាត់) ដែលជាអជ្ញាធរឃុំ (a local government) ។ កាលនោះនៅតាមឃុំជាច្រើន ដូចជានៅក្រុង Paris, ក្រុង Bordeaux, ក្រុង Marseille, អាជ្ញាធរមួយរបស់កម្មករ ត្រូវបានគេរៀបចំឲ្យមានឡើង ដើម្បីធ្វើការប្រឈមជាមួយ រដ្ឋាភិបាលកណ្តាល ក្នុងទីក្រុងប៉ារីស ។ គំនិតដែលបានលើកដោយលោក Karl Marx នេះត្រូវបានយកមកពង្រីកឲ្យមានភាពជាក់ស្តែងនិយមនៅក្នុងទ្រឹស្តីប្រទេសសង្គមនិយម ឈរលើគោលការណ៍អធិបតេយ្យសភាតំណាងប្រជាជន។ សរុបមកវិញ គោលការណ៍រដ្ឋសភាមជ្ឈការនិយមតាមបែបអង់គ្លេស ឬគោលការណ៍អាជ្ញាធររដ្ឋបាលឃុំ/សង្កាត់ ដែលបានដឹកនាំដោយកម្មករ រៀបចំឡើងដោយលោក Karl Marx ឬទ្រឹស្តីប្រព័ន្ធរដ្ឋសង្គមនិយម ពុំបានទទួលយកនូវគោលការណ៍នៃការបែងចែកអំណាចទេ ប៉ុន្តែជាការធ្វើសមាហរណកម្មផ្តុំអំណាចមកដាក់នៅក្រោមសភាតំណាងប្រជាជន និងក្លាយជាគោលការណ៍សំខាន់មួយក្នុងការរៀបចំអំណាចនាយុគ្គសម័យទំនើប ។

១.៣. ការបែងចែកអំណាចនៅអាមេរិកកាំង (Separation of Powers in USA)

អាមេរិកកាំងបានទទួលឯករាជ្យពីអង់គ្លេសឆ្នាំ១៧៧៦ និងបង្កើតឲ្យមានរដ្ឋធម្មនុញ្ញក្នុងឆ្នាំ១៧៨៨។ ច្បាប់ទាំងអស់របស់អាមេរិកឈរលើគោលការណ៍ Common Law ដូចគ្នានឹងច្បាប់អង់គ្លេស ប៉ុន្តែអាមេរិកកាំង ទទួលយកឲ្យមាននូវគោលការណ៍បែងចែកអំណាចច្បាស់លាស់តាមទ្រឹស្តី Montesquieu នៅក្នុងការរៀបចំអំណាចក្នុងរដ្ឋសហព័ន្ធ ដែលនេះ មានភាពផ្ទុយគ្នាពីប្រទេសអង់គ្លេស។ នៅក្នុងប្រព័ន្ធអាមេរិកកាំង អំណាចនីតិបញ្ញត្តិកាន់កាប់ដោយ Congress, អំណាចនីតិប្រតិបត្តិកាន់កាប់ដោយប្រធានាធិបតី និងអំណាចតុលាការកាន់កាប់ដោយតុលាការកំពូល ហើយនិងអំណាចតុលាការជាអំណាចឯករាជ្យ។ ទោះជាមកដល់សព្វថ្ងៃនេះក៏ដោយ ពាក្យនេះមិនត្រូវប្រើនៅប្រទេសអង់គ្លេសទេ ពីព្រោះនៅប្រទេសនេះ The House of Lords មកដល់បច្ចុប្បន្ននៅបំពេញតួនាទីជាសភាជាតិផង និងជាតុលាការកំពូលផង ។

១.៤. ទម្រង់បែងចែកអំណាចក្នុងរដ្ឋធម្មនុញ្ញទំនើប

មកដល់បច្ចុប្បន្ននេះ ការរៀបចំអំណាចក្នុងប្រព័ន្ធរដ្ឋទំនើប គេសង្កេតឃើញមានទម្រង់៣ផ្សេងគ្នា ។ ទម្រង់ទី១ ជាការបង្រួមផ្តុំអំណាច (Integration of Powers) នៅក្រោមរដ្ឋសភាតំណាងដែលអង់គ្លេសហៅថា "Assembly Government" បារាំងហៅថា "Gouvernement d'Assemble" អាឡឺម៉ង់ហៅថា "Versammlungsregierung" និង ខ្មែរទម្លាប់កន្លងមកហៅថា *<u>រដ្ឋាភិបាលសភានិយម</u>* ដែលមកដល់សព្វថ្ងៃឃើញមានអនុវត្តនៅក្នុងប្រទេស Switzerland និងនៅក្នុងរដ្ឋសង្គមនិយមមួយចំនួន ចិន/វៀតណាម។

ទម្រង់ទី២ ការបែងចែកអំណាច (Separation of Powers) តាមទ្រឹស្តី Montesquieu, ដែលអង់គ្លេសហៅថា "Presidential Government" បារាំងហៅថា "Gouvernement Presidential" អាឡឺម៉ង់ហៅថា "Prasidialregierung" និងខ្មែរទម្លាប់ហៅថា *<u>រដ្ឋាភិបាលប្រធានាធិបតីនិយម</u>* ដែលមកសព្វថ្ងៃនេះឃើញមានអនុវត្តនៅប្រទេសអាមេរិកកាំង បារាំង និង ប្រទេសនៅទ្វីប Africa មួយចំនួន ។ ទម្រង់ទី៣ ជាមជ្ឈន្តិក:រវាងទម្រង់ទី១ និងទម្រង់ទី២ ។ ជាទម្រង់កណ្តាលរវាងប៉ូលទាំងពីរនេះ ដែលប្រទេសភាគច្រើនរៀបចំរដ្ឋតាមទម្រង់នេះ។ នៅក្នុងទម្រង់ទី៣ អំណាចរដ្ឋាភិបាលអាស្រ័យរដ្ឋសភាក៏ពិតមែន ប៉ុន្តែវាមានឯករាជ្យភាពពីរដ្ឋសភា ទោះបីជារដ្ឋសភាជាតំណាងប្រជាជនជ្រើសតាំងតាមការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ និងមានអធិបតេយ្យភាពពីគ្នាក៏ដោយចុះ។ ទម្រង់ទី៣នេះ នៅអង់គ្លេសហៅថា "Parliamentary Government (or Cabinet)" បារាំងហៅថា "Gouvernement (ou Cabinet) Parlementaire" និងអាឡឺម៉ង់ហៅថា "Parlamentarische Regierung (od. Kabinet)" និងខ្មែរទម្លាប់ហៅថា *<u>រដ្ឋាភិបាលអាស្រ័យតាមរដ្ឋសភា</u>* ដែលឃើញមានការប្រតិបត្តិនៅក្នុងប្រទេសអង់គ្លេស ជប៉ុន ថៃ និងកម្ពុជាជាដើម ។

១.៥. ទម្រង់រៀបចំបែងចែកអំណាចក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ហាក់បីដាប្រកាសទទួលយកនូវគោលការណ៍បែងចែកអំណាចតាមលំនាំទ្រឹស្តី Montesquieu ប៉ុន្តែជាក់ស្តែងបានប្រតិបត្តិតាមទម្រង់ទី៣ -រដ្ឋាភិបាលអាស្រ័យរដ្ឋសភា ។ ឧទាហរណ៍៖

ទី១ មាត្រា៥១ (៤) កំណត់ពីការបែងចែកអំណាច។ មាត្រា៥១(៤) : អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

ទី២ មាត្រា៩០ (ថ្មីពីរ) និង ៩៩ (ថ្មី) កំណត់ថា រដ្ឋសភា និងព្រឹទ្ធសភាកាន់អំណាចនីតិបញ្ញត្តិ ។ មាត្រា៩០ ថ្មីពីរ មានត្រា៩៩ថ្មី កំណត់ថា រដ្ឋសភា និងព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ។

ទី៣ មាត្រា១១៨ ចែងថារាជរដ្ឋាភិបាលកាន់អំណាចនីតិប្រតិបត្តិ។ មាត្រា១១៨ : គណៈមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ... និងមាត្រា១នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, កំណត់ថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាជាអង្គការនីតិប្រតិបត្តិ ...។

ទី៤ មាត្រា១២៨ អំណាចតុលាការ ជាអំណាចឯករាជ្យ និងកាន់ដោយតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ជំនាន់ថ្នាក់។ មាត្រា១២៨ អំណាចតុលាការជាអំណាចឯករាជ្យ ។ អំណាចតុលាការធានារក្សាអនាគត និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ។ អំណាចតុលាការគ្របដណ្តប់ ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ត្រូវប្រគល់ឲ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

ទាំងអស់នេះ ច្បាស់ណាស់ជាទ្រឹស្តី Montesquieu ។ ប៉ុន្តែម៉្យាងវិញទៀតរដ្ឋធម្មនុញ្ញកម្ពុជា កំណត់ការ រៀបចំរាជរដ្ឋាភិបាល (អំណាចនីតិប្រតិបត្តិតាមរដ្ឋសភា) ។ រដ្ឋសភាដែលជ្រើសតាំងឡើងមកតាមការបោះឆ្នោតសាកលនិងដោយផ្ទាល់ពីប្រជាពលរដ្ឋ បង្កើតរាជរដ្ឋាភិបាលកាន់អំណាចនីតិប្រតិបត្តិ ហើយរាជរដ្ឋាភិបាលទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល (មាត្រា ១១៩ ១២១ថ្មី និង រដ្ឋធម្មនុញ្ញបន្ថែមឆ្នាំ២០០៤) ។ មួយវិញទៀតមាត្រា៧៧ ផ្តល់ឲ្យតំណាងរាស្ត្រក្នុងរដ្ឋសភាជាតំណាងឲ្យប្រជាជនខ្មែរទាំងមូល។ ដូច្នេះហើយក្នុងនាមតំណាងឲ្យប្រជាពលរដ្ឋខ្មែរទាំងមូល រដ្ឋសភាមានអំណាចច្រើនបន្ថែមទៀត ក្រៅពីអំណាចនីតិបញ្ញត្តិរបស់ខ្លួនក្នុងនោះមានដូចជា:

> ១- រដ្ឋសភាអនុម័តថវិការជាតិ ផែនការរដ្ឋ ការឲ្យរដ្ឋខ្ចីប្រាក់ពីគេ ការឲ្យរដ្ឋឲ្យប្រាក់គេខ្ចី ការសន្យានានា ផ្នែកហិរញ្ញវត្ថុ និងការបង្កើតកែប្រែ ឬលុបចោលពន្ធដារ (មាត្រា ៩០-២)។

២- រដ្ឋសភាឲ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល (មាត្រា ៩០-៣) ។
៣- រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ (មាត្រា ៩០-៤) ។
៤- រដ្ឋសភាអនុម័តយល់ព្រមឬលុបចោលសន្ធិសញ្ញាឬអនុម័តអន្តរជាតិ(មាត្រា៩០-៥)។
៥- រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម (មាត្រា ៩០-៦) ។
៦- រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល (មាត្រា ៩០-៨) ។
៧- រដ្ឋសភាអនុម័តវិសោធនកម្មរដ្ឋធម្មនុញ្ញ ឬរដ្ឋធម្មនុញ្ញបន្ថែមតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល(មាត្រា១៥១ និងមាត្រា ២ នៃធម្មនុញ្ញបន្ថែម)។
៨- រដ្ឋសភាអាចទម្លាក់សមាជិករដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាល ពីដំណែងដោយអនុម័តញ្ញាត្តិបន្ទោសតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល (មាត្រា៩៨)។
៩- ដំណាងរាស្ត្រមានសិទ្ធិដាក់សំណួរ ឬបើកការស៊ើបអង្កេតដល់សមាជិករដ្ឋាភិបាល (មាត្រា ៩៦-៩៧) ។

២. អំណាចនីតិបញ្ញត្តិ (រដ្ឋសភា និងព្រឹទ្ធសភា)

មាត្រា៧-១ ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។ មាត្រា ៥១-២,៣ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន និងអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ មាត្រា ៧៦-២ តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកលដោយសេរី ដោយស្មើភាព ដោយចំពោះ ។ មាត្រា៧៧-១ ដំណាងរាស្ត្រក្នុងរដ្ឋសភាជាដំណាងប្រជាជាតិខ្មែរទាំងមូល។ មាត្រា៧៨-១ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ លើកលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល១២ខែ។ ក្នុងន័យនេះរដ្ឋសភាឈរហាន:ជាស្ថាប័នដំណាងជាតិសំខាន់បំផុត ពីព្រោះឆ្លុះបញ្ចាំងចេញដោយផ្ទាល់ពីឆន្ទៈរបស់ប្រជាពលរដ្ឋជាអធិបតេយ្យ (Popular Sovereignty) ។

ប៉ុន្តែពុំមានន័យថា រដ្ឋសភាមានអំណាចអធិបតេយ្យនោះទេ ពីព្រោះម៉្យាងរដ្ឋធម្មនុញ្ញកម្ពុជា ត្រូវបានបញ្ញត្តិទុកជាច្បាប់កំពូល *[មាត្រា ១៥០ : រដ្ឋធម្មនុញ្ញនេះ ជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត]* និងម៉្យាងទៀត រដ្ឋធម្មនុញ្ញកំហិតព្រំដែនអំណាចនីតិបញ្ញត្តិជាក់លាក់ទៀតផង *[មាត្រា ៩២ : ការអនុម័តទាំងឡាយរបស់រដ្ឋសភាដែលផ្ទុយនឹងគោលការណ៍រក្សាការពារ ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឲ្យប៉ះពាល់ដល់ឯករាជ្យភាពនយោបាយឬ ការគ្រប់គ្រងរដ្ឋបាលប្រទេសជាតិ នឹងត្រូវចាត់ទុកជាអាសាសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ ដែលមានសមត្ថកិច្ច សម្រេចពីមោយ*

ភាពនេះ ។ មាត្រា ១៥៣ : ការ សើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញ មិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ] ។

២.១. ប្រព័ន្ធសហសភា (ប្រពន្ធ័ទ្វេសភា)

ប្រព័ន្ធសភាកម្ពុជាជាប្រព័ន្ធសហសភា ដែលរួមមានរដ្ឋសភា និងព្រឹទ្ធសភា ។ បើយើងឈរលើគោលការណ៍ប្រជាធិបតេយ្យ រដ្ឋសភាត្រូវជាសភាលំដាប់ទី១ ហើយព្រឹទ្ធសភាជាសភាលំដាប់ទី២ ពីព្រោះតំណាងរាស្ត្ររដ្ឋសភា ត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតជាសកលដោយផ្ទាល់ពីប្រជាពលរដ្ឋ និងរដ្ឋសភាមានអាណត្តិខ្លីជាងអាណត្តិរបស់ព្រឹទ្ធសភា (៤/៥) ។ នេះបញ្ជាក់ថា រដ្ឋសភានៅកៀកកិតនឹងប្រជាពលរដ្ឋ ដែលលោកជាម្ចាស់អំណាចជាងព្រឹទ្ធសភា។ រដ្ឋធម្មនុញ្ញកម្ពុជាដែលបានផ្តល់អំណាច និងមុខងារជាច្រើនទៅឲ្យរដ្ឋសភាជាងព្រឹទ្ធសភា គឺជាការត្រឹមត្រូវ ដោយគោរពតាមគោលការណ៍ប្រជាធិបតេយ្យ ។

២.២. ហេតុផលបង្កើតព្រឹទ្ធសភា

ហេតុផលសំខាន់ៗ ក្នុងការរៀបចំឲ្យមានសហសភានៅប្រទេសខ្លះ ឈរលើមូលដ្ឋាននៃប្រព័ន្ធវណ្ណៈសង្គម ឧទាហរណ៍ ដូចជានៅប្រទេសអង់គ្លេសបច្ចុប្បន្ននេះ ឬ នៅប្រទេសជប៉ុនមុនសង្គ្រាមលោកលើកទី ២។ នៅប្រទេសខ្លះទៀត ឈរលើមូលដ្ឋានហេតុផលប្រព័ន្ធរដ្ឋ ជាប្រព័ន្ធរដ្ឋសហព័ន្ធ (Federal System) ដូចនៅប្រទេសអាមេរិកកាំង ឬនៅប្រទេសអាឡឺម៉ង់ជាដើម ។ នៅប្រទេសខ្លះទៀត គេឈរលើមូលដ្ឋានប្រព័ន្ធស្វ័យភាពតំបន់ (Local Autonomy System) ដូចជានៅប្រទេសបារាំង និងអ៊ីតាលីជាដើម។ តើនៅប្រទេសកម្ពុជាយើង ឈរលើមូលដ្ឋានអ្វីខ្លះ ដែលតម្រូវឲ្យរៀបចំនូវប្រព័ន្ធសហសភានេះឡើង ?

បើពិនិត្យលើហេតុផលដំបូងនៃរៀបចំឲ្យមានរដ្ឋសភាតែមួយនោះ (១៩៩៣ - ១៩៩៩) ដែលកាលនោះកម្ពុជាបានឈរលើមូលដ្ឋានសំខាន់បី ទី១ យើងត្រូវការនូវប្រសិទ្ធភាពក្នុងការដំណើរការរៀបចំធ្វើច្បាប់ , ទី២ យើងខ្វះធនធានមនុស្ស (ធនធានអ្នកនយោបាយ), និង ទី៣ យើងខ្វះធនធានថវិការទ្រទ្រង់ ។ ប៉ុន្តែក្រោយមកនៅឆ្នាំ១៩៩៩ កម្ពុជាបានសើរើកែប្រែរៀបចំប្រព័ន្ធទ្វេសភាវិញដោយឈរលើហេតុផលមូលដ្ឋានសំខាន់ពីរ, ទី១ ដើម្បីស្មារតីសម្រុះសម្រួលនយោបាយជាតិ និងទី២ ស្មារតីពង្រីកប្រជាធិបតេយ្យ ។ ឧទាហរណ៍ជាក់ស្តែង តំណាងរាស្ត្ររដ្ឋសភា បានលើកហេតុផលនៅក្នុងការប្រជុំរដ្ឋសភាពេញអង្គៈ

<u>ឯកឧត្តម ចែមស្ងួន (ក្នុងសម័យប្រជុំពេញអង្គលើកទី២នៃសភាធម្មនុញ្ញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ១៩៩៣)</u>
... សុំបញ្ជាក់ជម្រាបជូនដៃរអំណាចនីតិបញ្ញត្តិ យើងចែងថារដ្ឋសភាយើងមានតែមួយថ្នាក់ទេ រដ្ឋសភាយើងគ្មានពីរជាន់ទេ ហេតុយ៉ាងដូចម្តេចបានជាគណៈកម្មការចែងយ៉ាងនេះ ពីព្រោះថាបើយើងចែងពីរជាន់

ជាន់រដ្ឋសភាខាងលើត្រូវដាជាន់ដែលគិតពិចារណា មានកំរិតយល់ដឹងខ្ពស់លើគ្រប់វិស័យ ហើយដែលជាជាន់សម្រេចជាចុងក្រោយ បើកាលណាមានពីរជាន់យ៉ាងនេះ អ្វីៗត្រូវសម្រេចជាពីរជាន់ដែរ សេចក្តីស្នើរបស់រដ្ឋាភិបាល ផែនការរបស់រដ្ឋាភិបាលអ្វីៗទាំងអស់ ច្បាប់ដែលចូលទៅក្នុងរដ្ឋសភាទាំងប៉ុន្មានចូលទៅជាន់ទីក្រោមសម្រេចរួចហើយដាក់ទៅជាន់ទីលើ បើជាន់ទីលើមិនព្រមទេរុញមកក្រោមវិញទីក្រោមពិនិត្យឡើងវិញហើយដូនទៅទីលើទៀត ទើបខាងលើសម្រេចឯកភាពជាចុងក្រោយ បើយើងពិនិត្យទៅរបៀបរបបដែលធ្វើការងារនេះឃើញថា ទាមទារពេលយូរណាស់ ទីមួយយើងមិនឲ្យមានពីជាន់ដោយសារថា អ្នកដែលនៅជាន់លើនេះ ទាមទារអ្នកដែលមានចំណេះដឹងខ្ពស់ អ្នកដែលមានវ័យចាស់មានបទពិសោធន៍ច្រើនយើងពិបាកនឹងរក ពីព្រោះបញ្ហាវន្តយើងតិចតួចស្តួចស្តើង បើអ៊ីចឹងយើងមិនអាចចែកគ្នាយកអ្នកចេះដឹងច្រើនហ្នឹងរុញទៅឲ្យនៅសភាជាន់លើហើយជាន់ក្រោមយើងហ្នឹងខ្វះគ្នានោះទេ អ៊ីចឹងយើងមិនអាចធ្វើពីរជាន់បានទេ។ ទី២ បើយើងកសាងប្រទេសយើងដោយផ្អែកលើជំនួយបរទេសទាំងអស់ យើងអត់មានលទ្ធភាពពីព្រោះខ្លួនយើងនេះអត់មានទុនដើម្បីនឹងកសាងប្រទេសជាតិយើងខ្លួនឯងទេ បើយើងពឹងផ្អែកទៅលើជំនួយបរទេសយ៉ាងនេះ ។ យើងត្រូវការអ្វីៗ ដែលរដ្ឋាភិបាលស្នើមក ដើម្បីនឹងកសាងប្រទេសហើយត្រូវឆ្លងកាត់រដ្ឋសភានេះ ត្រូវឲ្យឆ្លងកាត់បានឆាប់ជាទីបំផុតដើម្បីទទួលជំនួយបានមកកសាងប្រទេសជាតិបានឆាប់រហ័សដែរ បើយើងមានសភាពីរជាន់អ្វីដែលរដ្ឋាភិបាលស្នើមកហើយ ត្រូវតែឆ្លងកាត់ពីជាន់មួយទៅជាន់មួយអាចនឹងត្រឡប់មកជាន់ក្រោម ហើយបានវិលទៅជាន់លើវិញ យូរណាស់យើងមិនអាចសម្រេច យកជំនួយនេះបានដូចអំពីបំណងរបស់យើង ហើយយកមកកសាងប្រទេសជាតិយើងបានទាន់ពេលវេលាទេ ហេតុនេះរដ្ឋាភិបាលយើងមានតែមួយជាន់ទេ...។

<u>ឯកឧត្តម ស ខេង (ក្នុងសម័យប្រជុំវិសមញ្ញនៃសភានីតិកាលទី២ ថ្ងៃទី ០២ ខែមិនា ឆ្នាំ ១៩៩៩)</u>

... ការណ៍ដែលនាំឲ្យមានការសម្រេចចិត្ត ដើម្បីនឹងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ គឺក្នុងគោលបំណងបញ្ចៀសនូវភាពស្មុគស្មាញសម្រាប់ប្រទេសជាតិយើង ជាពិសេសក្រោយពីវិបត្តិនយោបាយ ដែលមានជាយូរណាស់មកហើយ និងជាពិសេសចុងក្រោយនេះ ហើយដោយមានការប្រជុំកំពូលពី ថ្ងៃទី១២-១៣ ខែវិច្ឆិការ ឆ្នាំ១៩៩៨ ទើបយើងអាចទម្លុះទម្លាយបាននូវភាពទ័លច្រក ឬក៏វិបត្តិនយោបាយសម្រាប់ប្រទេសជាតិយើងហើយ លទ្ធផលដែលយើងទទួលបានដូចសព្វថ្ងៃនេះ គឺយើងអាចនឹងសន្និដ្ឋានបានច្បាស់ថា ដោយសារមានការស្រុះស្រួល ដោយសារមានដំណោះស្រាយនៅក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះករុណា ជាអង្គម្ចាស់ជីវិតតំកល់លើត្បូង ដូច្នេះជាការចាំបាច់ហើយក្នុងការបង្កើតនូវព្រឹទ្ធសភានេះ ... ហើយការបង្កើតព្រឹទ្ធសភានេះ គឺជាការពង្រឹងនិងពង្រីកអំណាចនីតិបញ្ញត្តិ...។

<u>ឯកឧត្តម ហោ ណាំហុង (ក្នុងសម័យប្រជុំវិសាមញ្ញនៃសភានីតិកាលទី២ ថ្ងៃទី ០២ ខែមិនា ឆ្នាំ១៩៩៩</u>

... តើការបង្កើតព្រឹទ្ធសភានេះវាចាំបាច់ដែរឬទេ ក្នុងស្មារតីពង្រឹងនៃលទ្ធិប្រជាធិបតេយ្យនៅប្រទេសយើង? ការបង្កើតព្រឹទ្ធសភានេះពិតហើយមានការចំណាយលើថវិការតិចតួច ប៉ុន្តែខ្ញុំយល់ឃើញថា បើចំណាយថវិការប៉ុណ្ណោះ ហើយបើយើងពង្រីកលទ្ធិប្រជាធិបតេយ្យ យើងកែលំអនូវកិច្ចការបំរើការនីតិបញ្ញត្តិរបស់យើង ខ្ញុំយល់ថាគួរដែរ ... ។

២.៣. ទំនាក់ទំនងរវាងរដ្ឋសភា និងព្រឹទ្ធសភា

បើយោងតាមរដ្ឋធម្មនុញ្ញ អំណាចនីតិបញ្ញត្តិកាន់កាប់ដោយរដ្ឋសភា និងព្រឹទ្ធសភា។ សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ អាចស្នើឡើងក្នុងនាមសមាជិករដ្ឋសភា ព្រឹទ្ធសភា ឬនាយរដ្ឋមន្ត្រី (មាត្រាទី ៩១) និងត្រូវដាក់ជូនរដ្ឋសភាដើម្បីពិភាក្សានិងអនុម័ត ហើយនិងត្រូវដាក់បន្តជូនព្រឹទ្ធសភាពិនិត្យចប់សព្វគ្រប់មុនដាក់ជូនព្រះមហាក្សត្រប្រកាសឲ្យប្រើ។ ក្នុងដំណើរការធ្វើច្បាប់ ព្រឹទ្ធសភា ក្នុងទ្រឹស្តីនិងការអនុវត្តជាក់ស្តែងមានអំណាចតិចជាងរដ្ឋសភា។ នេះទីមួយ ព្រឹទ្ធសភាតាមផ្លូវច្បាប់ ពុំមានសិទ្ធិបើកការពិភាក្សាពេញអង្គលើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ណាមួយ មុនការអនុម័តរបស់រដ្ឋសភាបានទេ (The Priciple of One Way)។ ទីពីរ អំណាចដំទាស់ (The Powers of Veto) របស់ព្រឹទ្ធសភា ពុំមានទំងន់នយោបាយអ្វីទៅលើអំណាចរបស់រដ្ឋសភាឡើយ។ ម្យ៉ាងទៀតព្រឹទ្ធសភា មានការកិច្ចជាអ្នកសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល និងពុំមានអំណាចត្រួតពិនិត្យ ឬតាមដានកិច្ចការប្រចាំថ្ងៃរបស់រាជរដ្ឋាភិបាលទេ។

២.៤. មុខងាររដ្ឋសភា

រដ្ឋសភា ជាស្ថាប័នតំណាងឲ្យប្រជាជាតិខ្មែរទាំងមូល (មាត្រា៧៧) ។ ក្នុងន័យនេះ រដ្ឋធម្មនុញ្ញផ្តល់អំណាចនិងមុខងារឲ្យរដ្ឋសភាមានអំណាចនីតិបញ្ញត្តិ (អំណាចអនុម័ត) ។


ទីមួយ ដើមនីតិកាលនីមួយៗ រដ្ឋសភាត្រូវបំពេញមុខងារបង្កើតរាជរដ្ឋាភិបាល, តាមការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាល (មាត្រា ១១៩ &៩៩ ឬ ធម្មនុញ្ញបន្ថែម ២០០៤) ។

ទីពីរ រដ្ឋសភាមានមុខងារ ស្នើច្បាប់និងអនុម័តច្បាប់ (មាត្រា ៩០, ៩៩) ។ ការធ្វើច្បាប់ណាក៏ដោយត្រូវស្របនឹងឆន្ទៈរបស់ប្រជាពលរដ្ឋ ពីព្រោះប្រជាពលរដ្ឋជាម្ចាស់ និងរដ្ឋសភាជាតំណាងរាស្ត្រ,


ទីបី រដ្ឋសភាមានមុខងារ ឃ្លាំមើល និងត្រួតពិនិត្យ (watchdog and control) លើសកម្មភាពរបស់រាជរដ្ឋាភិបាល (មាត្រា ៨៩, ៩០, ៩៦, ៩៧) ដោយឈរលើឧត្តមប្រយោជន៍ជាតិ និងប្រជាពលរដ្ឋ។

ទីបួន រដ្ឋសភាបំពេញមុខងារជាតំណាង តំណាងជាតិទាំងមូល តំណាងមណ្ឌលបោះឆ្នោត និងតំណាងគណបក្សជាប់ឆ្នោត។ ក្នុងន័យនេះ តំណាងរាស្ត្ររដ្ឋសភា ត្រូវស្តាប់ គោរព និងបំរើ ប្រជាពលរដ្ឋ ។

តារាងទំនាក់ទំនងមុខងាររដ្ឋសភា និងរាជរដ្ឋាភិបាល



តារាងទំនាក់ទំនងការងារ និងមុខងាររបស់សមាជិករដ្ឋសភា



គណបក្សក្នុងរដ្ឋសភា និងការរៀបចំរាជរដ្ឋាភិបាល

នីតិកាលរដ្ឋសភា៥ឆ្នាំ	គណបក្សក្នុងរដ្ឋសភា និងសន្លឹកឆ្នោត	គណបក្សក្នុងរដ្ឋាភិបាល	គណបក្សឈរឈ្មោះបោះឆ្នោត
១ (១៩៩៣-១៩៩៨)	4 (៨៩.៧៨% នៃអ្នកទៅបោះឆ្នោត)	4 (រដ្ឋាភិបាលចម្រុះ)	២៣ (FUNCIPEC ឈ្នះឆ្នោត)
២(១៩៩៨-២០០៣)	3 (៩៣.៧៤% នៃអ្នកទៅបោះឆ្នោត)	2 (រដ្ឋាភិបាលចម្រុះ)	៣៩ (CPP ឈ្នះឆ្នោត)
៣ (២០០៣-២០០៨)	3 (៨៣.២២% នៃអ្នកទៅបោះឆ្នោត)	2 (រដ្ឋាភិបាលចម្រុះ)	២៣ (CPP ឈ្នះឆ្នោត)
៤ (២០០៨-២០១៣)	៥ (៧៥.២១% នៃអ្នកទៅបោះឆ្នោត)	៣ (រដ្ឋាភិបាលចម្រុះ)	១១ (CPP ឈ្នះឆ្នោត)
៥ (២០១៣-២០១៨)	២ (៦៩.៦១% នៃអ្នកទៅបោះឆ្នោត)	១ (រដ្ឋាភិបាល)	០៨ (CPP ឈ្នះឆ្នោត)
៦ (២០១៨-២០២3)	១ (៨៣.០២% នៃអ្នកទៅបោះឆ្នោត)	១ (រដ្ឋាភិបាល)	២០ (CPP ឈ្នះឆ្នោត)

(ប្រភព លេខាធិការដ្ឋាននៃគណកម្មាធិការជាតិរៀបចំការបោះឆ្នោត, ២០២១)

ដំណើរការអនុម័តច្បាប់ក្នុងនីតិកាលរដ្ឋសភា

រដ្ឋសភា (National Assembly)	ច្បាប់អនុម័ត (passed law)
First Term (1993-1998)	89
Second Term (1998-2003)	81
Third Term (2003-2008)	135
Fourth (2009-2013)	92
Fith (2013-2018)	101
Sixth (2018-2023)	74 (date to March 2021)

(Source, Secretariat of National Assembely, 2021)

២.៥. ការប្រជុំរដ្ឋសភា និងព្រឹទ្ធសភា

ប្រជុំរដ្ឋសភា និងព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ (មាត្រា៨៨, មាត្រា១១១)។ នេះជាគោលការណ៍សំខាន់បំផុតមួយនៃប្រព័ន្ធប្រជាធិបតេយ្យសភានិយម ពីព្រោះប្រជាពលរដ្ឋជាម្ចាស់ មានសិទ្ធិដឹងលឺកិច្ចការរបស់សភាតំណាងរបស់ខ្លួន (the rights to know) គ្រប់សកម្មភាពទាំងអស់ ក្នុងដំណើរការធ្វើនយោបាយជាតិ ឬធ្វើច្បាប់ (Legislative process) ។ ប៉ុន្តែក៏បានបង្កលក្ខណៈឲ្យមានការប្រជុំដាសំងាត់

ផងដែរ (Secret Meeting) ។ បន្ថែមពីនេះទៀតនៅក្នុងការប្រជុំគណៈកម្មការរបស់រដ្ឋសភា និងព្រឹទ្ធសភា ជាគោលការណ៍ មិនបើកចំហរទេ (Close Meeting) ។ ក្នុងការអនុវត្តជាក់ស្តែងកន្លងទៅពុំបើកទេ ប៉ុន្តែមានការផ្សព្វផ្សាយលទ្ធផលប្រជុំ។ ករណីនេះធ្វើឲ្យមានការលើកឡើងថា យន្តការចង្អៀតនេះមានលក្ខណៈប្រជាធិបតេយ្យពុំទូលំទូលាយ ដោយសារដំណើរការធ្វើច្បាប់ក្នុងយន្តការសភាឈរលើគោលការណ៍ប្រព័ន្ធគណៈកម្មការ (base on the committee system, and not reading system) ដែលការជជែកវែកញែកលើការសេចក្តីស្នើឬព្រាងច្បាប់ ក្នុងលក្ខណៈនយោបាយ និងបច្ចេកទេស ត្រូវបានរៀបចំធ្វើឡើងនូវជំហានបឋមក្នុងគណៈកម្មការចបច្ចេកទេសនោះ ។ នៅប្រទេសជប៉ុន អាឡឺម៉ង់ ឬអង់គ្លេស នៅក្នុងការអនុវត្តជាក់ស្តែង បើកចំហរឲ្យមានការបន្តផ្សព្វផ្សាយដោយផ្ទាល់តាមប្រព័ន្ធទូរទស្សន៍នូវការជជែកពិភាក្សា មិនត្រឹមតែសម្រាប់ការប្រជុំពេញអង្គរបស់សភាទាំងពីរនោះទេ ប៉ុន្តែរួមទាំងការប្រជុំគណៈកម្មការជំនាញ ។

២.៦. ដំណើរការធ្វើច្បាប់ក្នុងរដ្ឋសភា និងព្រឹទ្ធសភា

នៅកម្ពុជាតើភាគីខ្លះមានសិទ្ធិស្នើច្បាប់ទៅរដ្ឋសភា? មាត្រាទី៩១ ការស្នើច្បាប់ថ្មីចេញអាចមកពី៣ប្រភព អាចជាសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី ។ ក្នុងភាពជាក់ស្តែង នាយករដ្ឋមន្ត្រីដែលក្នុងនាមរាជរដ្ឋាភិបាល បានផ្តួចផ្តើមនូវសេចក្តីព្រាងច្បាប់ដាក់ជូនទៅរដ្ឋសភាមានច្រើនលើសលុបក្នុងនីតិកាលនីមួយៗ ។ ដោយឡែកសេចក្តីស្នើច្បាប់របស់សមាជិករដ្ឋសភា ឬព្រឹទ្ធសភាមានតិចតួចប៉ុណ្ណោះ។ នេះដោយសារអំណាចនីតិប្រតិបត្តិ មានក្រសួងស្ថាប័នបច្ចេកទេសច្រើន ជាអ្នកអនុវត្តគោលនយោបាយ និងច្បាប់របស់រាជរដ្ឋាភិបាល ដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ និងជាមួយសហគមន៍ ស្របតាមវិស័យបច្ចេកទេសនីមួយៗ ហើយពួកគាត់មានការយល់ដឹងពីសេចក្តីត្រូវការ និងភាពចាំបាច់ នៃការរៀបចំកែសម្រួលច្បាប់ និងគោលនយោបាយដើម្បីបម្រើសហគមន៍។ ដូច្នេះផ្លូវចេញចូលនៃឆន្ទៈរាស្ត្រតាមអំណាចនីតិប្រតិបត្តិមានភាពឆ្លើយតបលឿនជាង រហ័សជាង និងមានប្រសិទ្ធិភាពជាងតាមផ្លូវចេញចូលរដ្ឋសភា។

នៅប្រទេសបារាំង អាឡឺម៉ង់ និងអាមេរិក សេចក្តីស្នើច្បាប់ចេញពីអំណាចទាំង២មានតុល្យភាពនឹងគ្នា តែសេចក្តីស្នើច្បាប់ពីអំណាចនីតិប្រតិបត្តិបានទទួលការអនុម័តបានច្រើនជាង។ ការនេះមកពីសេចក្តីព្រាងច្បាប់នៃអំណាចនីតិប្រតិបត្តិមានសំឡេងភាគច្រើនក្នុងរដ្ឋសភា ជាបក្សកាន់អំណាច ។

២.៧. សមាជរដ្ឋសភា និងព្រឹទ្ធសភា

ក្នុងករណីចាំបាច់ រដ្ឋសភា និងព្រឹទ្ធសភា អាចប្រជុំរួមគ្នាជាសមាជដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ (មាត្រា១១៦ថ្មី)។ បញ្ហាសំខាន់ៗ របស់ប្រទេសជាតិ ការរៀបចំ និងការប្រព្រឹត្តិទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភានេះ ត្រូវកំណត់នៅក្នុងច្បាប់ (មាត្រា ១១៧ថ្មី)។

៣. អំណាចនីតិប្រតិបត្តិ (រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា)

៣.១. ការបង្កើតរាជរដ្ឋាភិបាល (ផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល)

រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ និងរដ្ឋធម្មនុញ្ញបន្ថែម កំណត់នីតិវិធីបង្កើតរាជរដ្ឋាភិបាលដោយរដ្ឋសភា។ នៅដើមនីតិកាលនីមួយៗ ក្រោយការប្រកាសលទ្ធផលបោះឆ្នោតសាកល រដ្ឋសភាថ្មីត្រូវបើកសម័យប្រជុំលើកដំបូង តាមការកោះរបស់ព្រះមហាក្សត្រ ដើម្បីចូលស្បថកាន់តំណែង និងរៀបចំនីតិវិធីបោះឆ្នោតបង្កើតក្បាលម៉ាស៊ីរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាលដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប។ នាយករដ្ឋមន្ត្រីត្រូវជាជាសមាជិករដ្ឋសភាស្នើចេញពីគណបក្សឈ្នះឆ្នោត ដែលមានចំនួនអាសនៈក្នុងរដ្ឋសភាច្រើនជាងគេ តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងឲ្យបង្កើតរាជរដ្ឋាភិបាល។

បើពិនិត្យការវិវត្តភាពជាក់ស្តែង (De Facto) ដំណើរការរៀបចំជ្រើសតាំងនាយរដ្ឋមន្ត្រីត្រូវបានរៀបចំឡើងស្របតាមឆន្ទៈភាគច្រើនរបស់ប្រជាពលរដ្ឋខ្មែរ ដែលបានសម្តែងឡើងនៅពេលបោះឆ្នោតជ្រើសតាំងដំណាងរាស្ត្ររដ្ឋសភា។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺស្របគ្នាជាមួយការបោះឆ្នោតជ្រើសតាំងបេក្ខជននាយករដ្ឋមន្ត្រីផងដែរ។ គណបក្សនយោបាយឈ្នះឆ្នោតទី១ នឹងទទួលបានប៉ុស្តិ៍នាយករដ្ឋមន្ត្រីជាស្វ័យប្រវត្តិនិងម៉្យាងទៀតនៅពេលឃោសនាបោះឆ្នោតនីមួយៗ គណបក្សនយោបាយធំៗ បានដាក់បង្ហាញដោយផ្ទាល់នូវបេក្ខជននាយករដ្ឋមន្ត្រីរបស់គណបក្ស ដោយភ្ជាប់ជាមួយនឹងកម្មវិធីនយោបាយគណបក្សច្បាស់លាស់ជូនប្រជាពលរដ្ឋដើម្បីសម្រេចតាមរយៈសន្លឹកឆ្នោត ។ នេះជានិន្នាការវិវត្តវិជ្ជមានមួយឆ្ពោះទៅរកប្រជាធិបតេយ្យភាវូបនីយកម្ម (Democratication) ក្នុងការរៀបចំបង្កើតក្បាលម៉ាស៊ីនស្ថាប័នអំណាចនីតិប្រតិបត្តិមួយនេះ។ ចរន្តវិវត្តនេះបានបង្កើតឲ្យមានបញ្ហាខ្លះ នៅក្នុងការរៀបចំបង្កើតរដ្ឋាភិបាលដោយរដ្ឋសភា នានីតិកាលទី១ និងទី២ក្នុងខណៈដែលប្រព័ន្ធកម្ពុជា កំណត់យកគោលការណ៍ (2/3) ក្នុងការបង្កើតរាជរដ្ឋាភិបាលកន្លងទៅ។ ប៉ុន្តែច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ២០០៦ បានកែសម្រួលយកតាមសំឡេងភាគច្រើនដាច់ខាត់ (50%+1) មកវិញដើម្បីធានានូវប្រសិទ្ធិភាពសណ្តាប់ធ្នាប់ប្រជាធិបតេយ្យ។

៣.២. អំណាចត្រួតពិនិត្យគ្នាទៅវិញទៅមករវាងរដ្ឋសភា និងរាជរដ្ឋាភិបាល

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ផ្តល់ឲ្យមានការបែងចែកអំណាចជាបីតាមទម្រង់រដ្ឋាភិបាលអាស្រ័យរដ្ឋសភា ប៉ុន្តែពុំមានប្រើគោលការណ៍ Check and Balances តាមទ្រឹស្តីរដ្ឋបស្ចឹមប្រទេសទាំងស្រុងនោះទេ ។

រដ្ឋសភាបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការបង្កើតរដ្ឋាភិបាល។ សមាជិករាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះមុខរដ្ឋសភា។ រដ្ឋសភាមានអំណាចទម្លាក់សមាជិករាជរដ្ឋាភិបាល/រាជរដ្ឋាភិបាល តាមការ

អនុម័តញត្តិបន្ទោស ប៉ុន្តែនាយករដ្ឋមន្ត្រីពុំមានអំណាចរំលាយរដ្ឋសភាបានទេ លើកលែងតែរាជរដ្ឋាភិបាលខ្លួនឯងត្រូវបានទម្លាក់ពីរដងដោយរដ្ឋសភាក្នុងរយៈពេល ១២ខែ ទើបព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភាក្រោយពីព្រះអង្គបានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា។ ករណីនេះមិនធ្លាប់បានកើតមាននៅឡើយ ហើយគោលការណ៍នេះ បានពង្រឹងនូវលំនឹងស្ថិរភាពរដ្ឋសភា និងស្ថិរភាពរាជរដ្ឋាភិបាលនៅគ្រប់នីតិកាលរដ្ឋសភា និងនាំមកនូវភាពសុខដុមនីយកម្មនៃអំណាចទាំងពីរ។

នៅប្រទេសអង់គ្លេស និងជប៉ុន ប្រព័ន្ធ Check & Balance ត្រូវបានយកមកប្រើនៅពេលអំណាចទាំងពីរមានការខ្វែងគំនិតគ្នាលើបញ្ហានយោបាយសំខាន់ៗ ឬនៅក្នុងការដំណើរការអនុម័តច្បាប់ ជាពិសេសរវាងបក្សកាន់អំណាច និងបក្សជំទាស់នៅក្នុងរដ្ឋសភា។ នាយករដ្ឋមន្ត្រីមានអំណាចរំលាយរដ្ឋសភាដោយគ្មានលក្ខខណ្ឌ និងប្រកាសឲ្យមានការរៀបចំការបោះឆ្នោតឡើងវិញ ជូនប្រជាពលរដ្ឋសម្រេចតាមការបោះឆ្នោត។ ប្រទេសកម្ពុជាធ្លាប់បានអនុវត្តនូវប្រព័ន្ធ Check & Balance នាសម័យរាជាណាចក្រទី១ (១៩៤៧-១៩៧០) ប៉ុន្តែប្រជាធិបតេយ្យសភានាពេលនោះ ពុំមានលំនឹងស្ថិរភាពរាជរដ្ឋាភិបាល និងរដ្ឋសភានោះទេ។ បទពិសោធន៍ Check & Balance របស់បស្ចឹមប្រទេស ពុំបានយកមកអនុវត្តពេញលេញឡើយ។

៤. **អំណាចតុលាការ** (**តុលាការកំពូល និងក្រុមប្រឹក្សាធម្មនុញ្ញ**)

ការរៀបចំអំណាចតុលាការកម្ពុជា លំអៀងតាមគំរូបារាំង និងអាឡឺម៉ង់ ដោយកំណត់យកនូវការបំបែកចេញនូវយុត្តាធិការទៅតាមវិស័យ ពុំដូចនៅអាមេរិក ឬជប៉ុនទេ ដែលបានកំណត់ក្នុងយុត្តាធិការតែមួយ។


រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ កំណត់អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។ អំណាចនេះ ត្រូវប្រគល់ឲ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់ (មាត្រា១២៨ថ្មី)។ រដ្ឋធម្មនុញ្ញ ផ្តល់ជូនព្រះមហាក្សត្រ ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ និងកំណត់បង្កើតឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ (មាត្រា១២៨, ១៣២)។

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចនៅក្នុងយុត្តាធិការពិសេស។ ទី១ ធានាការពារការគោរពរដ្ឋធម្មនុញ្ញ ទី២ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ និងទី៣ ពិនិត្យនិងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ នីតិវិធីនៃការពិនិត្យសំណុំរឿងមានលក្ខណៈចម្រុះនិងទូលំទូលាយ។

៥-អាជ្ញាធរមូលដ្ឋាន (ថ្នាក់ក្រោមជាតិ) និងសិទ្ធិស្វ័យភាព

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ កំណត់ការបែងចែកការគ្រប់គ្រងរដ្ឋបាលដែនដី ប៉ុន្តែពុំចែងអំពីសិទ្ធិស្វ័យភាពរបស់អាជ្ញាធរថ្នាក់ក្រោមជាតិទេ ដោយទុកឲ្យច្បាប់រៀបចំអង្គការជាអ្នកកំណត់ (មាត្រា ១៤៦&១៤៧)។ រាជរដ្ឋាភិបាលនិងរដ្ឋសភា បានរៀបចំអនុវត្តគោលនយោបាយប្រជាធិបតេយ្យនីយកម្ម ថ្នាក់ក្រោមជាតិតាមគោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការ។ ច្បាប់ស្តីពីការរៀបចំឃុំសង្កាត់២០០១ កំណត់នូវគោលនយោបាយវិមជ្ឈការ ដើម្បីពង្រឹកគ្រឹៈប្រជាធិបតេយ្យនៅមូលដ្ឋានដោយផ្ទាល់ ។ ការគ្រប់គ្រងអាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវបានធ្វើប្រតិភូកម្មអំណាចពីថ្នាក់ជាតិ តាមច្បាប់អនុម័តរបស់រដ្ឋសភា ផ្តល់ឲ្យក្រុមប្រឹក្សាឃុំសង្កាត់ ក្រុមប្រឹក្សាស្រុកខណ្ឌក្រុង និងក្រុមប្រឹក្សាខេត្តរាជធានី នូវសិទ្ធិស្វ័យភាពមួយចំនួនក្នុងកិច្ចការរៀបចំចាត់ចែងកិច្ចការអភិវឌ្ឍថ្នាក់មូលដ្ឋាន ប៉ុន្តែត្រូវអនុវត្តឲ្យស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។ មួយវិញទៀត ច្បាប់ថ្មីនេះ ឃុំសង្កាត់ ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំសង្កាត់មួយដែលត្រូវជ្រើសតាំងឡើងតាមការបោះឆ្នោតសកល ដោយប្រជាពលរដ្ឋក្នុងឃុំសង្កាត់របស់ខ្លួន តាមប្រព័ន្ធសមាមាត្រឃុំសង្កាត់។ ដោយឡែកការជ្រើសតាំងក្រុមប្រឹក្សាស្រុក/ខណ្ឌ/ក្រុង និងក្រុមប្រឹក្សាខេត្ត/រាជធានីកំណត់តាមការបោះឆ្នោតអសកល ដោយសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ជាអង្គបោះឆ្នោតវិញ។

រចនាសម្ព័ន្ធស្ថាប័នធម្មនុញ្ញនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣



៦. សំនួរសិក្ខាពិភាក្សា

សិទ្ធិស្វ័យភាពរបស់អាជ្ញាធរមូលដ្ឋាន តើអាចប៉ះពាល់ដល់ប្រជាធិបតេយ្យថ្នាក់ជាតិដែរឬទេ? តើមកដល់សព្វថ្ងៃនេះ បទពិសោធន៍នៅប្រទេសប្រជាធិបតេយ្យជឿនលឿន គេបានដោះស្រាយបែបណា? តើប្រទេសកម្ពុជាយើង បានជ្រើសរើសយកតាមទម្រង់ណាមួយ ក្នុងការរៀបចំអំណាចនៅថ្នាក់ក្រោមជាតិ?

(បទពិសោធន៍អង់គ្លេស)

Cf. James Bryce (1838-1922), the Famaous English scholar of political science, asserted in his book "Modern Democratic Politics" in 1921, "*Local autonomy System gives citizen their self-knowledge concering common interests for common affais and public oblication, and give citizens important education to learn how to cooperate with other citizens. Therefore the local autonomy is the best school for democracy and the best guarantor for success of democracy.*"

(បទពិសោធន៍ជប៉ុន)

Cf. Professor Hidenori Moto, the leading Japanese scholar of constitutional law, argued in the Seminar on the Comparative Study of the Constitutional Law (2004, in Nagoya University Graduate School of Law, doc.p.16.) that "the independent and sole state must be inseparable and indivisible, because the will of the sole state must be single. Therefore the democratic will, is in nature, excepted to be made by national wide democratic centralism. However it is very essential for democratic centralism that the true democratic people exist. The centralism without democratic people is very dangerous system."

ជំពូក៦

ប្រព័ន្ធបោះឆ្នោតជ្រើសតាំង

១. ប្រព័ន្ធបោះឆ្នោតក្នុងប្រទេសប្រជាធិបតេយ្យ

ប្រព័ន្ធបោះឆ្នោត (Election System) ជាចំណុចគន្លឹះសំខាន់បំផុត សម្រាប់ការកំណត់នូវចរិកលក្ខណៈរបស់ស្ថាប័នតំណាង និងអ្នកនយោបាយ ។ ម៉្យាងវិញទៀត Election System ដើរតួនាទីជាមូលសារាំង ចាក់បញ្ចូលនូវភាពស្របច្បាប់ ទៅក្នុងនយោបាយក្នុងការជ្រើសតាំងអង្គការរដ្ឋ - សម្រាប់កំរិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដោយសន្តិភាព ។ ដូច្នេះហើយ នៅប្រទេសប្រជាធិបតេយ្យជឿនលឿន គេយកចិត្តទុកដាក់ សម្បើមណាស់លើប្រព័ន្ធបោះឆ្នោត។ ដើម្បីជាប្រយោជន៍នៅក្នុងជំពូកនេះ ខ្ញុំព្យាយាមពិនិត្យសិក្សាមើលបទពិសោធន៍ខ្លះៗពីប្រទេសមួយចំនួនក្នុងការរៀបចំប្រព័ន្ធបោះឆ្នោតរបស់ផងគេ។

២. ប្រព័ន្ធបោះឆ្នោតប្រទេសអង់គ្លេស

នៅស្រុកអង់គ្លេស ការបោះឆ្នោតជ្រើសតាំងសភាជាន់ទាប (House of Commons, 659 seats) គេប្រើប្រព័ន្ធឯកត្តនាមយកតាមសម្លេងភាគច្រើន (First Past the Post System) ។ ចំណុចស្នូលនៅក្នុងប្រព័ន្ធនេះគឺភាពងាយស្រួលរបស់វា (Simplicity) ។ បេក្ខជនឈរឈ្មោះណាដែលបានទទួលសន្លឹកឆ្នោតច្រើនជាងគេនៅក្នុងការបោះឆ្នោតក្នុងមណ្ឌលរបស់ខ្លួន គឺជាអ្នកឈ្នះឆ្នោតតែម្តងដោយពុំខ្វល់អំពីសមាមាត្រនៃសន្លឹកឆ្នោតសម្រាប់ខ្លួនគេ ឬសម្រាប់គូរប្រជែងនឹងគេនោះឡើយ ។ ចំណុចនេះ នៅក្នុងការអនុវត្តជាក់ស្តែង បានបង្កើតឲ្យមានអសមភាព ក្នុងការបែងចែកអំណាចសន្លឹកឆ្នោត សម្រាប់តំណាងមកពីគណបក្សតូចៗ និងបាននាំមកនូវស្ថានភាពមួយដែលគណបក្សនយោបាយមួយចាញ់សន្លឹកឆ្នោតសោះ ប៉ុន្តែក្លាយជាគណបក្សឈ្នះអាសនៈក្នុងសភា Commons និងមានសិទ្ធិរៀបចំរដ្ឋាភិបាលគ្រប់គ្រងប្រទេស ។

គុណវិបត្តិនេះ ធ្វើឲ្យមានមតិរិះគន់ពីបញ្ញាជននិយមកែទម្រង់ ពីព្រោះវាផ្ទុយពីគោលការណ៍ប្រជាធិបតេយ្យ ហើយបានអំពាវនាវឲ្យមានការកែទម្រង់ប្រព័ន្ធបោះឆ្នោត ។ ប៉ុន្តែអ្នកគាំទ្រឲ្យរក្សាទុក ក្នុងនោះក្រុមអភិរក្សបានរកឃើញថា ប្រព័ន្ធឯកត្តនាមដែលនៅបន្តប្រើបច្ចុប្បន្ននេះ មានចំណុចខ្លាំងពិសេសៗ ជាច្រើនដែលតម្រូវឲ្យគួររក្សាទុកជាបន្តទៀត ។ ទីមួយ វាបានបង្កើតឲ្យមានប្រព័ន្ធគណបក្សពីរ (Two-Party System) ដែលប្រព័ន្ធនេះ បានលើកស្ទួយឲ្យមានគុណភាព និងការប្រកួតប្រជែងគណបក្សបានល្អបំផុតជាងបណ្តាប្រព័ន្ធឯកបក្ស ឬពហុបក្ស ។ ទីពីរ ប្រព័ន្ធនេះ បានបង្កើតឲ្យមាននូវរាជរដ្ឋាភិបាលពូកែ (A Strong Government) រួមជាមួយសមាជិកសភាជាច្រើននៅក្នុងសភា Commons ជំរុញឲ្យមានប្រសិទ្ធ

ភាពពេញលេញក្នុងការអនុវត្តកម្មវិធីនយោបាយរបស់គណបក្ស ដោយពុំសូវមានឧបសគ្គបញ្ហានយោបាយ ស្មុគស្មាញច្រើន។ ទីបី ប្រព័ន្ធនេះបានបង្កើតឲ្យមានទំនាក់ទំនងយ៉ាងជិតស្និតរវាងប្រជាពលរដ្ឋ និងអ្នក តំណាងរាស្ត្ររបស់លោកដែលបម្រើនៅក្នុងមណ្ឌលនោះបានល្អប្រសើររៀងដរាបមក។ ដូច្នេះការជម្រុញឲ្យ មានការកែទម្រង់នោះនៅតែស្ថិតនៅជាបញ្ហាមួយដែលមិនទាន់អាចធ្វើទៅបាន នៅក្នុងនយោបាយរបស់ ប្រទេសអង់គ្លេសនាបច្ចុប្បន្នភាពនេះ និងក៏ដូចជានាពេលអនាគតផងដែរ។

ដោយឡែក សភាគហបតីអង់គ្លេស ឬ សភាជាន់ខ្ពស់ (House of Lords, now 689 seats) ដែល បាន បន្តកេរ្តិ៍ដំណែលប្រវត្តិសាស្ត្រពីប្រព័ន្ធវណ្ណៈតាំងពីរាជបុរាណមកនោះ ពុំត្រូវបានជ្រើសតាំងតាមប្រព័ន្ធ ដូច សភាជាន់ទាបនោះទេ ប៉ុន្តែត្រូវបានតែងតាំងដោយព្រះមហាក្សត្រីយានី តាមសំណើររបស់នាយករដ្ឋមន្ត្រី សម្រាប់អាណត្តិមួយជីវិត ។ សមាជិកភាពជាអភិជនល្បីៗ (ទាំងថ្មីទាំងបន្តមរតក) ចៅក្រមចូលនិវត្តន៍ ឬចៅក្រមលាលែងពីដំណែង និងអតីតនាយករដ្ឋមន្ត្រីជាដើម។ លក្ខណៈពិសេសដោយឡែកមួយទៀត សភាគហបតីនេះពុំមានអាណត្តិ និងពុំអាចរំលាយបាន ។ ចំណុចទាំងអស់ហ្នឹងហើយ ដែលបានបង្កើតឲ្យ មានការរិះគន់ខ្លាំងៗ ពីក្រុមអ្នកនិយមការកែទម្រង់ ពីព្រោះមិនស្របទៅតាមគោលការណ៍ប្រជាធិបតេយ្យ តំណាង ហើយព្រមទាំងអំពាវនាវឲ្យរំលាយស្ថាប័ននេះចោលទៀតផង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅ ក្នុងការអនុវត្តជាក់ស្តែង The House of Lords បំពេញតួនាទីសំខាន់ នៅក្នុងដំណើរការប្រជាធិបតេយ្យ សភានិយមនៅអង់គ្លេស ពីព្រោះម៉្យាងសភានេះបានបំពេញតួនាទីជាវេទិកានយោបាយមួយ សម្រាប់ឆ្លុះ បញ្ចាំង និងសម្រាប់ធ្វើការពិចារណាជាលើកទី២លើកម្មវិធីនយោបាយជាតិ ឬលើសេចក្តីច្បាប់នានា (A Forum for Reflection and for Second Thoughts in Policies/Legislative Proposals) ។ ម៉្យាង ទៀត សភាគហបតីនេះបានសម្តែងនូវតួនាទីដ៏មានតម្លៃមួយនៅក្នុងសង្គមប្រជាធិបតេយ្យអង់គ្លេស ក្នុងការ ប្រើសិទ្ធិកែតម្រូវឡើងវិញនូវសេចក្តីព្រាងច្បាប់ទាំងឡាយណា ដែលបានអនុម័តដោយសភា Commons នៅពេលដែលមានការជំទាស់ពីមតិសាធារណៈជនផុលផុស។ ដូច្នេះហើយនៅក្នុងភាពជាក់ស្តែង House of Lords នៅតែមានសារប្រយោជន៍ និងសំខាន់សម្រាប់នយោបាយប្រជាធិបតេយ្យសភា ទោះបីជាពុំបាន បោះឆ្នោតជ្រើសតាំងជាសកល និងដោយផ្ទាល់ពីប្រជាពលរដ្ឋអង់គ្លេសក៏ដោយចុះ ។

៣. ប្រព័ន្ធបោះឆ្នោតប្រទេសអាឡឺម៉ង់

នៅស្រុកអាឡឺម៉ង់ ប្រព័ន្ធសភាជាសហសភាមានសភាសហព័ន្ធ Bundestag និងក្រុមប្រឹក្សាសភា សហព័ន្ធ Bundesrat ។ Bundesrat (Federal Council, now 69 seats) មិនត្រូវបានជ្រើសតាំងដោយ ការបោះឆ្នោតដូចសភា Bundestag ទេ ប៉ុន្តែជាក្រុមប្រឹក្សា (សភា) តំណាងដោយផ្ទាល់ពីរដ្ឋាភិបាលទាំង ១៦ រដ្ឋ ។ ចំណែកឯសភា Bundestag (=Federal Diet, now 598 seats) ជាសភាសហព័ន្ធដែលជ្រើស

តាំងដោយការបោះឆ្នោតសកលដោយផ្ទាល់ពីប្រជាពលរដ្ឋអាឡឺម៉ង់សម្រាប់មួយអាណត្តិបួនឆ្នាំ តាមប្រព័ន្ធ បោះ ឆ្នោតសមាមាត្រចម្រុះសមាជិក (Mixed Member Proportional System or Personalized Proportional Representation) ។ នៅក្នុងប្រព័ន្ធនេះ មានភាពស្មុគស្មាញបន្តិច ពីព្រោះបានច្របាច់ប្រព័ន្ធពីរបញ្ចូលគ្នាដោយគិតសរុបតាមសមាមាត្រសន្លឹកឆ្នោតនៅទូទាំងសហព័ន្ធ។

អាសនៈចំនួនពាក់កណ្តាល (២៩៩) បោះតាមប្រព័ន្ធឯកត្តនាមតាមសម្លេងភាគច្រើនធម្មតា និងអាសនៈចំនួនពាក់កណ្តាលទៀត (២៩៩) បោះតាមប្រព័ន្ធសមាមាត្រលើបញ្ជីគណបក្សនយោបាយសម្រាប់រដ្ឋនីមួយៗ ។ ដូច្នេះប្រជាពលរដ្ឋអាឡឺម៉ង់ក្នុងពេលបោះឆ្នោតម្តងៗ មានសន្លឹកឆ្នោតពីរ មួយបោះសម្រាប់បេក្ខជនឈរឈ្មោះនៅក្នុងមណ្ឌលឯកត្តនាម និងមួយទៀតបោះសម្រាប់គណបក្សដែលឈរឈ្មោះនៅក្នុងរដ្ឋរបស់ខ្លួន ។ សន្លឹកឆ្នោតទី២នេះ មានសារៈសំខាន់ណាស់ នៅក្នុងការកំណត់អាសនៈសម្រាប់គណបក្សនីមួយៗ ពីព្រោះការបែងចែកអាសនៈទៅក្នុង Bundestag សម្រាប់គណបក្សនីមួយៗ នោះត្រូវគិតសរុបតាមសមាមាត្រសន្លឹកឆ្នោតទីពីរនេះ សម្រាប់នៅទូទាំងសហព័ន្ធតែម្តង ។

ដូច្នេះហើយ គណបក្សនយោបាយនៅអាឡឺម៉ង់ នៅពេលឃោសនាបោះឆ្នោតម្តងៗ គេផ្តោតទៅលើសន្លឹក ទីពីរនេះ តាមរយៈការដាក់បង្ហាញកម្មវិធីនយោបាយ និងបេក្ខជនអធិការបតីជាក់លាក់មួយរបស់គណបក្សសម្រាប់ឲ្យប្រជាពលរដ្ឋរបស់គេ ធ្វើការសម្រេចចិត្តតាមរយៈសន្លឹកឆ្នោត ។ ប៉ុន្តែច្បាប់បោះឆ្នោតអាឡឺម៉ង់បានកែតម្រូវឲ្យគណបក្សនីមួយៗ អាចមានសិទ្ធិទទួលការបែងចែកអាសនៈ សម្រាប់សន្លឹកឆ្នោតទីពីរនេះបាន លុះត្រាតែពួកគេបានទទួលសន្លឹកឆ្នោតទីពីរ នេះយ៉ាងតិចក៏ ៥ភាគរយនៃសន្លឹកឆ្នោតទូទាំងសហព័ន្ធ ឬបានឈ្នះអាសនៈឯកត្តនាមយ៉ាងតិចបីអាសនៈ ។ ការដាក់ចេញនូវលក្ខខ័ន្តផ្លូវច្បាប់នេះ ហាក់បានរំលោភទៅលើគោលការណ៍ សមភាពនៃសិទ្ធិសន្លឹកឆ្នោត (The Principle of Equality of Voting Rights) ក៏ពិតមែន ប៉ុន្តែ ផ្តោតលើការលើកកម្ពស់ការទទួលខុសត្រូវជាសំខាន់ ទៅលើស្ថិរភាពនៃប្រព័ន្ធគណបក្ស (Political Party System) ទាំងមូលដែលជាគ្រឹះធ្វើឲ្យមានស្ថិរភាពនយោបាយជាតិ ។

ជាឧទាហរណ៍ជាក់ស្តែងមួយនៃការបែងចែកអាសនៈទៅក្នុងសភា Busdestag ។ ការបោះឆ្នោតនៅឆ្នាំ ២០០២ មានគណបក្ស៥ គឺគណបក្សសង្គមប្រជាធិបតេយ្យអាឡឺម៉ង់ (Social Democratic Party of Germany –SPD) គណបក្សសម្ព័ន្ធប្រជាធិបតេយ្យគ្រីស្ទេន (Christian Democratic Union –CDU) គណបក្សសម្ព័ន្ធសង្គមគ្រីស្ទេន (Christian Social Union –CSU) គណបក្សសម្ព័ន្ធបៃតង (Alliance 90/The Green) និងគណបក្សប្រជាធិបតេយ្យសេរី (Free Democratic Party (F.D.P) បានឈ្នះសន្លឹកឆ្នោតទីពីរ សរុបលើសពី៥ភាគរយដែលបានតម្រូវដោយច្បាប់បោះឆ្នោត ហើយត្រូវបានរាប់បញ្ចូលជាចំណែកក្នុងការបែងចែកអាសនៈ សម្រាប់កំរិតសហព័ន្ធតាមរបបសមាមាត្រ ។

សរុបសន្លឹកឆ្នោតរួមនៃគណបក្សទាំង៥ខាងលើមាន ៤៤,៦២០,៤៧៩សន្លឹក។ ម៉្យាងវិញទៀតគណបក្ស PDS (Party of Democratic Socialism) បានឈ្នះតែ២អាសនៈពីមណ្ឌលឯកត្តនាម ប៉ុន្តែសន្លឹកឆ្នោតទីពីររបស់គេ នៅក្រោម៥ភាគរយ ដូច្នេះហើយ គណបក្ស PDS នេះត្រូវបានដកចេញពីការបែងចែកអាសនៈសម្រាប់ សមាមាត្រពីកំរិតថ្នាក់សហព័ន្ធ ។ ដោយគណបក្ស PDS មាន២អាសនៈពីមណ្ឌលឯកត្តនាម ប៉ុន្តែបក្សនេះត្រូវបានដកចេញពីការបែងចែកអាសនៈតាមសមាមាត្រនោះ ដូច្នេះចំនួនអាសនៈដែលត្រូវបែងចែកទៅឲ្យ៥គណបក្សខាងលើនៅសល់៥៩៦អាសនៈ ។

ការគណនាខាងក្រោម នេះជារបៀបបែងចែកអាសនៈនៅអាឡឺម៉ង់ៈ

<u>ការគណនានៅជុំទី១</u>

១- បែងចែកអាសនៈជាសរុបតែម្តងទៅឲ្យគណបក្សនីមួយៗ តាមវិធីគណនាខាងក្រោម

[(18.488.688) : (44.620.479)] x (596) = 246, 954904 សម្រាប់ SPD

[(14.167.561) : (44.620.479)] x (596) = 189, 237466 សម្រាប់ CDU

[(4.315.080) : (44.620.479)] x (596) = 57, 636936 សម្រាប់ CSU

[(4.110.355) : (44.620.479)] x (596) = 54, 902404 សម្រាប់ Alliance 90/Green

[(3.538.815) : (44.620.479)] x (596) = 47, 268290 សម្រាប់ F.D.P

២- បន្ទាប់មកចំនួនគត់ដែលគណៈបក្សនីមួយៗទទួលពីការគណនានេះ ជាចំនួនអាសនៈដែល ទទួលបាន

List	Seats
SPD	246
CDU	189
CSU	57
Alliance 90/The Green	54
F.D.P	47
PDS	2
Total	595

៣- ប៉ុន្តែវានៅសល់សំណល់៣អាសនៈ ដូច្នេះហើយគេយកវាមកបែងចែកជាបន្តទៀតទៅឲ្យគណបក្ស តាមលំដាប់សំណល់ធំបំផុតរបស់គណបក្សនីមួយៗ (The Highest Decimal Frantions):

List	Fractions	Remaining Seats
SPD	0.954904	1
Alliance 90/The Greens	0.902404	1
CSU	0.636936	1
F.D.P	0.268290	0
CDU	0.237466	0

៤- ដូច្នេះចំនួនអាសនៈសរុបដែលគណបក្សនីមួយៗ បានទទួលពេញលក្ខណៈច្បាប់គឺ:

List	Seats
SPD	247
CDU	189
CSU	58
Alliance 90/The Greens	55
F.D.P	47
PDS	2
Total	598

<u>ការគណនានៅជុំទី២</u>


អាសនៈដែលគណបក្សនីមួយៗទទួលបាន ត្រូវបែងចែកតាមសមាមាត្រនៃសន្លឹកឆ្នោតដែលបក្ស បានទទួលនៅតាមរដ្ឋនីមួយៗជាបន្តទៀត ។ ឧទាហរណ៍ នៅក្នុងរដ្ឋ Nordrthein-Westfalen គណបក្ស SPD បានទទួលសន្លឹកឆ្នោត ៤ ៤៩៩ ៣៨៨ សន្លឹកនៃសន្លឹកឆ្នោតទីពីរសរុប ១៨ ៤៨៨ ៦៦៨ សន្លឹក ។ ដោយគណបក្សទទួលបានអាសនៈសរុប ២៤៧ អាសនៈពីការបែងចែកក្នុងកំរិតថ្នាក់សហព័ន្ធនោះ ការបែងចែកអាសនៈជាសមាមាត្រសម្រាប់កំរិតរដ្ឋជាបន្ត គឺធ្វើតាមវិធីគណនាដូចខាងក្រោមនេះ :

១- យក [(4.499.388): (18.488.668)] x (247) = 60,109730 មានន័យថា SPD ឈ្នះ ៦០ អាសនៈ នៅក្នុងរដ្ឋ Nordrthein-Westfalen ។

២- តាមការគណនា (១) គណបក្ស SPD ត្រូវបានទទួល៦០អាសនៈ សម្រាប់រដ្ឋ Nordrthein-Westfalen ។ ប៉ុន្តែដោយនៅក្នុងរដ្ឋនោះ គណបក្ស SPD បានឈ្នះ៤៥អាសនៈ នៅតាមមណ្ឌល ឯកត្តនាម ដូច្នេះចំនួនអាសនៈដែលបក្សនេះត្រូវទទួលបានសម្រាប់បញ្ជីគណបក្សក្នុងរដ្ឋ គឺមានតែ ១៥អាសនៈ ។ របៀបនេះបន្តធ្វើដូចៗ គ្នាសម្រាប់គណបក្សដទៃទៀត ។

ដូច្នេះប្រព័ន្ធបោះឆ្នោតសម្រាប់សមាជិកសភា Bundestag នៅអាឡឺម៉ង់មានលក្ខណៈជាប្រព័ន្ធសមាមាត្រសុទ្ធសាធទោះបីជាចំនួនពាក់កណ្តាលនៃសមាជិករបស់វាបោះឆ្នោតជ្រើសតាំង តាមប្រព័ន្ធឯកត្តនាមក៏ដោយចុះ។ តើហេតុអ្វីទៅបានជាអាឡឺម៉ង់បង្កើតប្រព័ន្ធនេះឡើង? ផ្តល់អ្វីខ្លះដល់ប្រជាធិបតេយ្យសភា?

រចនាសម្ព័ន្ធស្ថាប័នធម្មនុញ្ញប្រទេសអាឡឺម៉ង់



Source: Cf. Hor Peng (2005, p.147)

៤. ប្រព័ន្ធបោះឆ្នោតប្រទេសជប៉ុន

សភាជប៉ុន (Kokkai) ជាប្រព័ន្ធសហសភាដែលរួមមានសភាជាន់ទាប Shugi-In (House of Repre- sentatives, 480 Seats for its term four year) និងសភាជាន់ខ្ពស់ Sang-In (House of Councilors, 242 seats, for its term six years) ។ សភាទាំងពីរនេះ ជ្រើសតាំងឡើងតាមការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋជប៉ុន ប៉ុន្តែកំណត់យកប្រព័ន្ធខុសគ្នា។ សភាជាន់ទាប Shugi-In ប្រើប្រាស់ប្រព័ន្ធបោះឆ្នោតសំយោគរវាងប្រព័ន្ធឯកត្តនាមដែលមាន ៣០០អាសនៈ សម្រាប់៣០០ មណ្ឌល និងប្រព័ន្ធតំណាងសមាមាត្រក្នុងតំបន់ដែលមាន ១៨០ អាសនៈសម្រាប់ ១១មណ្ឌល (A combination system of mainly the single-seat constituencies [300], plus a small number of the proportional representation constituencies [180 for 11 muti-seat regional blocs] ។

នៅពេលមានការបោះឆ្នោតជ្រើសតាំងសមាជិកសភាជាន់ទាប Shugi-In ម្តងៗ អ្នកបោះឆ្នោតជប៉ុនមានសន្លឹកឆ្នោតពីរដូចគ្នានៅប្រទេសអាឡឺម៉ង់ ដែលមួយបោះសម្រាប់បេក្ខជនឈរនៅមណ្ឌលឯកត្តនាមក្នុងមណ្ឌលរបស់ខ្លួន និងមួយទៀតបោះសម្រាប់ឈ្មោះគណបក្សនយោបាយក្នុងតំបន់របស់ខ្លួនរស់នៅ។

ការបង្កើតប្រព័ន្ធសំយោគនេះឡើងគឺសំដៅដំរុញនិងបង្ខំឲ្យអ្នកនយោបាយជប៉ុន ត្រូវខិតខំបំរើប្រជាពលរដ្ឋនិងបំរើគណបក្ស ដើម្បីរក្សាអាសនៈរបស់ពួកគេឲ្យបាននៅយូរដែលអាចធ្វើបាន ។ មួយវិញទៀតប្រព័ន្ធបោះសម្រាប់សន្លឹកឆ្នោតទី២នៅជប៉ុន ពុំដូចគ្នាជាមួយនឹងប្រព័ន្ធនៅប្រទេសអាឡឺម៉ង់ទេ ។ នៅក្នុងប្រព័ន្ធបោះឆ្នោតសម្រាប់សភាជាន់ទាបនេះ មានចំណុចមួយចំនួនលើកមកធ្វើការកត់សំគាល់៖

<u>ចំណុចទីមួយ</u>: ប្រព័ន្ធតំណាងសមាមាត្រតំបន់ ។ ប្រព័ន្ធនេះបោះលើបញ្ជីបេក្ខជនគណបក្សបិទ (A Close Party Candidate List System) និងមានដាក់កំរិតលក្ខខណ្ឌយ៉ាងតឹងរ៉ឹងទាំងផ្លូវច្បាប់ ទាំងភាពជាក់ស្តែងមួយចំនួនទៅលើគណបក្សនយោបាយនីមួយៗ ទាំងក្នុងការដាក់ស្នើឡើងបញ្ជីបេក្ខជនគណបក្សនិងទាំងក្នុងការធ្វើការបែងចែកអាសនៈទៀតផង ។ គណបក្សនយោបាយនីមួយៗ ដើម្បីមានសិទ្ធិស្នើឡើងបញ្ជីបេក្ខជនគណបក្សជាផ្លូវការសម្រាប់មណ្ឌលតំបន់បាន (១)- ត្រូវមានអាសនៈនៅក្នុងសភាទាំងពីរយ៉ាងតិច៥អាសនៈ ឬ (២)- ត្រូវមានសន្លឹកឆ្នោតទទួលបានកាលពីបោះឆ្នោតលើកមុនយ៉ាងតិច២ភាគរយ ឬ (៣)- ត្រូវមានបេក្ខជនឈរឈ្មោះយ៉ាងតិច២០ភាគរយនៅក្នុងមណ្ឌលតំបន់ទាំងមូល ។

ម៉្យាងវិញទៀតតាមផ្លូវច្បាប់ពុំមានកំណត់លក្ខខណ្ឌអ្វីសម្រាប់គណបក្សនយោបាយ ដើម្បីធ្វើឲ្យគេមានសិទ្ធិក្នុងការបែងចែកអាសនៈដូចនៅក្នុងប្រទេសអាឡឺម៉ង់នោះទេ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែងនោះវាហាក់ដូចជាលេចមានលក្ខខណ្ឌខ្លះ ដោយសារការប្រកាន់យកវិធីបែងចែកអាសនៈ។ សម្រាប់គណបក្ស

នីមួយៗ ជាឧទាហរណ៍ នៅតំបន់ Shikoku (មាន៦អាសនៈ) ត្រូវការចាំបាច់សន្លឹកឆ្នោតជាបឋមយ៉ាងតិច ១/៦ នៃចំនួនសន្លឹកឆ្នោតសរុបក្នុងមណ្ឌលតំបន់នោះ ដើម្បីអាចមានសិទ្ធិឈ្នះមួយអាសនៈ បើមិនដូច្នោះទេ គណបក្សនោះ នឹងត្រូវដកចេញពីការបែងចែកអាសនៈក្នុងមណ្ឌលនៅតំបន់នោះទាំងស្រុង។ ការអនុវត្តនូវចំណុចនេះ បង្កឲ្យមានការទិទៀនថា ប្រព័ន្ធតំណាងសមាមាត្រសម្រាប់សន្លឹកឆ្នោតទី២នេះ មិនមែនប្រព័ន្ធតំណាងសមាមាត្រដែលយកសន្លឹកឆ្នោតពិតប្រាកដនោះទេ ពីព្រោះនៅពេលធ្វើការបែងចែកអាសនៈវាបានផាត់ចោលគណបក្សតូចៗចេញ ហាក់ដូចជាផ្ទុយទៅនឹងគោលការណ៍សមភាពនៃសម្លេងឆ្នោត ។

<u>ចំណុចទី២</u> ប្រព័ន្ធបោះឆ្នោតសម្រាប់សភាជាន់ទាបជប៉ុន អនុញ្ញាតឲ្យមានគោលការណ៍ទ្វេបេក្ខជន (Allowing Dual Candidacy) ដូចនៅប្រទេសអាឡឺម៉ង់ដែរ ។ គោលការណ៍នេះ អ្នកនយោបាយម្នាក់ នៅក្នុងគណបក្សមួយរបស់ជប៉ុន អាចឈរឈ្មោះជាបេក្ខជនបានស្របច្បាប់សម្រាប់មណ្ឌលឯកត្តនាមផង និងសម្រាប់មណ្ឌលសមាមាត្រតាមតំបន់ផង ដូច្នេះនៅពេលដែលបេក្ខជននេះចាញ់ឆ្នោតនៅស្រុកកំណើតនៅមណ្ឌលឯកត្តនាម គេអាចនៅមានឱកាសឈ្នះអាសនៈបាន ប្រសិនបើគេស្ថិតក្នុងលំដាប់ខ្ពស់ក្នុងបញ្ជីបេក្ខជនរបស់គណបក្សសម្រាប់មណ្ឌលតំបន់។ តើហេតុអ្វីជប៉ុនបង្កើតឲ្យមានគោលការណ៍នេះ ?

បើតាមទស្សនៈស្រប មានហេតុផលពីរ ទីមួយ គឺដើម្បីកាត់បន្ថយបន្ទុករបស់គណបក្សនយោបាយក្នុងការរកបេក្ខជន សម្រាប់ឈរឈ្មោះបោះឆ្នោត និងមួយទៀត គឺអនុញ្ញាតឲ្យគណបក្សអាចមានលទ្ធភាពដឹកកកាយយកសន្លឹកឆ្នោត ក្នុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត។ នេះជាការធ្វើឲ្យគណបក្សនិងអ្នកនយោបាយជប៉ុន អាចមានជីវិតរស់រានឡើងវិញក្នុងការបោះឆ្នោត (The Revival of Election) ។

ប្រសិនពុំមានប្រើគោលការណ៍នេះទេ ប្រជាធិបតេយ្យសភាជប៉ុន នឹងពុំមានភាពប្រសើរឡើយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយនៅក្នុងមតិសាធារណៈជប៉ុន គេមើលឃើញថាជាភាពអវិជ្ជមានមួយរបស់អ្នកនយោបាយ ។ ពាក្យថា "The Revival of Election" ខ្មែរយើងប្រែថា *ការធ្វើឲ្យរស់រានឡើងវិញក្នុងពេលបោះឆ្នោត* ធ្វើឲ្យមានមតិរិះគន់មិនល្អ លើគណបក្សនយោបាយ និងអ្នកនយោបាយជប៉ុន ពីព្រោះបេក្ខជនដែលចាញ់ឆ្នោតនៅមណ្ឌលឯកត្តនាម នៅមានលទ្ធភាពត្រលប់ចូលមកវិញតាមរយៈមណ្ឌលតំបន់តំណាងសមាមាត្រ។ នេះជាការរៀបចំដើម្បីការពាររក្សាទុកអ្នកជំនាញនយោបាយល្អៗ ដែលមិនសូវមានប្រជាប្រិយ៍ប៉ុន្តែមានបទពិសោធន៍ច្រើនក្នុងនយោបាយ ជាងការយកចិត្តទុកដាក់ធ្វើយ៉ាងណាឲ្យការបោះឆ្នោតអាចបម្រើឲ្យការឆ្លុះបញ្ចាំងឆន្ទៈប្រជាពលរដ្ឋជប៉ុនពិតៗ ទៅក្នុងនយោបាយប្រជាធិបតេយ្យសេរីនោះទេ ។

ចំនែកសភាជាន់ខ្ពស់ Sangi-In មានព្រឹទ្ធសមាជិក ២៤២ ជ្រើសតាំងឡើង តាមការបោះឆ្នោតដោយផ្ទាល់ ពីប្រជាពលរដ្ឋជប៉ុន ដូចគ្នានឹងសភាជាន់ទាប Shugi-In ដែរ ប៉ុន្តែប្រើប្រព័ន្ធបោះឆ្នោតខុសគ្នា ។

ប្រព័ន្ធនេះធ្វើសំយោគកម្មរវាងប្រព័ន្ធបោះឆ្នោតតំណាងសមាមាត្រកំរិតជាតិ ដែលយកប្រទេសទាំងមូលជាមណ្ឌលមួយ (a single nationwide electoral district) និងប្រព័ន្ធបោះឆ្នោតឯកត្តនាម តែមណ្ឌលមានពហុអាសនៈ (a single non-transferable vote within multi-seat constitutioncy system) ។

ចំនួន ៩៦អាសនៈ ក្នុងចំណោម ២៤២អាសនៈ កំណត់សម្រាប់មណ្ឌលតំណាង សមាមាត្រកំរិតជាតិ ហើយក្នុងនោះ ចំនួន៣ក់កណ្តាលនៃអាសនៈនេះ ត្រូវបោះឆ្នោតរាងរាល់៣ឆ្នាំម្តង ដូច្នេះមានតែចំនួន៤៨ អាសនៈ ទេ ដែលត្រូវជ្រើសតាំងរាល់ការបោះឆ្នោតនីមួយៗ សម្រាប់មណ្ឌលបោះឆ្នោតតំណាងសមាមាត្រកំរិតជាតិនេះ ។ ចំនែកចំនួនអាសនៈដែលនៅសល់ ១៤៦ អាសនៈសម្រាប់មណ្ឌលបោះឆ្នោត ឯកត្តនាម មានពហុអសនៈ ត្រូវបែងចែកសម្រាប់៤៧មណ្ឌល (ខេត្តទាំងអស់ជាមណ្ឌល) ក្នុងនេះអាសនៈមណ្ឌលនីមួយៗ មានពី២ ទៅ៨អាសនៈ ប៉ុន្តែដោយមានតែចំនួន៣ក់កណ្តាល ត្រូវបោះជ្រើសតាំងរៀងរាល់៣ឆ្នាំ ដូច្នេះចំនួនពិតមានតែ៧៣សម្រាប់ការបោះឆ្នោតមួយលើកៗ មណ្ឌលនីមួយៗពី១ទៅ៤អាសនៈ។

ដូចនៅពេលបោះឆ្នោតជ្រើសតាំងសមាជិកសភាព្រឹទ្ធសភាម្តងៗ អ្នកបោះឆ្នោតជប៉ុន មានសន្លឹកឆ្នោតពីរ សន្លឹកឆ្នោតទីមួយ បោះសម្រាប់ឈ្មោះគណបក្ស ឬឈ្មោះបេក្ខជនក្នុងបញ្ជីគណបក្សតំណាងសមាមាត្រថ្នាក់ជាតិ (Vote for Open Party Candidate List System of Proportional Representation) និងសន្លឹកឆ្នោតទី២ បោះសម្រាប់ឈ្មោះបុគ្គលនៅមណ្ឌលឯកត្តនាមដែលមានពហុអាសនៈ។ ដូច្នេះប្រព័ន្ធបោះឆ្នោតសភាជាន់ខ្ពស់ជប៉ុន មានលក្ខណៈខុសគ្នាទាំងស្រុងពីសភាជាន់ទាប ហើយអ្វីដែលលើកយកមកកត់សំគាល់នៅទីនេះ និងអាចថ្មីសម្រាប់កម្ពុជាយើង គឺប្រព័ន្ធសមាមាត្រនៃបញ្ជីបេក្ខជនគណបក្សបើកចំហរ (Open List)។ តើហេតុអ្វីបានជាប្រទេសជប៉ុនរៀបចំឲ្យមានប្រព័ន្ធបែបនេះឡើង?

មុនធ្វើការកែរទម្រង់ ឆ្នាំ២០០២ ព្រឹទ្ធសមាជិកជ្រើសតាំងចេញពីមណ្ឌលតំណាងសមាមត្រកំរិតជាតិ ដោយប្រើបញ្ជីគណបក្សបិទ (A Close Party Candidate List System) ។ ហេតុផល ផ្លូវការដែលប្តូរពីប្រព័ន្ធបិទទៅរកប្រព័ន្ធបើកចំហរនេះ មានហេតុផល៣ ។ ទីមួយប្រព័ន្ធបញ្ជីបើកចំហរអាចជម្រុញឲ្យអ្នកនយោបាយរត់ទៅបម្រើប្រជាពលរដ្ឋនៅកន្លែងដែលគេឈរឈ្មោះ ។ នេះបើកឱកាសឲ្យប្រជាពលរដ្ឋជប៉ុនលោកមានលទ្ធភាពស្គាល់មុខបេក្ខជនផ្ទាល់ ជៀសវាងគ្រាន់តែការដាក់បង្ហាញឈ្មោះតែក្នុងបញ្ជីបក្ស ។


ទីពីរ ប្រព័ន្ធបញ្ជីបើកចំហរ បំបែកចោលបុព្វសិទ្ធិលេខរៀងក្នុងបញ្ជីបក្ស និងធ្វើឲ្យងាយស្រួលសម្រាប់អ្នកបោះឆ្នោត និងបេក្ខជនឈរឈ្មោះឲ្យគេបោះឆ្នោត។ ទីបី ប្រព័ន្ធបញ្ជីបើកចំហរ នឹងនាំមកនូវប្រព័ន្ធបោះឆ្នោត មួយដែលមានលក្ខណៈខុសពីប្រព័ន្ធបោះឆ្នោតសម្រាប់សភាជាន់ទាបដែលប្រើប្រព័ន្ធបិទនោះ ។

ដូច្នេះ សម្រាប់ប្រជាពលរដ្ឋជប៉ុន ប្រព័ន្ធបញ្ជីបើកចំហរមានសារសំខាន់ ពីព្រោះបានផ្តល់ឲ្យពួកគេអាចធ្វើសេចក្តីសម្រេចក្នុងការជ្រើសតាំងនរណា ដែលអាចសមរម្យជាតំណាងរបស់ពួកគេ ។ សម្រាប់បេក្ខជនដែលឈរឈ្មោះក្នុងបញ្ជីបើកចំហរ ធ្វើឲ្យពួកគេមានអារម្មណ៍ឯករាជ្យភាពច្រើន ពីព្រោះពួកគេទទួលសន្លឹកឆ្នោតពុំមែនគ្រាន់តែដោយសារឈ្មោះគណបក្សរបស់ខ្លួន ប៉ុន្តែដោយសារកេរ្តិ៍ឈ្មោះប្រជាពលរដ្ឋស្រឡាញ់។


ប្រព័ន្ធបោះឆ្នោតជប៉ុន មិនដូចគ្នាជាមួយប្រព័ន្ធអាឡឺម៉ង់ទេ ទោះជាវាមានរូបភាពខ្លះ ប្រហាក់ប្រហែលនឹងគ្នាក៏ដោយចុះ ។ នៅក្នុងប្រព័ន្ធបោះឆ្នោតអាឡឺម៉ង់ អាសនៈនៅក្នុងមណ្ឌលឯកត្តនាមទាំងអស់ ត្រូវយកមកធ្វើសមាមាត្រជាមួយអាសនៈក្នុងមណ្ឌលតំណាងសមាមាត្រ "Together using system" ។

ការធ្វើសមាមាត្របញ្ចូលគ្នានេះ "Together using system" វាផ្ទុយពីប្រព័ន្ធជប៉ុនដែលអនុលោមតាមគោលការណ៍ "side-by-sides standing system" គឺមិនដាក់ការធ្វើសមាមាត្ររួមគ្នាទេ ប៉ុន្តែអាសនៈត្រូវបានបែងចែកដាច់ពីគ្នាទៅតាមប្រព័ន្ធនីមួយៗ ។

ប្រព័ន្ធត្រួតពិនិត្យគ្នាទៅវិញទៅមករវាងអំណាចទាំង៣នៅប្រទេសជប៉ុន



រចនាសម្ព័ន្ធស្ថាប័នធម្មនុញ្ញនៅប្រទេសជប៉ុន



Source: Cf. Hor Peng (see Diagram.1)

៥. ប្រព័ន្ធបោះឆ្នោតប្រទេសកម្ពុជា

ក- ប្រព័ន្ធបោះឆ្នោតតំណាងរាស្ត្ររដ្ឋសភា


ក្នុងមាត្រា៧៦នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងកំណត់ថា រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០រូប ហើយតំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសាកលដោយសេរីស្មើភាព និងតាមវិធីឆ្នោតជាសម្ងាត់ ។ មាត្រា ៥-២ នៃច្បាប់បោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភាចែងថា ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រខេត្តក្រុង ដោយយកខេត្តក្រុងជាមណ្ឌលបោះឆ្នោត ហើយមាត្រា ១១៨ ដាក់ការ

បែងចែកអាសនៈសម្រាប់គណបក្សនយោបាយនីមួយៗ ដោយគិតតាមចំនួនសន្លឹកឆ្នោតបានការក្នុងខេត្ត ក្រុងនោះតាមចំនួនមធ្យមភាគខ្ពស់បំផុត (Highest average formula/d՛ Hondt formula) ដោយផ្អែក តាមចំនួនអាសនៈក្នុងខេត្តក្រុងទាំងនោះ ។ នៅពេលបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភាម្តងៗ ប្រជា ពលរដ្ឋខ្មែរកម្ពុជាមានសន្លឹកឆ្នោតតែមួយសន្លឹក គួសជ្រើសរើសតែឈ្មោះគណបក្សមួយដែលខ្លួនពេញចិត្ត គឺពុំមែនបោះជ្រើសរើសបុគ្គលបេក្ខជនដោយផ្ទាល់ទេ ពីព្រោះកម្ពុជាយកប្រព័ន្ធ Propotional Preperation within a Close Party List System ។ នៅក្នុងប្រព័ន្ធនេះ ចំនួនអាសនៈ គឺត្រូវបានបែង ចែកទៅតាមខេត្តក្រុង សម្រាប់២៥មណ្ឌលខេត្តក្រុង ដោយគិតតាមចំនួនប្រជាពលរដ្ឋ (អាសនៈសម្រាប់ មណ្ឌលនីមួយៗ អាចមានពី១អាសនៈ ទៅដល់១២អាសនៈ) ហើយគណបក្សនយោបាយនីមួយៗ ត្រូវ ដាក់ស្នើឡើងនូវបញ្ជីរាយនាមបេក្ខជនឈរឈ្មោះតាមខេត្តក្រុង ជូនដល់គណកម្មការជាតិរៀបចំការបោះ ឆ្នោត។ ក្នុងច្បាប់បោះឆ្នោត មានកំណត់លក្ខខណ្ឌមួយចំនួន ដល់បេក្ខជននិងគណបក្សនយោបាយ សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ តើលក្ខខណ្ឌទាំងនេះមានអ្វីខ្លះ? តើការបែងចែក អាសនៈតាមមណ្ឌលខេត្តក្រុងនីមួយៗប្រព្រឹត្តិទៅយ៉ាងណា? (មាត្រាទី ៣៣-៣៨ ច្បាប់បោះឆ្នោត/ ឧបសម្ព័ន្ធស្តីពីប្រព័ន្ធបោះឆ្នោតនិងការបែងចែកអាសនៈ នៃបទបញ្ជានិងនីតិវិធីបោះឆ្នោតជ្រើសតាំង) ។

ខ- ប្រព័ន្ធបោះឆ្នោតសមាជិកព្រឹទ្ធសភា

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹង៣ក់កណ្តាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល និងនីតិ កាលមាន៦ឆ្នាំ ហើយនិងសមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និងជ្រើសតាំងដោយការបោះឆ្នោតអសកល ខ្លះ (មាត្រា ៩៩,១០២) ។ សមាជិកព្រឹទ្ធសភា ចំនួន២រូប ត្រូវចាត់តាំងដោយ ព្រះមហាក្សត្រ ២រូបទៀត ជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដោយប្រៀប និងសមាជិកព្រឹទ្ធសភានៅសល់ត្រូវជ្រើសតាំង ដោយការបោះឆ្នោតអសកល (មាត្រា ១០០) ។ នៅក្នុងច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ២០០៥ សមាជិកព្រឹទ្ធសភាដែលជ្រើសតាំងដោយការបោះឆ្នោតអសកល បច្ចុប្បន្នមាន ៥៧រូប -ត្រូវអនុ វត្តតាមប្រព័ន្ធសមាមាត្រ និងការបែងចែកអាសនៈតាមមណ្ឌលត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូច មានកំណត់ក្នុងមាត្រា១១៨ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសម្រាប់៨មណ្ឌលភូមិ ភាគ (មាត្រា ៨ និង ៩ ចបឆសជពក) ។ អ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់នៅក្នុងតំណែងក្នុងក្របខ័ណ្ឌនៃភូមិភាគរបស់ខ្លួននីមួយៗ ។

រចនាសម្ព័ន្ធស្ថាប័នធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣



Source: Hor Peng (see Diagtam-1)

ជំពូក៧

អំពីទ្រឹស្តីបកស្រាយគតិយុត្ត

(The Concepts of Legal Interpretation)

១- និយមន័យបកស្រាយគតិយុត្ត (Definition of Legal Interpretation)

ពាក្យថា Legal Interpretation ឬ Interpretation in Law ខ្មែរយើង អាចប្រែថា *ការបកស្រាយគតិយុត្ត ឬការបកស្រាយគតិច្បាប់* ។ មានទស្សនទានខ្វែងគ្នាជាច្រើនពីការបកស្រាយគតិយុត្តនេះ។ បើតាមលោក DWORKIN បានផ្តល់គំនិតអះអាងមួយចេញពីបទពិសោធន៍ជាក់ស្តែងថា ច្បាប់បានប្រព្រឹត្តទៅដោយការបកស្រាយដោយខ្លួនឯង (Law itself as an interpretative process) ។ តាមទស្សនទាននេះ ច្បាប់មិនចាំបាច់ធ្វើការបកស្រាយអ្វីទៀតទេ ពីព្រោះវាបានបកស្រាយដោយខ្លួនឯងហើយ។ ប៉ុន្តែលោក AHARON BARK, បានយល់ឃើញផ្សេងពីនេះ គឺថា គ្រប់អត្ថបទច្បាប់ទាំងអស់តម្រូវឲ្យមានការបកស្រាយ ពីព្រោះគេមិនអាចរកភាសា ពាក្យ ឬអក្សរ ដែលអាចផ្តល់អត្ថន័យនៅគ្រប់កាល:ទេស:បានទេ។ បើតាមទស្សនទាននេះ ច្បាប់ត្រូវការបកស្រាយទាំងអស់ ហើយការបកស្រាយគតិយុត្តបើតាមគាត់ គឺជាការធ្វើសនិទានកម្មសំដៅផ្តល់អត្ថន័យទៅលើអត្ថបទច្បាប់ (legal interpretion is a rational activity that gives meaning to a legal text) ។ ការធ្វើសនិទានកម្មលើគតិច្បាប់ សំដៅពន្លេចចេញឲ្យច្បាស់នូវធម្មនិយាមឬបទបញ្ញត្តិគតិយុត្តដែលចោទឡើងនៅក្នុងអត្ថបទច្បាប់។ ចំណែកក្រុមអ្នកទ្រឹស្តីច្បាប់ ដែលនិយមកណ្តាលបានឯកភាពថា ការបកស្រាយគតិយុត្តគួរ ឬអាចធ្វើបានតែលើច្បាប់ណា ឬបទបញ្ញត្តិណា ដែលមិនច្បាស់លាស់តែប៉ុណ្ណោះនៅពេលកើតមានឡើង ពីព្រោះន័យច្បាប់មិនច្បាស់លាស់ ធ្វើឲ្យមានការយល់ឃើញខុសៗគ្នា ឬអាចបង្កើតឲ្យមានវិវាទក្នុងខ្លឹមសារគតិយុត្តនៅក្នុងការអនុវត្តន៍ ។ ក្រុមអ្នកច្បាប់កណ្តាលនេះ បានទទួលស្គាល់ថា ការបកស្រាយគតិយុត្ត មិនមែនជាការប៉ុនប៉ងធ្វើច្បាប់ថ្មីទេ ប៉ុន្តែជាការកែតម្រូវឲ្យត្រូវស្របតាមស្មារតីឆន្ទ:ដើមរបស់ច្បាប់នូវអ្វីដែលក្រុមអ្នកតាក់តែងធ្វើច្បាប់នាសម័យនោះគេចង់បាន ។

ករណីមាត្រា៨២ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ដែលបានចែងថា *(រដ្ឋសភាបើកសម័យ ប្រជុំដំបូង ហុកសិបថ្ងៃ យ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ...)* ។ បទបញ្ញត្តិនេះ នៅក្នុងការអនុវត្ត បានបង្កនូវចំណោទគតិយុត្តមិនច្បាស់លាស់ នៅដើមនីតិកាលទី៣ នៃការបើកសម័យប្រជុំរដ្ឋសភាដំបូងថា តើព្រះមហាក្សត្រត្រូវយាងទៅបើកសម័យប្រជុំដំបូងដែរឬទេ? តើការប្រជុំសម័យដំបូងត្រូវកំណត់ក្បរ៉ុមប្រជុំដែរទេ? ចំណោទគតិយុត្តទាំងនេះ ត្រូវបានបំភ្លឺដោយក្រុមប្រឹក្សាធម្មនុញ្ញ ។32

ក្នុងសេចក្តីថ្វាយព្រះរាជយោបល់ ព្រះករុណាត្រូវយាងទៅបើកសម័យប្រជុំរដ្ឋសភាដំបូង ដោយឈរលើមូលដ្ឋាន តាមទម្លាប់ និងព្រះរាជវត្តមានរបស់ទ្រង់ មានសារៈសំខាន់ចំពោះប្រជាជាតិទាំងមូល និងចំពោះស្ថាប័នកំពូលរដ្ឋសភា។ ប៉ុន្តែពាក្យថាត្រូវយាងទៅ មិនមានន័យថាត្រូវតែទៅនោះទេ។ ក្នុងន័យនេះ ការយាងទៅបើកប្រជុំរដ្ឋសភាដំបូង ពុំមែនជាព្រះរាជកាតព្វកិច្ច ប៉ុន្តែជាព្រះរាជានុសិទ្ធិ។ នៅត្រង់ចំនុចនេះ ព្រះមហាក្សត្រ បានកំណត់នូវលក្ខខណ្ឌចាំបាច់ ព្រះអង្គទ្រង់យាងទៅលុះត្រាតែគណបក្សទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភាបានទៅចូលរួមទាំងអស់គ្នា ដោយឈរលើមូលដ្ឋាន ព្រះមហាក្សត្រទ្រង់ជានិមិត្តរូបឯកភាពជាតិ។ ដោយឡែក អំពីកូរ៉ុមប្រជុំរដ្ឋសភាដំបូង ក្រុមប្រឹក្សាធម្មនុញ្ញ បានថ្វាយព្រះរាជយោបល់ថា ការបើកប្រជុំដំបូងមិនចាំបាច់តម្រូវរាប់កូរ៉ុមទេ ប៉ុន្តែបន្ទាប់ពីនេះភ្លាម រាល់ការប្រជុំរដ្ឋសភាត្រូវប្រើ កូរ៉ុម។

ភាពចំរុងចំរៃនៃខ្លឹមសារគតិយុត្តនៃមាត្រា៨២នេះ ត្រូវបានដំរះបញ្ចប់ជាស្ថាពរ តាមច្បាប់វិសោធនកម្មស្តីពីច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្ររដ្ឋសភាឆ្នាំ២០១៤ ដោយកំណត់ថា គណបក្សណាដែលនៅតែបន្តមិនព្រមចូលរួមប្រជុំរដ្ឋសភា តាមការកោះហៅរបស់ព្រះមហាក្សត្រ ឬមិនព្រមចូលស្បថចូលកាន់តំណាង ត្រូវចាត់ទុកថាបានបោះបង់ចោលអាសនៈទាំងស្រុង ហើយគណកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបែងចែកអាសនៈជាថ្មីស្របតាមនីតិវិធីច្បាប់ជាធរមាន។

32 សេចក្តីថ្វាយយោបល់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ១៩/២០០៣ កបធ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៣ និង លេខ២០/២០០៣ កបធ ចុះថ្ងៃទី២២ នៃកញ្ញា ឆ្នាំ២០០៣ លើចំនុចផ្នែកច្បាប់មួយចំនួន៣ក់ព័ន្ធមាត្រា៨២នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ អានបន្ថែម តាំង រតនា អំណាចរដ្ឋធម្មនុញ្ញ និងព្រះមហាក្សត្រកម្ពុជា ក្នុងការយាងបើកសម័យប្រជុំដំបូងនៃរដ្ឋសភា (២០០៦)។

ជាគោលការណ៍ គេគប្បីត្រូវប្រុងប្រយ័ត្នលើការបកស្រាយបទបញ្ញាត្តិច្បាប់ ក្នុងករណីដែលច្បាប់ពុំបានកំណត់ ឬពុំមានចែងច្បាស់លាស់ ហើយការបកស្រាយ ដែលអាចទទួលយកបាន សមស្របតាមគោលការណ៍យុត្តិធម៌ ត្រូវឈរលើមូលដ្ឋានគតិយុត្ត ឬនីត្យានុកូលភាពនៃប្រភពគតិយុត្តជាក់លាក់ ។

មានសំណួរបឋមខ្លះៗត្រូវបានលើកមកជជែក ទី១ តើការព្យាយាមដោះស្រាយភាពផ្ទុយគ្នារវាងបទបញ្ញត្តិនានាក្នុងច្បាប់ណាមួយ អាចចាត់ទុកថា ជាការបកស្រាយគតិយុត្តដែរឬទេ? ទី២ ការព្យាយាមដោះស្រាយភាពផ្ទុយគ្នារវាងច្បាប់ពីរ ដែលមានឋានានុក្រមខុសគ្នា ឬដូចគ្នា អាចចាត់ទុកជាការបកស្រាយគតិយុត្តដែរ? ទី៣ តើការព្យាយាមដោះស្រាយបំពេញបន្ថែមនូវកង្វះខាតក្នុងច្បាប់ណាមួយ អាចចាត់ទុកថាជាការបកស្រាយគតិយុត្តដែរឬទេ? ទី៤ តើច្បាប់ដែលមានន័យច្បាស់លាស់ត្រូវការបកស្រាយដែរទេ?

២ .ន័យច្បាប់ និងន័យភាសាអក្សរ (Legal Meaning and Semantic Meaning)

ការបកស្រាយគតិយុត្តធ្វើឲ្យយើងដឹងបាននូវសារធម្មនិយាមរបស់ច្បាប់។ ន័យច្បាប់មានទំនាក់ទំនងជាប់គ្នាជាមួយន័យភាសា។ ដំណើរការបកស្រាយគតិយុត្ត គឺជាការដកស្រង់គតិច្បាប់ពីអត្ថន័យភាសា។

ចៅក្រមបកស្រាយភាសាមនុស្ស អក្សរទៅជាភាសាច្បាប់ និងប្រែច្បាប់ឋិតិវន្ត (Static Law) ទៅជាច្បាប់ថាមវន្ត (Dynamic Law) នេះគឺជាការប្រែពាក្យ និងប្រយោគក្នុងអត្ថបទច្បាប់ ឲ្យទៅជាធម្មនិយាមឬបទដ្ឋានច្បាប់ (A Legal Norm) ។ ដូច្នេះដើម្បីបកស្រាយច្បាប់ណាមួយ គេគួររុករកន័យច្បាប់ណាមួយដែលសមរម្យក្នុងចំណោមន័យពាក្យភាសា ។ អត្ថន័យភាសាកំណត់ សក្តានុពលភាព ឬទំហំទង្វើរបស់វាជាក់លាក់ ហើយគតិច្បាប់ស្រូបយកសក្តានុពលភាពនេះបញ្ចូលទៅក្នុងការអនុវត្តជាក់ស្តែង ។ ភាសាអក្សរអាចនៅពេលខ្លះស្រពេចស្រពិល និងពោរពេញដោយមហិច្ឆតា និងអាចបង្កើតឲ្យមានន័យច្រើនខុសគ្នា ប៉ុន្តែគេត្រូវដឹងថាការរុករកគតិច្បាប់ពីពាក្យ គប្បីឲ្យស្របនឹងគោលដៅរួមរបស់ច្បាប់ទាំងមូល ឬស្របទៅនឹងស្មារតីរបស់អ្នកអនុម័តច្បាប់នោះ ។ ក្នុងន័យនេះ ការបកស្រាយគតិយុត្តមានតួនាទីសំខាន់បំផុត ក្នុងសង្គមនីតិរដ្ឋ ។ អ្នកច្បាប់ ចៅក្រម មេធាវី បានព្យាយាមបង្កើតទ្រឹស្តី វិធីសាស្ត្រ និងគោលការណ៍ បកស្រាយគតិយុត្តសំខាន់ៗមួយចំនួន ប៉ុន្តែសព្វថ្ងៃនេះ គេនៅមិនទាន់មានការឯកភាពគ្នានៅឡើយ ។

៣-វិធីសាស្ត្រ និងគោលការណ៍ (System & Principle of Legal Interpretation)

វិធីសាស្ត្រ (ប្រព័ន្ធ) បកស្រាយគតិយុត្តមានច្រើន ហើយគេជ្រើសមកប្រើអាស្រ័យទៅតាមប្រព័ន្ធនីតិរបស់គេតម្រូវ ។ វិធីសាស្ត្របកស្រាយគតិយុត្ត (System of Legal Interpretation) និងគោលការណ៍បកស្រាយគតិយុត្ត (Principle of Legal Interpretation) គឺមិនដូចគ្នាទេ ។ វិធីសាស្ត្របកស្រាយ គតិយុត្តជាបទដ្ឋាន (Standards) ដែលអ្នកច្បាប់ប្រើសម្រាប់ធ្វើនិស្សារណកម្មគតិយុត្តពីទម្រង់មួយ របស់អត្ថន័យភាសា ។ គោលការណ៍បកស្រាយគតិយុត្ត គឺជាគោលការណ៍និស្សារណកម្ម (Priciple of Ectraction) ដែលបង្កើតចេញមកពីវិធីសាស្ត្របកស្រាយគតិយុត្តសម្រាប់កំណត់ខ្លឹមសារគតិយុត្ត ។ ម៉្យាងទៀតគោលការណ៍បកស្រាយគតិយុត្តក៏ជាផ្នែកមួយនៃវិធានវេយ្យសព្ទ័ភាសាកំណត់បានដែនគតិយុត្ត។

វិធីសាស្ត្របកស្រាយគតិយុត្តនីមួយៗ បង្កើតនូវគោលការណ៍បកស្រាយគតិយុត្តផ្ទាល់ខ្លួន និងអាចមានភាពខុសគ្នា ពីប្រព័ន្ធនីតិមួយទៅប្រព័ន្ធនីតិមួយទៀត។ វិធីសាស្ត្របកស្រាយគតិយុត្តនៅក្នុងប្រទេសប្រកាន់តាម Common Law អាចខុសគ្នា ពីប្រទេសប្រកាន់តាម Civil Law ។

តាមការស្រាវជ្រាវថ្មីៗមកនេះ វិធីសាស្ត្របកស្រាយគតិយុត្តមានច្រើនប្រភេទ ប៉ុន្តែនៅក្នុងជំពូកនេះយើង លើកយកមកធ្វើការសិក្សាពិភាក្សាវែកញែកតែបីប្រព័ន្ធប៉ុណ្ណោះ៖

១- វិធីសាស្ត្រអញ្ញថភាពនិយម (Subjective Method of Legal Interpretation)
២- វិធីសាស្ត្រយថភាពនិយម (Objective Method of Legal Interpretation)
៣- វិធីសាស្ត្រចេតនាភាពនិយម (Purposive Method of Legal Interpretation)

៤. ព្រំដែននៃការបកស្រាយ (The Limits of Legal Interpretation)

ការបកស្រាយគតិយុត្តមានដែនកំណត់ ពីព្រោះការបកស្រាយគតិយុត្ត ជាសនិទានកម្មទាញយកអត្ថន័យពីអត្ថបទច្បាប់។ ដូច្នេះហើយ ន័យភាសា ដែលប្រើប្រាស់ក្នុងអត្ថបទច្បាប់ ជាផ្នែកមួយនៃព្រំដែនកំណត់របស់វា ។ ភាសាអក្សរ អាចមានន័យច្រើនយ៉ាងតាមកាល:ទេស: ប៉ុន្តែមានព្រំដែនដូចស៊ុមរូបថត

មួយចឹង ហើយការបកស្រាយគតិយុត្ត ត្រូវផ្តល់ន័យទៅលើរូបភាពដែលនៅក្នុងស៊ុមរូបថតនោះ ថាតើរូបថតនោះ អាចជានរណា ។ អត្ថន័យច្បាប់ (Legal Text) កំរិតព្រំដែនបកស្រាយគតិយុត្តហើយ និងព្រំដែនភាសាកំរិតព្រំដែនអត្ថបទច្បាប់។ ការព្យាយាមធ្វើសនិទានកម្មណាក៏ដោយដែលសំដៅការផ្តល់អត្ថន័យទៅលើអត្ថបទច្បាប់ក្រៅពីអត្ថន័យភាសា ពុំមែនជាការបកស្រាយគតិយុត្តទេ ប៉ុន្តែជាទង្វើក្រៅការ បកស្រាយគតិយុត្ត ឬក្រៅច្បាប់ទៅវិញ (Non-Interpretive Doctrines or Non-Interpretativism) ។ ទ្រឹស្តី Non-Interpretativism ជាការធ្វើសនិទានកម្មសំដៅពន្លេចចេញនូវធម្មនិយាមក្រៅពីអត្ថន័យភាសា ផ្តល់ឲ្យអត្ថបទច្បាប់ (Non-interpretive doctrines operate beyond the language of the text)។

ការបកស្រាយគតិយុត្តដែលគ្មានដែនកំណត់ គឺច្បាប់នឹងក្លាយជាកម្មវត្ថុនៃបំណង ហើយផលវិបាករបស់វាច្បាប់អាចក្លាយជាឧបករណ៍នយោបាយ ។ ហេតុផលសំខាន់ក្នុងព្រំដែនបកស្រាយគតិយុត្ត ម៉្យាងអាចឲ្យយើងកំណត់បាននីត្យានុកូលភាពនៃទង្វើបកស្រាយគតិយុត្ត និងម៉្យាងទៀតអាចឲ្យយើងកំណត់បានពីភាពខុសគ្នារវាងទ្រឹស្តី Interpretation និងទ្រឹស្តី Non-Interpretation ។ ប៉ុន្តែនៅកាលៈទេសៈពិសេសខ្លះ ចៅក្រមអាចព្យាយាមប្រើបានទ្រឹស្តីទាំងពីរ ។

៥- បញ្ហាប្រឈម (Basic Problems in Legal Interpretation)

ចំណោទសំខាន់ៗថា តើវិធានគតិយុត្តមួយដែលមានលក្ខណៈទូទៅ (A General Rule) មានន័យយ៉ាងណាក្នុងស្ថានភាពកាលៈទេសៈពិសេសជាក់ស្តែងណាមួយនោះ (Specific Factual Situation)?

ឧទាហរណ៍១ ច្បាប់កូមិបាលមាត្រា៣៨: *"ដើម្បីក្លាយជាកម្មសិទ្ធិលើអចលនវត្ថុបានលុះត្រា តែភោគៈត្រូវកាន់កាប់<u>ដោយពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត</u> ។..."* ឧបមាថា ពាក្យគតិយុត្តទាំងនេះ ពុំមានការបកស្រាយនៅក្នុងច្បាប់កូមិបាលនោះទេ ឧបមាថា អ្នកជាចៅក្រម ឬជាមេធាវី តើអ្នកបកស្រាយវាយ៉ាងណាដើម្បីកំណត់សិទ្ធិកាន់កាប់?

ឧទាហរណ៍២ នៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ មាត្រា៧៣: " *ដើម្បីផលប្រយោជន៍របស់កូន ការឲ្យភាគីណាមួយរក្សាកូន ត្រូវសម្រេចតាមការយល់ព្រមនៃប្តីប្រពន្ធដែលលែងលះគ្នានោះ ។ តាមគោលការណ៍ កូនដែលនៅបំបៅដោះត្រូវឲ្យទៅម្តាយរក្សា ។ ក្នុងករណីដែលគូភាគីទាំងសងខាង មិន ឯកភាពគ្នាលើការរក្សាកូន តុលាការប្រជាជនត្រូវសម្រេច ។* " ពាក្យថា "ផលប្រយោជន៍របស់កូន" គឺជា លក្ខខ័ណ្ឌមួយដ៏សំខាន់ សម្រាប់តុលាការពិបញ្ហាថែរក្សាកូន ។ ឧបមាថា អ្នកជាចៅក្រម ឬ មេធាវី តើអ្នក កំណត់អត្ថន័យ " ផលប្រយោជន៍របស់កូន " យ៉ាងដូចម្តេច?

នេះជាបញ្ហាប្រឈម ដែលអ្នកបកស្រាយគតិយុត្តត្រូវបង្ខំចិត្តស្វែងរកប្រភពគតិយុត្តផ្សេង ពីអត្ថបទច្បាប់ដើម្បីយល់ន័យទាំងនោះឲ្យបានស៊ីជម្រៅ ហើយតម្រូវឲ្យធ្វើការពិចារណាស្រាវជ្រាវបន្ថែម លើទម្រង់ (Form of Text) និងខ្លឹមសារ (Substance of Text) ក្នុងអត្ថបទច្បាប់នោះ ។ អ្នកបកស្រាយគតិយុត្តត្រូវពិនិត្យផ្តោតលើទម្រង់និងខ្លឹមសារគតិយុត្តព្រមគ្នា ពីព្រោះទម្រង់កំណត់ឲ្យភាពភ្លៀវភ្លាំនៃខ្លឹមសារ ហើយខ្លឹមសារកំណត់ឲ្យភាពជាក់លាក់នៃទម្រង់។ ដើម្បីយល់ច្បាប់ឲ្យកាន់តែស៊ីជម្រៅ គឺតម្រូវដោយមិនគ្រាន់តែយល់អត្ថន័យគតិយុត្ត ប៉ុន្តែត្រូវយល់ពីអំណាចគតិយុត្តទៀតផង។ សំណួរគឺថា តើទម្រង់គតិយុត្តគ្រប់គ្រងលើខ្លឹមសារគតិយុត្តយ៉ាងណា? ហើយខ្លឹមសារគ្រប់គ្រងទម្រង់យ៉ាងណា? ដើម្បីអាចស្រាយចំណោទនេះបាន អ្នកបកស្រាយគតិយុត្ត គួរគម្លឹត្រូវព្យាយាមពិនិត្យលើចំណោទគតិយុត្តសំខាន់បី:

ទី១ តើខ្លឹមសារគតិយុត្តអ្វីដែលផ្តល់អត្ថន័យទៅឲ្យទម្រង់គតិយុត្តនោះ? (What is the legal substance that gives meaning to the legal form?) ឧទាហរណ៍ តើការបកស្រាយច្បាប់រដ្ឋធម្មនុញ្ញត្រូវផ្អែកលើឆន្ទៈ និងបំណងដើមរបស់អ្នកធ្វើច្បាប់រដ្ឋធម្មនុញ្ញ ឬត្រូវផ្អែកលើតម្លៃជាក់ស្តែងនៃសង្គម? (Do we interpret a constitution according to the intent of the framers, or according to the modern values?) ។ តើការបកស្រាយច្បាប់រដ្ឋសភា ត្រូវផ្អែកលើឆន្ទៈ និងបំណងដើមរបស់អ្នកតំណាងរាស្ត្រ ឬត្រូវផ្អែកលើតម្រូវការជាក់ស្តែងរបស់សង្គមវិញ? (Do we interpret the statute according to the intent of the legistators, or according to contemporary needs?) ។ តើការបក ស្រាយកិច្ចសន្យា ត្រូវផ្អែកលើឆន្ទៈ និងបំណងដើមរួមនៃអ្នកធ្វើកិច្ចសន្យា ឬត្រូវផ្អែកលើបំណងសមស្រប របស់កិច្ច

សន្យានោះ? (Do we interpret a contract according to the join intent of the parties, or according to its reasonable goal?) ។ តើការបកស្រាយសំបុត្របណ្តាំមតកសាសន៍ណាមួយ ត្រូវផ្អែកលើបំណងដើមរបស់អ្នកម្ចាស់បណ្តាំ ឬផ្អែកលើធម្មនិយាមរបស់ប្រព័ន្ធគតិយុត្តនោះ? (Do we interpret a will according to intent of the testator, or according to the objective values of the legal system?) ។

ទី២ តើគោលបំណងរបស់អ្នកតាក់តែងច្បាប់ ជាប្រភពឲ្យយល់ដឹងគតិច្បាប់ ពីពួកគេបានបង្កើតឬ?
<u>មតិទី១</u> ឆន្ទៈដើមរបស់អ្នកធ្វើច្បាប់ចេញពីប្រវត្តិតាក់តែងច្បាប់-ទ្រឹស្តីឆន្ទៈនិយម ។ ទ្រឹស្តីឆន្ទៈនិយម (Will Theory) តម្រូវឲ្យពិចារណារកឆន្ទៈពិតរបស់អ្នកនិពន្ធច្បាប់តាមប្រវត្តិតាក់តែងច្បាប់ និងអនុញ្ញាតិឲ្យអ្នកបកស្រាយគតិយុត្ត អាចរុករកប្រភពក្រៅពីអត្ថបទច្បាប់ថែមទៀតផង ។ ទ្រឹស្តីនេះសំអាងថា ភាសា-អក្សរគួរតែបកស្រាយផ្អែកលើឆន្ទៈដើមរបស់អ្នកសរសេរច្បាប់នោះ ។

<u>មតិទី២</u> ឆន្ទៈដើមអ្នកធ្វើច្បាប់ស្ថិតនៅតែលើឆន្ទៈដែលបានសំដែងក្នុងអត្ថបទច្បាប់តែប៉ុណ្ណោះ-ទ្រឹស្តីវិញ្ញត្តិនិយម ។ ទ្រឹស្តីវិញ្ញត្តិនិយម (Expression Theory) ពុំផ្តោតសំខាន់លើបំណងអ្នកតាក់ តែងច្បាប់នោះទេ ប៉ុន្តែផ្តោតសំខាន់លើអ្វីដែលអត្ថបទច្បាប់បានចែងជាក់ស្តែង (The question is not what the text's author wanted, but rather what the text says) ។ ទ្រឹស្តីនេះព្យាយាម ដោះស្រាយជាមួយកាលៈទេសៈជាក់ស្តែង ក្នុងពេលដែលនិយាមគតិយុត្ត ក្នុងអត្ថន័យច្បាប់ណាមួយមិន ច្បាស់លាស់ ។ មួយវិញទៀតទ្រឹស្តីវិញ្ញត្តិនិយមបានអនុញ្ញាតឲ្យអ្នកបកស្រាយគតិយុត្តពិនិត្យលើប្រភពអត្ថបទច្បាប់ផ្សេងៗបានតែលើច្បាប់អនុម័តដោយសភាក្នុងនីតិកាលដូចគ្នា ។

ទី៣ តើអ្វីជាកម្មវត្ថុរបស់ខ្លឹមសារគតិច្បាប់? តើត្រូវកំណត់វាដូចម្តេច? តើអ្វីជាតម្លៃជាសារប្រយោជន៍និងជាកម្មបំណងនៃអត្ថបទគតិយុត្ត ដែលនឹងត្រូវធ្វើការបកស្រាយនោះ?

ជំពូក៨

ទ្រឹស្តី និងវិធីសាស្ត្របកស្រាយគតិយុត្ត

(Doctrines and System of Interpretation in Law)

១ .ទ្រឹស្តីបកស្រាយគតិយុត្ត (Doctrines of Interpretation in Law)

លោកសាស្ត្រាចារ្យ Aharons Barak បានបែងចែកគោលការណ៍បកស្រាយគតិយុត្តជាពីរ គោលការណ៍ទូទៅ (Ordinary Interpretive Doctrines in Law) និងគោលការណ៍ពិសេស (Special Interpretive Doctrines in Law) ។ ទ្រឹស្តីបកស្រាយគតិយុត្តទូទៅ ត្រូវរុករកគតិយុត្ត ឬគតិច្បាប់តែក្នុងអត្ថបទច្បាប់ (It operate within the language of the legal text) ។ ទ្រឹស្តីនេះ តម្រូវឲ្យអ្នក បកស្រាយធ្វើសនិទានកម្មគតិយុត្តផ្តល់ន័យទៅឲ្យគតិច្បាប់តែក្នុងអត្ថបទច្បាប់មានចែងប៉ុណ្ណោះ។ ព្រំដែន របស់វាផ្សាភ្ជាប់ជាមួយន័យភាសាក្នុងអត្ថបទច្បាប់។ ទ្រឹស្តីនេះមិនអនុញ្ញាតឲ្យចៅក្រម ឬ អ្នកបកស្រាយគតិយុត្ត អាចកែប្រែពាក្យ ឬបំពេញបន្ថែមទៅលើគតិយុត្ត ឬគតិច្បាប់ដែលមានរួចមកហើយនោះ បានឡើយ ពីព្រោះធ្វើបែបនេះមានន័យថា ចៅក្រមធ្វើច្បាប់ដែលទ្រឹស្តីនេះចាត់ថាជាការបំពានអំណាចលើគោលការណ៍បែងចែកអំណាច (the Principle of Separation of Powers) ឬបំពានលើគោលការណ៍ស្វ័យភាពឆន្ទៈបុគ្គល (Autonomy of Private Will) ។ ក្នុងន័យនេះ បុព្វសិទ្ធតុលាការមានកំរិតជាក់លាក់ គឺមិនបង្កើតច្បាប់ថ្មី ប៉ុន្តែត្រឹមតែបញ្ជាបង្ខំច្បាប់ដែលមានស្រាប់ ។

ដូច្នេះ បើក្នុងករណីមានការធ្វើសនិទានកម្មគតិយុត្ត ឬគតិច្បាប់ក្នុងអត្ថបទច្បាប់ណាមួយក្រៅពីន័យភាសាដែលពុំមានចែងក្នុងអត្ថបទច្បាប់នោះទេ នោះពុំមែនជាទ្រឹស្តីបកស្រាយគតិយុត្តទូទៅឡើយ ប៉ុន្តែគេចាត់ទុកវាជាករណីពិសេសមួយ និងត្រូវប្រើគោលការណ៍ពិសេស ទ្រឹស្តីពិសេស (Specail Interpretive Doctrine in Law) ។ ទ្រឹស្តីបកស្រាយគតិយុត្តពិសេស អាចរុករកនិយាមគតិយុត្ត ឬគតិច្បាប់ក្រៅពី ន័យភាសាក្នុងអត្ថបទច្បាប់ ដើម្បីជាមធ្យោបាយបន្ថែមក្នុងការដោះស្រាយក្នុងវិវាទគតិច្បាប់ (It operate beyond the language of the legal text) ។ ទ្រឹស្តីនេះកើតឡើងឈរលើមូលដ្ឋានដែលថា ចៅក្រមមាន

អំណាចចន្ទានុសិទ្ធតុលាការ ពិសេសក្នុងការសម្រេចលើវិវាទគតិយុត្តដែលពិបាកៗ ។ ក្នុងន័យនេះចៅក្រមបានបង្កើតច្បាប់ថ្មី។ ពិតណាស់ ទ្រឹស្តីនេះមានភាពចម្រូងចម្រៃបន្តិចមែន ប៉ុន្តែវាមានសារៈសំខាន់ទាំងក្នុងការអនុវត្ត ទាំងក្នុងទ្រឹស្តី ។ ទោះជាយ៉ាងណាក៏នៅក្នុងការអនុវត្តជាក់ស្តែង តុលាការក្នុងប្រទេសភាគច្រើនទាំងប្រទេសប្រកាន់ Civil Law System ទាំងប្រទេសប្រកាន់ Common Law System គេជៀសវាងវា ឲ្យនៅតិចបំផុត ហើយបើករណីនេះត្រូវបានយកមកប្រើ ចៅក្រមត្រូវបកស្រាយផ្អែកលើទ្រឹស្តីទូទៅគតិយុត្ត ឬតាមធម្មនិយាមសង្គមជាក់ស្តែង ឬតាមគោលការណ៍ធម្មនុញ្ញភាពដែលមានជាធរមាន មិនមែនតាមឆន្ទៈផ្ទាល់ខ្លួនរបស់ចៅក្រមនោះទេ។ នីត្យានុកូលភាពនៃការប្រើទ្រឹស្តី អាស្រ័យទម្លាប់ប្រព័ន្ធនីតិនីមួយៗ ។


ប្រទេសប្រកាន់ប្រព័ន្ធច្បាប់ Civil Law ឬ Roman Law ចៅក្រមមានឆន្ទានុសិទ្ធតិចតួចណាស់ ក្នុងការប្រើទ្រឹស្តីពិសេស ដោយសារគេត្រូវគោរពគោលការណ៍ភាពជាក់លាក់នៃក្រមសរសេរ (The Principle of Legislative Certainty) និងគោរពយ៉ាងខ្ជាប់ខ្ជួនបំផុត លើគោលការណ៍បែងចែកអំណាច (The Principle of Separation of Power) ។ ចេញពីគោលការណ៍ទាំងនេះ បានជាសេចក្តីសម្រេចរបស់តុលាការ ក្នុងគ្រប់រឿងវិវាទទាំងអស់ មានអំណាចអាជ្ញាតែលើរឿក្តីតែមួយនោះតែបុណ្ណោះ ពោលគឺមិនអាចនឹងយកមកធ្វើជាគោលការណ៍ដោះស្រាយរឿងក្តីក្រោយៗ ដែលមានអង្គហេតុប្រហាក់ប្រហែលគ្នាបាននោះទេ ។ ចំណែកប្រទេសប្រកាន់ប្រព័ន្ធច្បាប់ Common Law ចៅក្រមមានអំណាចទូលំទូលាយក្នុងការបកប្រើទ្រឹស្តីគតិយុត្តពិសេស ដោយសារមានគោលការណ៍ *(Jusicial Doctrine of Stare Decisis)* ។ សេចក្តីសម្រេចរបស់តុលាការ គឺជាច្បាប់ដែលមានអនុភាពអាជ្ញាគតិយុត្ត មិនគ្រាន់តែក្នុងរឿងក្តីដែលខ្លួនបានសម្រេចនោះទេ ប៉ុន្តែក្លាយជាប្រភពអំណាចអាជ្ញាដល់រឿងក្តីក្រោយៗ ដែលមានអង្គហេតុប្រហាក់ប្រហែលគ្នានោះទៀតផង។ ជាការពិតច្បាប់អនុម័តដោយរដ្ឋសភា ជាគោលការណ៍មានឋានានុក្រមធំជាងប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង សេចក្តីសម្រេចលើសំណុំរឿងរបស់តុលាការ (Jusicial Precedent) មានកំលាំងអំណាចគតិយុត្តលើក្រម ដោយសារថា វាត្រូវបានចៅក្រមបង្កើត ចេញមកពីវិវាទជាក់ស្តែង ។

ប៉ុន្តែនៅប្រទេសខ្លះ ច្បាប់របស់គេមានសរសេរច្បាស់តែម្តង តើនៅពេលណាដែលចៅក្រមអាចប្រើទ្រឹស្តីនេះបាន។ ប្រទេសកម្ពុជា យើងឃើញមានច្បាប់មួយចំនួន ចែងបញ្ជាក់ពីករណីដែលអាចប្រើទ្រឹស្តី

នេះបាន ជាពិសេសសម្រាប់ការបកស្រាយ លើកិច្ចសន្យាពាណិជ្ជកម្មទាំងឡាយណាដែលមិនច្បាស់លាស់ (នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ មាត្រា១០ ជាដើម) ។

ទ្រឹស្តីបកស្រាយគតិយុត្តទូទៅផ្តល់នយលើចំណោទគតិយុត្ត "តើវាមាននយដូចម្តេច?" ចំណែកទ្រឹស្តីបកស្រាយគតិយុត្តពិសេសបន្ថែមពី "តើវាមាននយដូចម្តេច?" និង "តើវាមិនមាននយដូចម្តេច?" ។ ដូច្នេះនៅក្នុងការអនុវត្តជាក់ស្តែង ដើម្បីអាចប្រើប្រាស់ទ្រឹស្តីបកស្រាយគតិយុត្តពិសេសបាន ចៅក្រមត្រូវប្រើទ្រឹស្តីទូទៅជាមុនសិន ។ ទ្រឹស្តីបកស្រាយគតិយុត្តពិសេស "ឬតាមនយទូលាយ" អាចអនុញ្ញាតឲ្យចៅក្រម ១-បំពេញបន្ថែមចន្លោះខ្វះខាតក្នុងគតិយុត្ត ឬគតិច្បាប់, ២-ដោះស្រាយលើភាពផ្ទុយគ្នានៃគតិច្បាប់ពីរ, ៣-កែតម្រូវកំហុសក្នុងអត្ថបទច្បាប់, និង៤-ផ្លាស់ប្តូរពាក្យភាសាដើម្បីបង្ការមិនឲ្យមានភាពមិនសមរម្យលើខ្លឹមសារគតិយុត្ត ។ ចំណុចនេះ សូមបញ្ជាក់បន្តិច ទ្រឹស្តីបកស្រាយគតិយុត្ត (ទូទៅ/ពិសេស) របៀបប្រើវា ត្រូវចេញពីនិយាមទូទៅសិន ទើបទៅនិយាមពិសេសបាន។ ប៉ុន្តែសូមកុំប្រឡំជាមួយគោលការណ៍ក្នុងច្បាប់ទូទៅ (ក្រមរដ្ឋប្បវេណី) និងគោលការណ៍ក្នុងច្បាប់ពិសេស (ច្បាប់ពាណិជ្ជកម្ម) កាលណានៅពេលមានវិវាទពាណិជ្ជកម្ម ចៅក្រម ឬមេធាវី គេត្រូវប្រើគោលការណ៍ក្នុងច្បាប់ពាណិជ្ជកម្មមុន ពីព្រោះគេត្រូវគោរពទៅតាមគោលការណ៍នៃច្បាប់ពិសេស មានអំណាចអាជ្ញាលើគោលការណ៍ក្នុងច្បាប់ទូទៅ។

<u>ទំនាក់ទំនងរវាងទ្រឹស្តីបកស្រាយគតិយុត្តទូទៅ និងទ្រឹស្តីបកស្រាយគតិយុត្តពិសេស</u>



កម្ពុជា ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ និងសម្រេចក្តីក្នុងវិវាទបោះឆ្នោត ។ អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ (រដ្ឋប្បវេណី ព្រហ្មទ័ណ្ឌ រដ្ឋបាល) ។ ដូចនេះ ការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ជាអំណាចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ ការបកស្រាយច្បាប់ ឬ កិច្ចសន្យា ឬ លិខិតបណ្តាំមរតក ក្រោមយុត្តាធិការវិវាទរឿងក្តី ជាសិទ្ធិអំណាចរបស់តុលាការគ្រប់លំដាប់ថ្នាក់ វៀងលែងតែមានករណីចំណោទធម្មនុញ្ញភាពនៃច្បាប់ ភាគីនៃរឿងក្តីនោះអាចស្នើសុំទៅក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់តាមរយៈប្រធានតុលាការកំពូល។

នៅក្នុងយន្តការការបកស្រាយគតិយុត្ត បើតាមការសិក្សាលើយុត្តិសាស្ត្រកន្លងមក ក្រុមប្រឹក្សាធម្មនុញ្ញ កម្ពុជា បានប្រើប្រាស់ទ្រឹស្តីបកស្រាយគតិយុត្តទាំងពីរ ទ្រឹស្តីទូទៅ ឬ ទ្រឹស្តីពិសេស ទៅតាមករណីចាំបាច់។

២-វិធីសាស្ត្របកស្រាយ (System of Interpretation in Law)

ច្បាប់ជាសំណុំវិធានគតិយុត្តបង្កើតឡើងដោយមនុស្ស ដូច្នេះច្បាប់ត្រូវតែបកស្រាយដោយមនុស្ស។ វិធីសាស្ត្របកស្រាយគតិយុត្ត ជាបច្ចេកទេស (វិធី/បទដ្ឋាន) ដែលអ្នកបកស្រាយគតិយុត្តប្រើសម្រាប់ធ្វើនិស្សារណកម្មគតិយុត្តពីទម្រង់ន័យភាសាក្នុងអត្ថបទច្បាប់ ។ នៅក្នុងសង្គមនីតិរដ្ឋ វិធីសាស្ត្របកស្រាយគតិយុត្តឆ្លើយតបទៅនឹងតួនាទីរបស់ច្បាប់ តួនាទីរបស់ចៅក្រម ទំនាកទំនងជាមួយស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ និងឆន្ទៈបុគ្គលក្នុងប្រព័ន្ធគតិយុត្តនោះ ។ បច្ចុប្បន្នភាពនេះ មានវិធី សាស្ត្របកស្រាយគតិយុត្តច្រើនយ៉ាង ប៉ុន្តែក្នុងជំពូកនេះសូមលើកយកមកសិក្សាតែបីទេដែលនិយមប្រើ។


២.១ .វិធីសាស្ត្រអញ្ញូថភាពនិយម) ឆន្ទៈដើម/Intentionalism)

(Subjective System of Interpretation in Law: Intentionalism)

១-មូលដ្ឋានប្រភពគតិយុត្តនៃវិធីសាស្ត្រនេះ ផ្តោតសំខាន់លើឆន្ទៈដើម ឬបំណងដើមរបស់អ្នកធ្វើច្បាប់ (Intentionalism) ។ វាតម្រូវឲ្យអ្នកបកស្រាយគតិយុត្ត ត្រូវតែគោរព និងអនុវត្តតាមឆន្ទៈដើមរបស់អ្នកធ្វើច្បាប់ដោយត្រូវចាប់ផ្តើមចេញពីន័យភាសាក្នុងអត្ថបទច្បាប់ហើយនឹងត្រូវបញ្ចប់នៅត្រឹមបំណងដើមរបស់អ្នកធ្វើច្បាប់ ។ នេះមានន័យថា អ្នកតាក់តែងធ្វើច្បាប់ និងអ្នកបកស្រាយគតិយុត្ត ត្រូវស្ថិតលើដង ផ្លូវ

តែមួយ ប៉ុន្តែគ្រាន់តែស្ថិតលើទិសដៅផ្ទុយគ្នាតែប៉ុណ្ណោះ ។ អ្នកបកស្រាយគតិយុត្តដែលប្រកាន់តាមវិធីសាស្ត្រនេះ តម្រូវរុករកអត្ថន័យគតិយុត្តក្នុងអត្ថបទច្បាប់ឲ្យដូចគ្នានៅពេលដែលច្បាប់នោះបានតាក់តែងដោយមិនខ្វល់ពីភាពជាក់ស្តែងក្នុងបច្ចុប្បន្នភាពនោះទេ ពីព្រោះឆន្ទៈដើមរបស់គតិយុត្ត គឺមានចេរភាព និងមិនអាចប្រែប្រួលតាមពេលវេលាបានទេដរាបណា មិនមានការធ្វើវិសោធនកម្មបន្ថែមទៀតនោះ ។ ដូច្នេះ Intentionalism ជាគ្រឹះគតិយុត្តពីកំណើត ។

២-វិធីសាស្ត្រអញ្ចឹចភាពនិយមនេះបង្កើតឲ្យមានគោលការណ៍គតិយុត្តមួយចំនួន ។ ទីមួយ តើត្រូវមានគោលការណ៍បែបណាដើម្បីកំណត់រកឆន្ទៈដើមរបស់អ្នកធ្វើច្បាប់នោះ? (Relate to the way for characterizing subject intent) ។ តើគេត្រូវតែទទួលស្គាល់តែឆន្ទៈដើមដែលមានភាពជាក់លាក់ ឬ ត្រូវទទួលស្គាល់ឆន្ទៈដើមដែលមានលក្ខណៈទូទៅ? (Relate to the way for realizing the intent of the text's author: concrete or general intent) ។ ទីពីរ តើគេត្រូវមានគោលការណ៍បែបណា ដើម្បីកំណត់នីត្យានុកូលភាពនៃប្រភពគតិយុត្ត (The way concretes the sources) ។ ប្រសិនបើ ពាក្យក្នុងអត្ថបទច្បាប់មិនច្បាស់ ឬមានមហិច្ឆតា តើចៅក្រមអាចសិក្សាប្រភពគតិយុត្តក្រៅពីអត្ថបទច្បាប់ ដែរឬទេ? ទីបី តើគេត្រូវមានគោលការណ៍បែបណា ទាក់ទងទៅនឹងពេលវេលា (Relate to the time of sources) ។ ជាទូទៅ ចៅក្រមស្រាវជ្រាវរុករកឆន្ទៈដើមរបស់អ្នកតាក់តែងច្បាប់តាមរយៈប្រភពពីរ (១) ដកស្រង់ចេញពីអត្ថបទច្បាប់ខ្លួនឯងតែម្តង (From internal text itself) និង (២) អាចដកស្រង់ប្រភពក្រៅពីអត្ថបទច្បាប់នោះបន្ថែមទៀត (From external to the text) ។




៣- តើបច្ចុប្បន្នភាពនេះ អ្នកបកស្រាយគតិយុត្តនៅកម្ពុជាបានប្រើវិធីសាស្ត្រនេះឬទេ? ក្រុមប្រឹក្សាធម្មនុញ្ញពេលខ្លះធ្លាប់យកមកប្រើផងដែរ ដូចជាក្នុងសំណុំរឿងលេខ ០៨៣-០០៦-២០០៤ ។

២.២ .**វិធីសាស្ត្រយថភាពនិយម (អត្ថបទនិយម/អក្សរនិយម)**

(Objective System of Interpretation in Law: Textualism)

មូលដ្ឋានប្រភពគតិយុត្តនៃវិធីសាស្ត្រយថភាពនិយម សំខាន់លើខ្លឹមសារជាក់ស្តែងក្នុងអត្ថបទច្បាប់ (Textualism) ។ វិធីសាស្ត្រមិនផ្តោតសំខាន់ទៅលើបំណងដើមពិតរបស់អ្នកធ្វើច្បាប់ (Intentionalism) ទេ ពីព្រោះគេសំអាងថា អ្នកតាក់តែងច្បាប់បានផ្ទេរឆន្ទៈពិតរបស់គេ បញ្ចូលទៅក្នុងច្បាប់តាមរយៈភាសាបានចប់សព្វគ្រប់អស់ហើយ ហើយនិងក្នុងន័យនេះ ឆន្ទៈដើមពិតរបស់អ្នកធ្វើច្បាប់គឺចប់ ត្រឹមន័យភាសា ។


ដូច្នេះវិធីសាស្ត្រនេះ មិនតម្រូវឲ្យគិតត្រឡប់ទៅរកអ្វីដែលបានគិតទុកពីអតីតកាលនោះទេ ប៉ុន្តែត្រូវគិតរុករកនូវអ្វីដែលមិនទាន់បានគិតទុកជាមុន។ វាមិនមែនរុករកឆន្ទៈដើមពិត (True Intent) របស់អ្នកតាក់តែងច្បាប់ទេ ប៉ុន្តែត្រូវរៀបចំរុករកឆន្ទៈពីសម្មតិកម្មមកវិញ (Hypothetical Intent) ។ បើតាម វិធីសាស្ត្រនេះ នៅពេលដែលច្បាប់បានអនុម័ត និងដាក់ឲ្យប្រើប្រាស់នោះ វាបង្កើតគន្លងផ្លូវដើរផ្ទាល់ខ្លួន គឺ ដូចគ្នានឹងគ្រាប់កាំភ្លើងបានបាញ់ចេញពីកាណុង ។ ជាតុសំខាន់នៃវិធីសាស្ត្រយថភាពនិយមគឺឈរនិងផ្តោតលើអត្ថបទច្បាប់ទាំងស្រុង Textualism ។



២.៣. វិធីសាស្ត្រចេតនាភាពនិយម (ឆន្ទៈដើមនិយម/អត្ថបទដើមនិយម)

(Purposive Sysetem of Interpretation in Law: Intentionalism and Textualism)

វិធីសាស្ត្រចេតនាភាពនិយមជាសំយោគកម្ម រវាងវិធីសាស្ត្រអញ្ញថភាពនិយម និងវិធីសាស្ត្រយថភាពនិយម ។ មូលដ្ឋានប្រភពគតិយុត្តរបស់វា ឈរជាសំខាន់លើគោលការណ៍ Intentionalism និង គោលការណ៍ Textualism ដើម្បីបង្កើតលិទ្ធផលតាម Pragmatism និង Synthesis ។



ជំពូក៩

គោលការណ៍បកស្រាយទម្រង់គតិយុត្ត


នៃមរតកសាសន៍ និងកិច្ចសន្យា

នៅក្នុងវិធីសាស្ត្រទាំងបីដែលបានសិក្សាកន្លងមក គេបានពិនិត្យឃើញ វិធីសាស្ត្រអញ្ចថភាពនិយម (Subjectivism within Intentionalism) និងវិធីសាស្ត្រយថភាពនិយម (Objectivism within Textualism) មាននិន្នាការនិយមជ្រុល និងបាននាំមកនូវវិបត្តិលើគុណភាពយុត្តិធម៌ និងបណ្តាលឲ្យមានការរិះគន់ខ្លាំងៗ ពីអ្នកនិយមកណ្តាល ដែលគាំទ្រវិធីសាស្ត្រចេតនាភាពនិយម ។ វិធីសាស្ត្រចេតនាភាពនិយម (Textualism and Intentionalism) ត្រូវបានគេមើលឃើញថាជាវិធីសាស្ត្រសម្របសម្រួលមួយផ្តល់ឲ្យមានភាពកាន់ តែប្រសើរលើគុណភាពយុត្តិធម៌តាមវិធានគតិយុត្ត។ ចៅក្រមនៅប្រទេស ប្រជាធិបតេយ្យធំៗ មួយចំនួន ប្រទេសប្រកាន់ Common Law និង Civil Law បានអនុវត្តវិធីសាស្ត្រនេះ ក្នុងប្រព័ន្ធគតិយុត្តរបស់គេយ៉ាងទូលំទូលាយ ដូចជានៅប្រទេសអង់គ្លេស ប្រទេសអាឡឺម៉ង់ ប្រទេស កាណាដា ប្រទេសអូស្ត្រាលី ។ តែទោះជាយ៉ាងណាក៏ដោយ នៅប្រទេសមួយចំនួនពុំមានអនុវត្តទេ។ ដោយឡែកនៅជំពូកនេះ ខ្ញុំលើកយកវិធីសាស្ត្រចេតនាភាពនិយម អនុវត្តនៅក្នុងទម្រង់គតិយុត្តឯកជន ។

១-គោលការណ៍បកស្រាយមតកសាសន៍ (Legal Interpretation of Will)


ក្រមរដ្ឋប្បវេណីកម្ពុជាទទួលស្គាល់សន្តតិកម្មតាមមរតកសាសន៍ និងសន្តតិកម្មច្បាប់ ។ មរតកសាសន៍ (Will) ឈរលើគោលការណ៍គតិយុត្តទូទៅបី: (១) មរតកសាសន៍ជាលិខិតគតិយុត្តឯកតោភាគី (A Unilateral Legal act) (២) បំណងនិងឆន្ទៈមរតកជន ជាប្រភពអាជ្ញាគតិយុត្ត (Testator's intent is legal competent) និង (៣) មរណៈភាពមរតកជន ផ្តល់សុពលភាពមរតកសាសន៍ ។

តារាងសង្ខេបគោលការណ៍បកស្រាយមរតកសាសន៍




២ .គោលការណ៍បកស្រាយកិច្ចសន្យា (Legal Interpretation of Contract)

តាមទ្រឹស្តីគតិយុត្តទំនើប កិច្ចសន្យាជាកិច្ចព្រមព្រៀងសម្តែងឡើងពីស្វ័យភាពនៃឆន្ទៈបុគ្គលរបស់ភាគីកិច្ចសន្យា (Private Autonomy of Contratual Parties) និងភ្ជាប់ដោយកាតព្វកិច្ច គតិយុត្តបង្ខំ (Legal Biding) ។ គោលការណ៍នេះ បានវិវត្តចេញពីសិទ្ធិចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្ស (Right to Human Dignity) និងសិទ្ធិចំពោះកម្មសិទ្ធិ (Right to Property) ។ គោលការណ៍ទាំងពីរនេះ ជានាសិទ្ធិ ស្វ័យសម្រេច និងសេរីភាពក្នុងការធ្វើកិច្ចសន្យារបស់រូបវន្តបុគ្គលម្នាក់ៗ ។ តែទោះជាយ៉ាងណាក៏ដោយ ដោយសិទ្ធិស្វ័យភាពនៃឆន្ទៈបុគ្គល (Private Autonomy) ក្នុងយុគ្គសម័យទំនើប ត្រូវបានកំរិត ព្រំដែនឈរលើគោលការណ៍យុត្តិធម៌និងស្មើភាព (Fairness, Justice, and Equality) ។ ការកំរិតព្រំដែននេះ ក្រោមហេតុផលជានាយុត្តិធម៌ និងសុខុមាលភាពសង្គម (Justice and Public Welfare) ។ ហេតុនេះប្រព័ន្ធច្បាប់ទំនើប កំណត់ភាពចាំបាច់ខ្លះលើការកំរិតព្រំដែននៃស្វ័យភាពឆន្ទៈបុគ្គល។



តារាងសង្ខេបគោលការណ៍បកស្រាយកិច្ចសន្យា



ឯកសារយោង

១. រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ (ការផ្សព្វផ្សាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ២០១៨)

២. ឃឹម អ៊ី កម្រងច្បាប់ខ្មែរ អត្ថបទរដ្ឋធម្មនុញ្ញខ្មែរ (១៩៤៧-១៩៩៣)

៣. កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស (១៩៩១, Khmer/Eglish Agreement)

៤. ហោ ប៉ែង កម្រងឯកសារ ស្នាដៃស្រាវជ្រាវបោះពុម្ពផ្សាយ (២០២០, សៀវភៅបោះពុម្ពខ្លួនឯង)

៥. Hidenori Moto, Comparative Study of Constitutional Law (Lecture, 2001)

៦. Hor Peng, Cambodian Lawmaking Process (2002)/the Reform of Parliament (2005)

៧. សម្តេច ជួន ណាត, វចនានុក្រមខ្មែរ (១៩៣៨) និង ថាច់ គ្វាន់ ប្រវត្តិសាស្ត្រប្រជាជាតិខ្មែរ (២០១០)

៨. ត្រឹង ងា, ប្រវត្តិសាស្ត្រខ្មែរ (១៩៧២) និង ប៉ាង ខាត់, ប្រវត្តិពុទ្ធសាសនានៅខ្មែរ (១៩៦១)

៩. អាដេម៉ារ ឡឺក្លែរ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា (២០០៥), ប្រៃពីភាសាបារាំងច្បាប់ដើម (១៩១៤)

១០. កំណត់ហេតុពិស្តារសម័យប្រជុំពេញអង្គលើកទី២នៃសភាធម្មនុញ្ញ (១៥.៩.១៩៩៣)

១១. Kyoko Inoue, MacArthur´s Japanese Constitution, A Linguistic and Cultural Study of Its Making, (University of Chicago Press, 1991)

១២. Nigel Foster & Salish Sule, German Legal System and Laws, (4th Ediction, 2010)

១៣. Hilaire Barnet, Constiutional & Administrative Law (5th Edition, 2004)

១៤. Charles Howards McIlwain, Constitutionalism: Ancient and Modern (1940)

១៥. Aristotles, Politics (in Great Books of the Western World)

១៦. K. Zweigert & H. Kotz, An Introduction to Comparative Law (3rd Edition, 1998)

១៧. Source of Internet, Free Encyclopedia (www.wkikipedia.org) and others.

១៨. Aharon Barak, The Judge In A Democracy, (Princeton University Press, 2006)

១៩. Rolf H. Hasse, Hermann Schneider and Klaus Weigelt (Ed.) Social Market Economy Principles and Implementation, Economic Policy from A to Z, (KAS 2008)។

ឧបមសម្ព័ន្ធ១


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
រដ្ឋធម្មនុញ្ញ
ការផ្សាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
ព.ស.២៥៦៤ គ.ស.២០២១



ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ឪរ៉ុន
រាជហរិវង្ស ខ្ចតគោសុជាត ទិសុទ្ធិពង្ស
អគ្គមហាបុរសរតន៍ និភរោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមចពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមមាត្រាទី ១៣៥ និង ១៣៦ នៃ ជំពូក ១៤ ស្តីអំពីអន្តរប្បញ្ញត្តិ នៃ រដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រ កម្ពុជា អនុម័តដោយសភាធម្មនុញ្ញ នៅថ្ងៃទី ២១ ខែកញ្ញា គ.ស. ១៩៩៣ ។

ត្រាស់បង្គាប់

មាត្រាទី១ៈ ប្រកាសឱ្យប្រើជាផ្លូវការភ្លាម នូវ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ដែលសភាធម្មនុញ្ញបានអនុម័ត នៅថ្ងៃទី ២១ ខែកញ្ញា គ.ស. ១៩៩៣ ។

មាត្រាទី២ៈ សភាធម្មនុញ្ញ បានត្រឡប់ទៅជា រដ្ឋសភា នៃ កម្ពុជា ចាប់ពីពេលនេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣

ន. សីហនុ

នរោត្តម សីហនុ

បុព្វកថា

*****

យើង ប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភធំទូលាយ ប្រុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ,

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយទ្រុឌទ្រោមឱនថយមហាសោកស្តាយ,

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ធន្ទៈមោះមុត ប្តូរផ្តាច់រួបរួមគ្នា ពង្រឹងឯកភាពជាតិ រក្សាការពារ ទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឲ្យទៅជា «កោះសន្តិភាព» ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់, ទទួលខុសត្រូវខ្ពស់ចំពោះវាសនាអនាគតជាតិ ឱយបានឈានឡើងរីកចំរើន លូតលាស់ សម្បូររុងរឿងជានិច្ចនិរន្តរ៍ ។

ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដូចតទៅ ៖

ជំពូកទី ១

អំពី អធិបតេយ្យ

មាត្រា ១.-

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនិងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ។

មាត្រា ២.-

បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទី ខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះ ឆ្នាំ ១៩៦៣ - ១៩៦៩ ។

មាត្រា ៣.-

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន ។

មាត្រា ៤.-

បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ : ជាតិ ,សាសនា ,ព្រះមហាក្សត្រ។

មាត្រា ៥.-

ភាសា និងអក្សរ ដែលប្រើជាផ្លូវការ គឺភាសា និងអក្សរខ្មែរ ។

មាត្រា ៦.-

ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

ទង់ជាតិ ភ្លេងជាតិ និងសញ្ញាជាតិ មានកំណត់នៅក្នុងឧបសម្ព័ន្ធ ១, ២ និង ៣ ។

ជំពូកទី ២

អំពី ព្រះមហាក្សត្រ

មាត្រា ៧.-

ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។

ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ ។

មាត្រា ៨.-

ព្រះមហាក្សត្រព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ ។

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យនិងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ ។

មាត្រា ៩.-

ព្រះមហាក្សត្រទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឲ្យមានភាពទៀងទាត់ ។

មាត្រា ១០.-

របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង ។

ព្រះមហាក្សត្រទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរដ្ឋទាយាទសម្រាប់គ្រងរាជសម្បត្តិឡើយ។

មាត្រា ១១.-ថ្មី

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជការៈជាព្រះប្រមុខរដ្ឋបានដូចធម្មតាដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភានិងនាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គក្នុងឋានៈជាព្រះរាជានុសិទ្ធិ ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ចនេះ ។

តំណែងជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិនេះ អាចនឹងដូរតស្សរជនផ្សេងទៀត ក្នុងករណីដូចដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ តាមឋានានុក្រមដូចតទៅ :

ក- អនុប្រធានទី ១ ព្រឹទ្ធសភា
ខ- អនុប្រធានទី ១ រដ្ឋសភា
គ- អនុប្រធានទី ២ ព្រឹទ្ធសភា
ឃ- អនុប្រធានទី ២ រដ្ឋសភា

មាត្រា ១២.-ថ្មី

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ក្នុងពេលព្រះអង្គចូលទីវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងហាន:ជាព្រះរាជានុសិទ្ធិត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ថ្មី ។

មាត្រា ១៣.-ថ្មី

ក្នុងរយៈវេលា ៧ថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

-ប្រធានព្រឹទ្ធសភា

-ប្រធានរដ្ឋសភា

-នាយករដ្ឋមន្ត្រី

-សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ

-អនុប្រធានទី ១ និងអនុប្រធានទី ២ ព្រឹទ្ធសភា

-អនុប្រធានទី ១ និងអនុប្រធានទី ២ រដ្ឋសភា

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិនឹងមានកំណត់ក្នុងច្បាប់មួយ ។

មាត្រា ១៤.-

ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សមាជិកនៃព្រះរាជវង្សានុវង្សខ្មែរ ដែលមានព្រះជន្មាយុយ៉ាងតិច៣០ព្រះវស្សា ហើយដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ **អង្គឌួង** ឬ

ព្រះមហាក្សត្រ **នរោត្តម** ឬក៏ព្រះមហាក្សត្រ **ស៊ីសុវត្ថិ** ។

មុនចូលគ្រងរាជសម្បត្តិ ព្រះមហាក្សត្រទ្រង់ថ្លែងសច្ចាប្រណិធាន ដូចមានចែងក្នុងឧបសម្ព័ន្ធ ទី៤ ។

មាត្រា ១៥.-

ព្រះជាយានៃព្រះមហាក្សត្រមានព្រះរាជឋានៈជាព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៦.-

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានព្រះរាជសិទ្ធិធ្វើនយោបាយ ទទួលតួនាទីជាអ្នកដឹកនាំរដ្ឋ ឬជាអ្នកដឹកនាំរាជរដ្ឋាភិបាល ឬទទួលតួនាទីរដ្ឋបាល ឬនយោបាយឡើយ ។

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជាទុកព្រះរាជកាយពលបំពេញព្រះរាជភារៈបំរើប្រយោជន៍សង្គម មនុស្សធម៌ សាសនា និងជួយព្រះមហាក្សត្រក្នុងព្រះរាជកាតព្វកិច្ច ផ្នែកពិធីការ និងការទូត ។

មាត្រា ១៧.-

ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ហើយដែលមានចែងក្នុងវាក្យខ័ណ្ឌទីមួយនៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញនេះ មិនអាចសុំកែប្រែបានដាដាច់ខាត ។

មាត្រា ១៨.-ថ្មី

ព្រះមហាក្សត្រព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភានិងរដ្ឋសភាដោយព្រះរាជសារ ។

ព្រះរាជសារនេះ ព្រឹទ្ធសភានិងរដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ ។

មាត្រា ១៩ ថ្មី.-

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រីនិងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី ។

មាត្រា ២០.-

ព្រះមហាក្សត្រទ្រង់ទទួលសវនាការជាផ្លូវការពីរដងក្នុងមួយខែ ឲ្យនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីចូលគាល់រាយការណ៍ទូលថ្វាយទ្រង់ជ្រាបអំពីសភាពការណ៍នៃប្រទេសជាតិ ។

មាត្រា ២១.-

តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារៈកិច្ចមន្ត្រីជាន់ខ្ពស់ ស៊ីវិលនិងយោធា ឯកអគ្គរាជទូត និងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព ។

តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬដកចៅក្រមផ្នែកយុត្តាធិការ ។

មាត្រា ២២.-ថ្មី

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភានិងប្រធានព្រឹទ្ធសភា ។

មាត្រា ២៣.-

ព្រះមហាក្សត្រទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ។ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើងដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ។

មាត្រា ២៤.-ថ្មី

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា ។

មាត្រា ២៥.-

ព្រះមហាក្សត្រទ្រង់ទទួលសារតាំងឯកអគ្គរដ្ឋទូត ឬប្រេសិតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសក្រៅ មកប្រចាំព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២៦.-ថ្មី

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញានិងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភានិងព្រឹទ្ធសភា ។

មាត្រា ២៧.-

ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស ។

មាត្រា ២៨.-ថ្មី

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្តលេខានៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ ។

មាត្រា ២៩ ថ្មី.-

ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិ ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈយោធានិងស៊ីវិលតាមច្បាប់កំណត់ ។

មាត្រា ៣០.-ថ្មី

ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ពេលព្រះអង្គទ្រង់អវត្តមានការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ថ្មី ។

ជំពូកទី ៣
អំពី សិទ្ធិ និងករណីយកិច្ច
របស់ប្រជាពលរដ្ឋខ្មែរ

មាត្រា ៣១.-

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិ សេរីភាព ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិ សេរីភាព អ្នកដទៃឡើយ ។ ការប្រើសិទ្ធិ សេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។

មាត្រា ៣២.-

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាពនិងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឲ្យមានឡើយ ។

មាត្រា ៣៣.-

ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬ ចាប់បញ្ជូនខ្លួនទៅឲ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

មាត្រា៣៤.- ថ្មី (មួយ)

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។

បទប្បញ្ញត្តិដកសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់។

មាត្រា ៣៥.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

មាត្រា ៣៦.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នា នឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គមនិងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់។

មាត្រា ៣៧.-

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

មាត្រា ៣៨.-

ច្បាប់រ៉ាប់រងមិនឲ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាម បញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឲ្យធ្វើឡើយ ។ អ្នកដែដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

មាត្រា ៣៩.-

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទាវសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

មាត្រា ៤០.-

សេរីភាពក្នុងការដើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់ របស់ប្រជាពលរដ្ឋត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬ វិលត្រឡប់មកវិញបាន។

ការរក្សាសិទ្ធិមិនឲ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការ

ឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទ ត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គល ត្រូវធ្វើឲ្យស្រប នឹងបញ្ញត្តិច្បាប់ ។

មាត្រា ៤១.-

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារពត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

មាត្រា ៤២.- ថ្មី

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគមនិងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។

គណបក្សនយោបាយត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។

មាត្រា ៤៣.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

មាត្រា ៤៤.-

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយ សមរម្យ និងយុត្តិធម៌ ។

មាត្រា ៤៥.-

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល។

ការធ្វើអាជីវកម្ម លើការងាររបស់ស្ត្រី ត្រូវហាមឃាត់ ។

បុរស និង ស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្មគ្រចិត្ត ប្តីមួយប្រពន្ធមួយ ។

មាត្រា ៤៦.-

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឲ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋនិងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឲ្យនារី ជាពិសេសនារីនៅជនបទ ដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជម្ងឺ ឲ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

មាត្រា ៤៧.-

មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីយកិច្ចចិញ្ចឹមនិងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ ។

មាត្រា ៤៨.-

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណ លើកុមារ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឲ្យខូចដល់ការ អប់រំ និង ការរៀនសូត្ររបស់កុមារ ឬ ដែលនាំអោយអន្តរាយដល់សុខភាព ឬ សុខុមាលភាពរបស់កុមារ ។

មាត្រា ៤៩.- ថ្មី

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់។

មាត្រា ៥០.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធិ ស្របច្បាប់របស់ឯកជន ។

ជំពូកទី ៤

អំពី របបនយោបាយ

មាត្រា ៥១.-ថ្មី

ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលនិងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

មាត្រា ៥២.-

រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សាការពារទំនៀមទម្លាប់និងប្រពៃណីល្អរបស់ជាតិ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវការពារនីត្យានុកូលភាពជានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។ រដ្ឋយកចិត្តទុកដាក់ជាអាទិភាព ចំពោះជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

មាត្រា ៥៣.- ថ្មី

ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជារួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក។

ព្រះរាជាណាចក្រកម្ពុជាមិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក។

ព្រះរាជាណាចក្រកម្ពុជាប្រឆាំងដាច់ខាតការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ទោះបីក្រោមរូបភាពណាក៏ដោយ។

ព្រះរាជាណាចក្រកម្ពុជាមិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ។

ព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ។

ព្រះរាជាណាចក្រកម្ពុជារក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈយោធា អាវុធ គ្រាប់រំសែវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស។

មាត្រា ៥៤.-

ការផលិត ការប្រើប្រាស់ ការរក្សាទុកអាវុធបរមាណូ អាវុធគីមី ឬ អាវុធវេត្រាណូ ត្រូវហាមឃាត់ដាច់ខាត ។

មាត្រា ៥៥.-

សន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្របនឹង ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិ របស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល ។

ជំពូក ទី ៥
អំពី សេដ្ឋកិច្ច

មាត្រា ៥៦.-

ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់។

មាត្រា ៥៧.-

ការយកពន្ធដារនឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត ។ ថវិកាជាតិត្រូវបានកំណត់ឲ្យអនុវត្តតាមច្បាប់ ។

របបគ្រប់គ្រងរូបិយវត្ថុនិងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់។

មាត្រា ៥៨.-

ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្ទ បាតសមុទ្ទ ក្រោមបាតសមុទ្ទ ឆ្នេរសមុទ្ទ អាកាស កោះ ទន្លេ ព្រៃក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ ។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ក្នុងច្បាប់ ។

មាត្រា ៥៩.-

រដ្ឋត្រូវរក្សាការពារបរិដ្ឋាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឲ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភោគោគ្គសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ហាមពល ប្រេងកាត និងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានដលផល ។

មាត្រា ៦០.-

ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី ។ ការតម្រូវឲ្យលក់ផលិតផលជូនរដ្ឋ ឬការយកភោគផល ឬទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់ ទោះបីមួយរយៈពេលក៏ដោយត្រូវហាមឃាត់ វៀរលែងតែក្នុងករណីពិសេសដែលមានច្បាប់អនុញ្ញាត ។

មាត្រា ៦១.-

រដ្ឋជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាលដោយយកចិត្តទុកដាក់ទៅលើ នយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន ។

មាត្រា ៦២.-

រដ្ឋយកចិត្តទុកដាក់ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផល ជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល ។

មាត្រា ៦៣.-

រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ជួយឲ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានកម្រិតសមរម្យ ។

មាត្រា ៦៥.-

រដ្ឋហាមឃាត់និងផ្តន្ទាទោសជាទម្ងន់ដល់ជនណា ដែលនាំចូល ផលិត លក់ដូរ គ្រឿងញៀន ទំនិញក្លែងក្លាយ ហួសរយៈពេលប្រើដែល ប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើ ។

ជំពូក ទី ៦

អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច

មាត្រា ៦៥.-

រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កំរិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាដំហានៗ ដើម្បីឲ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។

រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយនិងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

មាត្រា ៦៦.-

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញនិងឯកភាព នៅទូទាំងប្រទេសដែលធានាឲ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការនិងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នាក្នុងការកសាងជីវិត ។

មាត្រា ៦៧.-

រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើបរាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស ។

រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និងថ្នាក់សិក្សាសាធារណៈនិងឯកជននៅគ្រប់ភូមិសិក្សា ។

មាត្រា ៦៨.-

រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈ សំរាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ។

ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ ។

រដ្ឋជួយផ្សព្វផ្សាយនិងលើកតំកើងសាលាបាលីនិងពុទ្ធិកសិក្សា។

មាត្រា ៦៩.-

រដ្ឋមានកាតព្វកិច្ចថែរក្សា និងពង្រីកវប្បធម៌ជាតិ ។

រដ្ឋមានកាតព្វកិច្ចការពារ និងពង្រីកភាសាខ្មែរឲ្យសមស្របនឹងសេចក្តីត្រូវការ ។

រដ្ឋមានកាតព្វកិច្ចថែរក្សានិងការពារ ប្រាសាទបុរាណវត្ថុសិល្បៈបុរាណ និងកែលំអរមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ ។

មាត្រា ៧០.-

បទល្មើសទាំងឡាយដែលប៉ះពាល់ ឬទាក់ទងនឹងបេតិកភ័ណ្ឌវប្បធម៌ និងបេតិកភ័ណ្ឌសិល្បៈ ត្រូវផ្តន្ទាទោសជាទម្ងន់ ។

មាត្រា ៧១.-

បរិវេណបេតិកភ័ណ្ឌជាតិក៏ដូចជាបេតិកភ័ណ្ឌដែលបានបញ្ចូលជាបេតិកភ័ណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹត ដែលមិនឲ្យមានសកម្មភាពយោធា ។

មាត្រា ៧២.-

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារដម្ងឺនិងព្យាបាលជម្ងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួល

ការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ ។

រដ្ឋរៀបចំឲ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ ។

មាត្រា ៧៣.-

រដ្ឋយកចិត្តទុកដាក់ចំពោះកុមារនិងមាតា ។ រដ្ឋរៀបចំឲ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង ។

មាត្រា ៧៤.-

រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។

មាត្រា ៧៥.-

រដ្ឋចាត់ចែងឲ្យមានរបបសន្តិសុខសង្គម ដល់កម្មករនិងនិយោជិត ។

ជំពូកទី ៧

អំពី រដ្ឋសភា

មាត្រា ៧៦.- ថ្មី

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រ ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៧៧.-

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ ។

មាត្រា ៧៨.-

នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង ។ រដ្ឋសភាមិនអាចត្រូវបានរំលាយ

មុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈ ១២ ខែ ។

ក្នុងករណីនេះព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា ។

ការបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋសភាថ្មី នឹងប្រព្រឹត្តទៅក្នុងរយៈពេល ៦០ ថ្ងៃយ៉ាងយូរ ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក ។

ក្នុងរយៈកាលនេះ រាជរដ្ឋាភិបាលមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ ។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៧៩.-

អាណត្តិនៃសមាជិករដ្ឋសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល ។

ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះ មានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗ នៃរដ្ឋសភា ។

មាត្រា ៨០.-

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទ័ណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសំរេច ។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើន បីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៨១.-

រដ្ឋសភាមានថវិកាស្វយ័ត សំរាប់ដំណើរការ ។

តំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់ ។

មាត្រា ៨២.- ថ្មី

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។

មាត្រា ៨៣.-

រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនិមួយៗ មានចិរៈវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិច គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ។

ក្នុងករណីនេះ របៀបវារៈជាក់លាក់នៃសម័យប្រជុំជាវិសាមញ្ញត្រូវផ្សាយដល់ប្រជារាស្ត្រជាមួយនឹងថ្ងៃកំណត់ប្រជុំ ។

មាត្រា ៨៤.-

នៅចន្លោះសម័យប្រជុំរបស់រដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាទទួលការកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភារួមមាន : ប្រធានរដ្ឋសភា អនុប្រធានរដ្ឋសភា និងប្រធានគណៈកម្មការទាំងអស់របស់រដ្ឋសភា ។

មាត្រា ៨៥.-

សម័យប្រជុំរដ្ឋសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់រដ្ឋសភា លើកលែងតែមានការសំរេចផ្សេង ចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើ និងក្រៅពីកន្លែង និងពីកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់រដ្ឋសភាត្រូវទុកជាខុសច្បាប់ ហើយជាអាសាសូន្យពេញលក្ខណៈ ។

មាត្រា ៨៦.-

ក្នុងកាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ រដ្ឋសភាមានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើរដ្ឋសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

នៅពេលដែលប្រទេសជាតិបិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ។

មាត្រា ៨៧.-

ប្រធានរដ្ឋសភាដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលអាញ្ញត្តិច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយដែលរដ្ឋសភាបានអនុម័ត រ៉ាប់រងការអនុវត្ត បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា ។

ក្នុងករណីដែលប្រធានរដ្ឋសភាមានធុរៈ មិនអាចបំពេញមុខងារបានដោយហេតុមកពីមានជម្ងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានរដ្ឋសភាមួយរូបត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬអនុប្រធានរដ្ឋសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី ។

មាត្រា ៨៨.-ថ្មី(ពីរ)

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភា នឹងយកជាការបានលុះត្រាតែមាន :

ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្តាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៨៩.-

តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយ មកបំភ្លឺរដ្ឋសភាអំពីបញ្ហាដែលមានសារៈសំខាន់ពិសេស ។

មាត្រា ៩០.- ថ្មី(ពីរ)

រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬ លុបចោលសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៩១.-ថ្មី

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភានិងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្ដួចផ្តើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។

មាត្រា ៩២.-

ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារ ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឲ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអាសាសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ ។

មាត្រា ៩៣.-ថ្មី

ច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលកំណត់ខាងលើ ។

មាត្រា ៩៤.-

រដ្ឋសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំនិងការប្រព្រឹត្តទៅ នៃរដ្ឋសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

មាត្រា ៩៥.-

ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬប្រាសចាកសមាជិកភាព ដែលកើតមានឡើង ៦ខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះ តាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៩៦.-

តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ។ សំណួរនេះត្រូវសរសេរជាលាយល័ក្ខអក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។

ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូបឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើង ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូបឬច្រើនរូប ។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន ។

ចម្លើយរបស់រដ្ឋមន្ត្រីឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ឬសរសេរជាលាយល័ក្ខអក្សរ ។

ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ ។

ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសំរេចបើកឲ្យមាន ឬមិនឲ្យមានការជជែកដេញដោល ។ បើគ្មានការបើកឲ្យជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី នឹងបញ្ចប់សំណួរតែម្តង។

បើមានការបើកឲ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធឬនាយករដ្ឋមន្ត្រី អាចជជែកប្តូរយោបល់ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ ។

រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ សម្រាប់ការឆ្លើយសំណួរ ។

ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសំរាប់ឆ្លើយសំណួរខាងលើនេះមិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ។

មាត្រា ៩៧.-

គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន ។

មាត្រា ៩៨.- ថ្មី

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងដូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

ជំពូកទី ៨ ថ្មី
អំពីព្រឹទ្ធសភា

មាត្រា ៩៩.-ថ្មី

ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន ។

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះនិងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ ។

សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំងនិងជ្រើសតាំងសាជាថ្មីបាន ។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោតមានអាយុយ៉ាងតិច ៤០ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត ។

មាត្រា ១០០.-ថ្មី

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប ។

រីឯសមាជិកព្រឹទ្ធសភាឯទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល។

មាត្រា ១០១.-ថ្មី

ការរៀបចំ បែបបទនិងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោតនិងមណ្ឌលបោះឆ្នោត ត្រូវចែងក្នុងច្បាប់មួយ ។

មាត្រា ១០២.-ថ្មី

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

ក្នុងពេលមានសង្គ្រាមឬក្នុងកាល:ទេស:ពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភាត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងកាល:ទេស:ដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ ព្រឹទ្ធសភាមានសិទ្ធិសំរេចបញ្ចប់កាល:ទេស:ពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

មាត្រា ១០៣.-ថ្មី

អាណត្តិនៃសមាជិកព្រឹទ្ធសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម ជាមួយមុខងារជាតំណាងរាស្ត្រនិងជាមួយមុខងារជាសមាជិកស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

មាត្រា ១០៤.-ថ្មី

សមាជិកព្រឹទ្ធសភា មានអភ័យឯកសិទ្ធិសភា ។

សមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួនឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។ ការចោទប្រកាន់ការចាប់ខ្លួន ការឃាត់ខ្លួនឬការឃុំខ្លួនសមាជិកណាមួយនៃព្រឹទ្ធសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទ័ណ្ឌជាក់ស្តែង ។ ក្នុងករណីចុងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភាឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីសំរេច ។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

មាត្រា ១០៥.-ថ្មី

ព្រឹទ្ធសភាមានថវិកាស្វ័យតសំរាប់ដំណើរការ ។

សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់បំណាច់ ។

មាត្រា ១០៦.-ថ្នី(មួយ)

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

មាត្រា ១០៧.-ថ្នី

ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនីមួយៗមានចិរៈវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ ។

មាត្រា ១០៨.-ថ្នី

នៅចន្លោះសម័យប្រជុំរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាទទួលការកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភារួមមាន : ប្រធានព្រឹទ្ធសភា អនុប្រធានព្រឹទ្ធសភានិងប្រធានគណៈកម្មការទាំងអស់របស់ព្រឹទ្ធសភា ។

មាត្រា ១០៩.-ថ្មី

សម័យប្រជុំព្រឹទ្ធសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់ព្រឹទ្ធសភា លើកលែងតែមានការសំរេចផ្សេងចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើនិងក្រៅពីកន្លែង និងកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់ព្រឹទ្ធសភាត្រូវទុកជាខុសច្បាប់ ហើយអសារសូន្យពេញលក្ខណៈ ។

មាត្រា ១១០.-ថ្មី

ប្រធានព្រឹទ្ធសភាដឹកនាំអង្គប្រជុំរបស់ព្រឹទ្ធសភា ទទួលអាញត្តិច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយដែលព្រឹទ្ធសភាបានអនុម័ត រ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានិងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់ព្រឹទ្ធសភា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាមានធុរៈ មិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជម្ងឺឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិឬបំពេញបេសកកម្មនៅបរទេស អនុប្រធានព្រឹទ្ធសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬអនុប្រធានព្រឹទ្ធសភាលាលែងពីមុខតំណែងឬទទួលអនិច្ចកម្ម ព្រឹទ្ធសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី ។

មាត្រា ១១១.-ថ្មី(ពីរ)

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ-កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬ យកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រមហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

មាត្រា ១១២.-ថ្មី

ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភានិងរដ្ឋាភិបាល ។

មាត្រា ១១៣.-ថ្មី

ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រមឬពុំបានឱ្យយោបល់សោះ ក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

បើព្រឹទ្ធសភាសុំឱ្យកែសំរួលសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ ។ រដ្ឋសភាត្រូវពិនិត្យនិងសំរេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសំរួល ដោយបដិសេធចោលទាំងមូលឬទុកជាបានការខ្លះ ។

ការបង្វិលទៅបង្វិលមកវាងព្រឹទ្ធសភានិងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសំរេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់ ។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភានិងព្រឹទ្ធសភា ត្រូវបន្ថែមឱ្យស្មើគ្នាដែរ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបាន មុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិនិងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ជាលើកទី ២ នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហនិងយកតាមមតិភាគច្រើនដាច់ខាត ។

សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ណាដែលបានសំរេចដូចខាងលើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

មាត្រា ១១៤.-ថ្នី(មួយ)

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះត្រូវអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

មាត្រា ១១៥.-ថ្នី

ក្នុងករណីមានសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្ម លាលែងឬប្រាសចាកសមាជិកភាពដែលកើតមានឡើងប្រាំមួយខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់តាំងឬជ្រើសតាំងជំនួសសមាជិកនោះ តាមលក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា និងក្នុងច្បាប់ស្តីពីការចាត់តាំងនិងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ៩ ថ្មី

អំពីសមាជរដ្ឋសភានិងព្រឹទ្ធសភា

មាត្រា ១១៦.-ថ្មី

ក្នុងករណីចាំបាច់ រដ្ឋសភានិងព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។

មាត្រា ១១៧.-ថ្មី

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិដូចមានចែងក្នុងមាត្រា ១១៦ ថ្មី ខាងលើ ព្រមទាំងការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជ នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

ជំពូកទី ១០ ថ្មី

អំពីរាជរដ្ឋាភិបាល

មាត្រា១១៨.- ថ្មី (មួយ)

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីជាសមាជិក។

មាត្រា ១១៩.-ថ្មី (មាត្រា ១០០ ចាស់)

តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោត ឱ្យបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្គូរផ្គងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបីរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។

មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦ ។

មាត្រា ១២០.-ថ្មី (មាត្រា ១០១ ចាស់)

មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិតភាពនិងសកម្មភាពខាងវិជ្ជាជីវៈផ្នែកពាណិជ្ជកម្មឬឧស្សាហកម្ម ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ។

មាត្រា ១២១.-ថ្មី (មាត្រា ១០២ ចាស់)

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួន ចំពោះនាយករដ្ឋមន្ត្រីនិងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត ។

មាត្រា ១២២.-ថ្មី (មាត្រា ១០៣ ចាស់)

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលមិនអាចយកសំអាងនៃសេចក្តីបង្គាប់ដោយលាយលក្ខអក្សរឬដោយវាចាអំពីនរណាមួយ ដើម្បីដោះសាឱ្យរួចខ្លួនពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ ។

មាត្រា ១២៣.-ថ្មី (មាត្រា ១០៤ ចាស់)

គណៈរដ្ឋមន្ត្រីត្រូវប្រជុំរាល់សប្តាហ៍ ជាប្រជុំធំឬជាប្រជុំពិនិត្យស្រាវជ្រាវ ។

អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ។ នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន ។

កំណត់ហេតុនៃអង្គប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រី ត្រូវធ្វើថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប ។

មាត្រា ១២៤.-ថ្មី (មាត្រា ១០៥ ចាស់)

នាយករដ្ឋមន្ត្រីអាចរំលែកអំណាចរបស់ខ្លួនឱ្យទៅឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន ។

មាត្រា ១២៥.-ថ្មី (មាត្រា ១០៦ ចាស់)

បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរដោស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងលក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ បើការទំនេរនេះជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្តីទីជាបណ្តោះអាសន្ន ។

មាត្រា ១២៦.-ថ្មី (មាត្រា ១០៧ ចាស់)

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ។

ក្នុងករណីនេះនិងក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួនរដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភាសំរេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ១២៧.-ថ្មី (មាត្រា ១០៨ ចាស់)

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

ជំពូកទី ១១ ថ្មី
អំពីអំណាចតុលាការ

មាត្រា ១២៨.-ថ្មី (មាត្រា ១០៩ ចាស់)

អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការធានារក្សាអនាគតិនិងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូលនិងសាលាដំរះក្តីគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់ ។

មាត្រា ១២៩.-ថ្មី (មាត្រា ១១០ ចាស់)

ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធីនិងច្បាប់ជាធរមាន ។

មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់និងឱ្យអស់ពីដួងចិត្តនិងសម្បជញ្ញៈរបស់ខ្លួន ។

មាត្រា ១៣០.-ថ្មី (មាត្រា ១១១ ចាស់)

គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។

មាត្រា ១៣១.-ថ្មី (មាត្រា ១១២ ចាស់)

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

មាត្រា ១៣២.-ថ្មី (មាត្រា ១១៣ ចាស់)

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

មាត្រា ១៣៣.-ថ្មី (មាត្រា ១១៤ ចាស់)

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស ។

មាត្រា ១៣៤.-ថ្មី (មាត្រា ១១៥ ចាស់)

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយដែលនឹងកំណត់សមាសភាពនិងមុខងារ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រមនិងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចំពោះចៅក្រមនិងព្រះរាជអាជ្ញា ត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូលឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រមឬព្រះរាជអាជ្ញា ។

មាត្រា ១៣៥.-ថ្មី (មាត្រា ១១៦ ចាស់)

លក្ខន្តិក:នៃចៅក្រមនិងព្រះរាជអាជ្ញានិងការរៀបចំអង្គការតុលាការ នឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា ។



ជំពូកទី ១២ ថ្មី
អំពីក្រុមប្រឹក្សាធម្មនុញ្ញ

មាត្រា ១៣៦.- ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

មាត្រា ១៣៧.- ថ្មី (មាត្រា ១១៨ ចាស់)

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ប្តីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រធានមានសំឡេងឧត្តមានុភាពក្នុងករណីបែកសំឡេងជាពីរស្មើគ្នា ។

មាត្រា ១៣៨.- ថ្មី (មាត្រា ១១៩ ចាស់)

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាទៅ ខាងច្បាប់ ខាងរដ្ឋបាល ខាងការទូតឬខាងសេដ្ឋកិច្ច ហើយមានពិសោធន៍ច្រើនក្នុងការងារ ។

មាត្រា ១៣៩.- ថ្មី

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពនឹងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងតំណែង ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធានគណបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព ។

មាត្រា ១៤០.- ថ្មី

ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភាឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នោះ ត្រូវប្រកាសឱ្យប្រើ ។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានិងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឱ្យប្រើ ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេច ក្នុងរយៈពេលសាមសិប (៣០)ថ្ងៃយ៉ាងយូរ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភានិងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្របឬមិនស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ១៤១.- ថ្មី

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ឬតុលាការអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រឬប្រធានរដ្ឋសភាឬសមាជិកព្រឹទ្ធសភាឬប្រធានព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

មាត្រា ១៤២.- ថ្មី (មាត្រា ១២៣ ចាស់)

បទប្បញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាមិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសឱ្យប្រើឬយកទៅអនុវត្តបានឡើយ ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសំរេចបិទផ្លូវតវ៉ា ។

មាត្រា ១៤៣.- ថ្មី (មាត្រា ១២៤ ចាស់)

ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ។

មាត្រា ១៤៤.- ថ្មី (មាត្រា ១២៥ ចាស់)

ច្បាប់រៀបចំអង្គការមួយនឹងកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

ជំពូកទី ១៣ ថ្មី
អំពីការគ្រប់គ្រងរដ្ឋបាល

មាត្រា ១៤៥.- ថ្មី (មួយ)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

មាត្រា ១៤៦.- ថ្មី (មួយ)

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ ។

ជំពូកទី ១៤ ថ្មី
អំពីសមាជជាតិ

មាត្រា ១៤៧.-ថ្មី (មាត្រា ១២៨ ចាស់)

សមាជជាតិបើកឱ្យប្រជារាស្ត្រជ្រាបដោយផ្ទាល់ អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិនិងលើកបញ្ហា និងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ ។

ប្រជារាស្ត្រខ្មែរទាំងពីរភេទមានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ ។

មាត្រា ១៤៨.- ថ្មី (មាត្រា ១២៩ ចាស់)

សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំ នៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ។

សមាជជាតិប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។

មាត្រា ១៤៩.- ថ្មី

សមាជជាតិអនុម័តសំណូមពរជូនព្រឹទ្ធសភា ជូនរដ្ឋសភា និងជូនរដ្ឋអំណាចពិចារណា ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជជាតិនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

ជំពូកទី ១៥ ថ្មី(ពីរ)

អំពីអង្គការរៀបចំការបោះឆ្នោត

មាត្រា ១៥O.- ថ្មី (ពីរ)

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអង្គការដែលមានសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

មុខងារជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានវិសមិតភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអាចធ្វើជាសមាជិកនៃគណបក្សនយោបាយ ឬធ្វើជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬក្រុមហ៊ុនពាណិជ្ជកម្មណាមួយបានឡើយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានថវិកាស្វយ័តសម្រាប់ដំណើរការ ។

មាត្រា ១៥១.-ថ្មី(ពីរ)

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមាសភាព ប្រាំបួនរូបដែលទទួលអាណត្តិប្រាំឆ្នាំ ។ សមាសភាពបួនរូបត្រូវជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល បួនរូបត្រូវជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និងមួយរូបត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដំណើរការរៀបចំឲ្យមានការជ្រើសរើសដោយបើកចំហ និងតម្លាភាព នូវសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភារៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាក់ជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បាត់បង់សមាជិកភាពរបស់ខ្លួន គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវចាត់នីតិវិធីជ្រើសរើស សមាសភាពថ្មីជំនួស ក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ គិតពីថ្ងៃបាត់បង់សមាជិកភាព ។ នីតិវិធីលំអិតនៃការជ្រើសរើសសមាសភាពថ្មី ជំនួស ត្រូវកំណត់ដោយច្បាប់ ។

ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ចដើម្បីចាត់ចែងរៀបចំការបោះឆ្នោតតាមច្បាប់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

ជំពូកទី ១៦ ថ្មី (ពីរ)

អំពីអានុភាព ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ

មាត្រា ១៥២.- ថ្មី (ពីរ មាត្រា ១៥០ ថ្មី)

រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

មាត្រា ១៥៣.- ថ្មី (ពីរ មាត្រា ១៥១ ថ្មី)

ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ១៥៤.- ថ្មី (ពីរ មាត្រា ១៥២ ថ្មី)

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឲ្យធ្វើនៅពេលប្រទេសជាតិបិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។

មាត្រា ១៥៥.- ថ្មី (ពីរ មាត្រា ១៥៣ ថ្មី)

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

ជំពូកទី ១៧ ថ្មី

អំពីអន្តរប្បញ្ញត្តិ

មាត្រា ១៥៦.- ថ្មី (ពីរ មាត្រា ១៥៤ ថ្មី)

រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឲ្យចូលជាធរមានភ្លាម ដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៥៧.- ថ្មី (ពីរ មាត្រា ១៥៥ ថ្មី)

ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា ។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និងអនុប្រធានទីពីរ នៃសភាធម្មនុញ្ញ នឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ក្នុងប្រទេសទាមទារ ។

មាត្រា ១៥៨.- ថ្មី (ពីរ មាត្រា ១៥៦ ថ្មី)

ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមលិខ្ខណ្ឌដែលមានចែងក្នុងមាត្រា ១៣ ថ្មី និង ១៤ ។

មាត្រា ១៥៩.- ថ្មី (ពីរ មាត្រា ១៥៧ ថ្មី)

នីតិកាលទី ១ នៃព្រឹទ្ធសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

សម្រាប់នីតិកាលទី ១ នៃព្រឹទ្ធសភា :

-សមាជិកព្រឹទ្ធសភាមានចំនួនសរុបហុកសិបមួយរូប ។

-ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី ១ អនុប្រធានទី ២ នៃព្រឹទ្ធសភា ។

-សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិក នៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ។

-កិច្ចប្រជុំជាសមាជរដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។

មាត្រា ១៦០.- ថ្មី (ពីរ មាត្រា ១៥៨ ថ្មី)

ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោលលើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។

រដ្ឋធម្មនុញ្ញនេះ ត្រូវបានសភាធម្មនុញ្ញអនុម័ត
នៅភ្នំពេញថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ នាសម័យប្រជុំពេញអង្គលើកទី ២

ភ្នំពេញ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣

ប្រធាន



សឺន សាន

ឧបសម្ព័ន្ធទី ១

ទង់ជាតិ



ភ្លេងជាតិ នគរវាដ

១- សូមពួកទេព្តា រក្សា មហាក្សត្រយើង
ឲ្យ បានរុងរឿង ដោយជ័យមង្គល សិរីសួស្តី
យើងខ្ញុំព្រះអង្គ សូមជ្រកក្រោម ម្លប់ព្រះបារមី
នៃព្រះន-របតី វង្សក្សត្រដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ បុរាណថ្កើងថ្កាន ៗ

២- ប្រាសាទសីលា កំចាំងកណ្តាលព្រៃ
គួរឲ្យស្រមៃយ ឆឹកដល់យសសក្តិ មហានគរ
ជាតិខ្មែរដូចថ្ម គង់វង់នៅល្អ រឹងប៉ឹងជាអរ
យើងសច្ចឹមពរ តំពូព្រោងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន យូរអង្វែងហើយ ៗ

៣- គ្រប់វត្តអារាម ឮតែសូរសំឡេងធម៌
សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា
ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា
គង់តែទេវតា ឆឹងជួយជ្រោមជ្រែងផ្តត់ផ្តង់ប្រយោជន៍ឲ្យ
ដល់ប្រទេសខ្មែរ ជាមហានគរ ៗ

សញ្ញាជាតិ



សច្ចាប្រណិធាន
នៃ
ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

ខ្ញុំតាំងសច្ចាថានឹងប្រព្រឹត្តតាមរដ្ឋធម្មនុញ្ញ និង ច្បាប់ ទាំងឡាយនៃព្រះរាជាណាចក្រ ហើយនឹងតាំងចិត្តធ្វើផលប្រយោជន៍ដល់រដ្ឋ និង ប្រជារាស្ត្រ ។

សច្ចាប្រណិធាន

ទូលព្រះបង្គំ
យើងខ្ញុំ
ប្រធាន អនុប្រធាន និង សមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
សូមធ្វើសច្ចាប្រណិធាន
នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ
និងទេវតារក្សាស្វេតច្ឆត្រ
ដូចតទៅ ៖

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូន ចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជានិច្ចទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតិភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថាមិនកេងប្រវ័ញ្ច នូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារ ឬសំរាប់បក្សពួក ឬសំរាប់ភាគីរៀងៗខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ

• ឯករាជ្យភាពទាំងស្រុង នៃមាតុភូមិកម្ពុជា

• អធិបតេយ្យភាពជាតិពេញបរិបូណ៌

• បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មាន ក្នុងជំនាន់ឆ្នាំ ១៩៦៣ ដល់ ១៩៦៩

• ឯកភាពជាតិ ហើយមិនអនុញ្ញាតឲ្យមានការបែងចែង ឬការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធ សំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឲ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុង នៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិ របស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាត នូវផលប្រយោជន៍បរទេស ហើយធ្វើឲ្យខូចខាតដល់ផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយ លើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុង នូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុក នូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកល ស្តីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំង អំពើពុករលួយ គ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និង សន្តិភាពជាតិ ដើម្បីភាព សម្បូរសប្បាយ នៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿង ថ្កើងថ្កាន នៃ មាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំ គ្រប់រូប ។

សច្ចាប្រណិធាន

ទូលព្រះបង្គំ
យើងខ្ញុំ
នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល
សូមធ្វើសច្ចាប្រណិធាន
នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ
និងទេវតារក្សាស្វែតច្ឆត្រ
ដូចតទៅ ៖

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូន ចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតិភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ច នូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារ ឬសំរាប់បក្សពួក ឬសំរាប់ភាគី រៀងៗខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាបូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ

• ឯករាជ្យភាពទាំងស្រុង នៃមាតុភូមិកម្ពុជា

• អធិបតេយ្យភាពជាតិពេញបរិបូណ៌

• បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មាន ក្នុងជំនាន់ឆ្នាំ ១៩៦៣ ដល់ ១៩៦៩

• ឯកភាពជាតិ ហើយមិនអនុញ្ញាតឲ្យមានការបែងចែង ឬការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធ សំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឲ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុង នៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិ របស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាត នូវផលប្រយោជន៍បរទេស ហើយធ្វើឲ្យខូចខាតដល់ផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយ លើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុង នូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុក នូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្នទាំង

ក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និង ពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូច មានចែងក្នុងសេចក្តីប្រកាសជាសកល ស្តីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំង អំពើពុករលួយ គ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និង សន្តិភាពជាតិ ដើម្បីភាព សម្បូរសប្បាយ នៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿង ថ្កើងថ្កាន នៃ មាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំ គ្រប់រូប ។

សច្ចាប្រណិធាន

ទូលព្រះបង្គំ

យើងខ្ញុំ

ប្រធាន អនុប្រធាននិងសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

សូមធ្វើសច្ចាប្រណិធាន

នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ

និងទេវតារក្សាស្វេតច្ឆត្រ

ដូចតទៅ :

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្មដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំសូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជាតិច្ចទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិនិងមាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ចនូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារ ឬសំរាប់បក្សពួក ឬសំរាប់ភាគីរៀងៗខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្នទាំងក្នុងអនាគតនូវ :

  • ឯករាជ្យភាពទាំងស្រុងនៃមាតុភូមិកម្ពុជា

• អធិបតេយ្យភាពជាតិពេញបរិបូណ៌

• បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មាន ក្នុងដំនាន់ឆ្នាំ១៩៦៣ ដល់១៩៦៩

• ឯកភាពជាតិ ហើយមិនអនុញ្ញាតឱ្យមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធសំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឱ្យជនណាមួយក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្កាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាតនូវផលប្រយោជន៍បរទេស ហើយធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយលើផ្នែករាបជាតិនិងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ចទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភានិងពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស

ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និង សន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយ នៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿងថ្កើងថ្កាន នៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

គណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ

បានអនុម័តដោយសភាធម្មនុញ្ញនាសម័យប្រជុំពេញអង្គលើកទី ១

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៣

១-	ឯកឧត្តមសម្តេចប្រធានសភាធម្មនុញ្ញឬឯកឧត្តមអនុប្រធានសភាធម្មនុញ្ញ « ករណីសម្តេចប្រធានអវត្តមាន »		ជាប្រធាន *
២-	ឯកឧត្តម	ចែម ស្ងួន	ជាអនុប្រធាន
៣-	ឯកឧត្តមបណ្ឌិត	តាវ សេងហួរ	ជាអ្នករាយការណ៍
៤-	ឯកឧត្តម	កាន់ ម៉ន	ជាសមាជិក
៥-	ឯកឧត្តម	គាត ឈន់	ជាសមាជិក
៦-	ឯកឧត្តម	ឈួរ លាងហួត	ជាសមាជិក
៧-	ឯកឧត្តម	ថោ ប៉ែងលាត	ជាសមាជិក
៨-	ឯកឧត្តម	សម រង្សី	ជាសមាជិក
៩-	អ្នកអង្គម្ចាស់	ស៊ីសុវត្ថិ សិរីវុឌ្ឍ	ជាសមាជិក
១០-	ឯកឧត្តម	សឺន ស៊ូបែរ៉ុី	ជាសមាជិក
១១-	ឯកឧត្តម	សោម ចាន់បុត្រ	ជាសមាជិក
១២-	ឯកឧត្តម	អ៊ុន នឹង	ជាសមាជិក
១៣-	ឯកឧត្តម	ទ្បួយ សុឹមឈាង	ជាសមាជិក
១៤-	ឯកឧត្តម	ជាម យៀប	ជាសមាជិកបំរុង
១៥-	ឯកឧត្តម	ប៉ុល ហំម	ជាសមាជិកបំរុង
១៦-	ឯកឧត្តម	ពូ សុធីរៈ	ជាសមាជិកបំរុង
១៧-	ឯកឧត្តម	សរ សាអាត	ជាសមាជិកបំរុង

១៨- ឯកឧត្តម	អ៊ឹង គៀត	ជាសមាជិកបំរុង
១៩- ឯកឧត្តម	អ៊ុក រ៉ាប៊ុន	ជាសមាជិកបំរុង
២០- ឯកឧត្តម	អ៊ុង ផន	ជាសមាជិកបំរុង
២១- ឯកឧត្តម	ឯក សំអុល	ជាសមាជិកបំរុង
២២- ឯកឧត្តម	សាយ បូរី	ជាអ្នកជំនាញការ
២៣- ឯកឧត្តម	ចាន់ សុខ	ជាអ្នកជំនាញការ
២៤- ឯកឧត្តម	ឈន អៀម	ជាអ្នកជំនាញការ
២៥- ឯកឧត្តម	ហេង វង្សប៊ុនធាត	ជាអ្នកជំនាញការ
២៦- ឯកឧត្តម	ខៀវ រ៉ាដា	ជាអ្នកជំនាញការ

<u>កំណត់សំគាល់</u> : * យោងជំពូក៧ប្រការ១៨ស្តីពីការគណៈកម្មការ
និង ប្រធានគណៈកម្មការសភាធម្មនុញ្ញ

ច្បាប់ធម្មនុញ្ញបន្ថែម
សំដៅ
ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ



ព្រះរាជក្រម

នស/រកម/០៧០៤/០០១ **យើង**

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ខ្ចតគោសុជាត ឥសុន្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ នៃរដ្ឋសភា នាថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៤
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ នៃព្រឹទ្ធសភា នាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤
- យោងតាមសំណើ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០០៤ របស់ព្រឹទ្ធសមាជិករដ្ឋសភា នីតិកាលទី៣

ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

ច្បាប់ធម្មនុញ្ញបន្ថែម
សំដៅ
ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

មាត្រា ១.-

ច្បាប់ធម្មនុញ្ញនេះ មានគោលដៅធានាក្នុងគ្រប់កាល:ទេស:នូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាន នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមស្របតាមតម្រូវការនៃភាពចាំបាច់ ។

មាត្រា ២.-

នៅដើមនីតិកាលថ្មីនីមួយៗ រដ្ឋសភា ក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភា មុននឹងផ្តើមការងាររបស់ខ្លួន និង ក្រោយពេលសំរេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកម្នាក់ៗ អាចចាប់ផ្តើមអនុម័ត អត្ថបទដែលមានចារិក ជារដ្ឋធម្មនុញ្ញ ឬ ច្បាប់ដើម្បីអនុវត្តបាននូវគោលដៅដូចមានចែងក្នុងមាត្រា ១ ។

អត្ថបទទាំងនេះ ក្រោយពីបានត្រូវទទួលការបោះឆ្នោតអនុម័តដោយរដ្ឋសភារួចហើយ ត្រូវតែបានទទួលជាបន្ទាន់នូវចំណាត់ការដោយរួសរាន់ពីសំណាក់ព្រឹទ្ធសមាជិករដ្ឋសភា តាមនីតិវិធីកំណត់សំរាប់ អត្ថបទទាំងនោះ រហូតដល់ពេលដែលត្រូវបានប្រកាសអោយចូលជាធរមាន ។

មាត្រា ៣.-

ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា ៨២ និង ១១៩ថ្មី នៃរដ្ឋធម្មនុញ្ញ មិនអាចសំរេចបាន រដ្ឋសភា តាមសំណើររបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បី ជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជា ប្រធាន និង អនុប្រធានគណៈ កម្មការក្នុងពេលជាមួយគ្នា និង ការផ្តល់សេចក្តីទុកចិត្តចំពោះ រាជរដ្ឋាភិបាល ។

មាត្រា ៤.-

ការរៀបចំបញ្ជីរាយនាមបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង និង ផ្តល់សេចក្តីទុកចិត្តត្រូវអនុវត្តដូចតទៅ :

- បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជា ប្រធាន និង អនុប្រធានគណៈ កម្មការ ជំនាញទាំងអស់ នៃរដ្ឋសភា ត្រូវរៀបចំ និង ស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចំរុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- តាមសេចក្តីស្នើពីគណបក្សនយោបាយ ដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រ នៃគណបក្សនយោបាយដែលឈ្នះឆ្នោតអោយបង្កើតរាជរដ្ឋាភិបាល ។

វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្លូវផ្តួងតំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជី រាយនាម សមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- ព្រឹទ្ធសមាជិករដ្ឋសភា ត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវ បេក្ខជន ប្រធាន អនុប្រធាន នៃរដ្ឋសភា ក៏ដូចជាប្រធាន និង អនុប្រធាន គណកម្មការ ជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជន នាយករដ្ឋមន្ត្រី និង សមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភា បោះឆ្នោត ។

មាត្រា ៥.-

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់ មិនអាចជជែកពិភាក្សា អ្វីឡើយ ហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតនេះ ក្រោយ ការប្រកាសលទ្ធផល នៃការបោះឆ្នោតជាកញ្ចប់នេះដែរ ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថាព្រម ឬ មិន ព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយ ដែលព្រឹទ្ធសមាជិករដ្ឋសភាបាន ដាក់ជូន ។ ការបោះឆ្នោតនេះត្រូវធ្វើឡើងដោយវិធីលើកដៃ ។

មាត្រា ៦.-ថ្នី នៃច្បាប់ធម្មនុញ្ញបន្ថែម

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើន ដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែល នេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

មាត្រា ៧.-

ច្បាប់ធម្មនុញ្ញបន្ថែមនេះ ត្រូវបានប្រកាសជាការប្រញាប់ និង យកមកអនុវត្តចាប់តាំងពីដើម នីតិកាល បច្ចុប្បន្ននេះទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជក្រឹត្យលេខ

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ញឹក ប៊ុនឆៃ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមទ្បាយព្រះហស្តលេខាព្រះមហាក្សត្រ

ព្រឹទ្ធសមាជិក និង ជាប្រធានអង្គប្រជុំរដ្ឋសភា

ហត្ថលេខា

ជា សុជ្ជ

លេខ: ៩៣០ ច.ល

ថ្ងៃ ១៣ ខែ កក្កដា ឆ្នាំ២០០៤

កំណត់សម្គាល់ក្នុងការចោះពុម្ពផ្សាយ

ដើម្បីសម្រួលដល់ការស្រាវជ្រាវ ក៏ដូចជាបង្កភាពងាយស្រួលក្នុងការអានរដ្ឋធម្មនុញ្ញនេះ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **អ៊ឹម ឈុនឆឺម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ បានចាត់ឱ្យមានការរៀបចំភ្ជាប់ជាមួយនូវ (១) មាត្រាទាំងឡាយដែលត្រូវបានធ្វើវិសោធនកម្ម (២) ប្រមូលផ្តុំវិសោធនកម្មតាមមាត្រា (៣) មាតិកា ។

មាត្រាទាំងឡាយដែលត្រូវបានធ្វើវិសោធនកម្ម

កំណត់សម្គាល់

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ នេះ បានធ្វើវិសោធនកម្មចំនួន ៨ លើកគឺ :

១- ច្បាប់ធម្មនុញ្ញស្តីពីការកែប្រែមាត្រា ២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤ នាសម័យប្រជុំវិសាមញ្ញសម័យពិសេស ហើយប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤ ។

២- ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ ក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី២ ហើយប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩ ។

៣- ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៩ និងមាត្រា ២៩ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃចន្ទ ទី២ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិច្បាប់នេះទាំងស្រុង

កាលពីថ្ងៃច័ន្ទ ទី២៣ ខែកក្កដា ឆ្នាំ២០០១ និងប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៧០១/១១ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០១ ។

៤- ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៨៨ និងមាត្រា១១ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ។

៥- ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៦ថ្មី មាត្រា១១១ថ្មី(មួយ) មាត្រា១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាអនុម័តនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៦ ។

៦- ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១៤៥ថ្មី និងមាត្រា ១៤៦ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាដែល រដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែល ព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់អាចពិនិត្យ និងឱ្យ យោបល់តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ បានឡើយ ហើយប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ។

៧- ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ៧៦ និងមាត្រាទាំង ឡាយពីដំពូកទី១៥ថ្មី ដល់ដំពូកទី១៦ថ្មីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពី ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ និងប្រកាស ឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០១៤/០២២ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ។

៨- ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៣៤ថ្មី មាត្រា ៤២ មាត្រា ៤៩ មាត្រា ៥៣ និងមាត្រា ១១៨ ថ្មី នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពី ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២ ០ ១ ៨ នាសម័យប្រជុំរដ្ឋសភាជា

វិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី១

មាត្រា ២៨.-

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី២

មាត្រា ១១.-

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈជាព្រះប្រមុខរដ្ឋបានដូចធម្មតា ដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នោះប្រធានរដ្ឋសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គក្នុងឋានៈជា "ព្រះរាជានុសិទ្ធ" ។

មាត្រា ១២.-

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធ នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ១៣.-

ក្នុងរយៈវេលាប្រាំពីរថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ
- អនុប្រធានទីមួយ និងអនុប្រធានទីពីរ នៃរដ្ឋសភា ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ នឹងមានកំណត់ក្នុងច្បាប់មួយ ។

មាត្រា ១៨.-

ព្រះមហាក្សត្រព្រះអង្គទ្រង់ទាក់ទងជាមួយរដ្ឋសភាដោយព្រះរាជសារ ។ ព្រះរាជសារនេះ រដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ ។

មាត្រា ២២.-

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិបឹតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា ។

មាត្រា ២៤.-

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា ។

មាត្រា ២៦.-

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា ។

មាត្រា ២៨ ថ្មី.-

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួនហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្តលេខានៅលើ ព្រះរាជក្រមឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួស ដោយព្រះរាជសារប្រគល់សិទ្ធិ ។

មាត្រា ៣០.-

ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

មាត្រា ៣៤.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឲ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឲ្យគេបោះឆ្នោត ។

បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោតនិងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៥១.-

ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

មាត្រា ៩O.-

រដ្ឋសភាជាអង្គការតែមួយគត់ដែលមានអំណាចនីតិបញ្ញត្តិ ។ អំណាចនេះ រដ្ឋសភាមិនអាចប្រគល់ឲ្យទៅអង្គការ ឬបុគ្គលណាមួយបានឡើយ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឲ្យរដ្ឋខ្ចីប្រាក់ពីគេ ការឲ្យរដ្ឋឲ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឲ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៩១.-

តំណាងរាស្ត្រ និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះ សំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកទៅលើប្រជាពលរដ្ឋ ។

មាត្រា ៩៣.-

ច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល ១០ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឲ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល ២០ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឲ្យប្រើ ។

ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឲ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ ត្រូវចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយនៅទូទាំងប្រទេសឲ្យទាន់តាមពេលកំណត់ខាងលើ ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៣

មាត្រា ១៩.-

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា ១០០ ។

មាត្រា ២៩.-

ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធា និងស៊ីវិល តាមច្បាប់កំណត់ ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៤

មាត្រា ៨៨.-

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បាន តាមការសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ១១១.- ថ្មី

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការសុំពីប្រធានឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រីឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសម្លេងដែលតម្រូវសំរាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសំរាប់ព្រឹទ្ធសភាផងដែរ ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៥

មាត្រា ៨២.-

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធាន មុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៥ ។

មាត្រា ៨៨ ថ្មី.-

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិករដ្ឋសភាទាំងមូល ។

ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៩០.- ថ្មី

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុនិងការបង្កើត កែប្រែឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រមឬលុបចោលសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៩៨.-

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោសតាមសម្លេងឆ្នោតពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

មាត្រា ១០៦.-ថ្មី

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗនិងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភានិងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

មាត្រា ១១១ថ្មី (មួយ).-

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសំរាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសំរាប់ព្រឹទ្ធសភាផងដែរ ។

មាត្រា ១១៤.-ថ្មី

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រមដោយសម្លេងភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

មាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែម

មាត្រា ៦.-

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណី ការបោះឆ្នោតជុំទីមួយមិនបានសំរេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៦

មាត្រា ១៤៥.- ថ្មី (មាត្រា ១២៦ ចាស់)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជាខេត្ត និងក្រុង ។

ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។

ក្រុងចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់ ។

មាត្រា ១៤៦.- ថ្មី (មាត្រា ១២៧ ចាស់)

ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំនិងសង្កាត់ ត្រូវគ្រប់គ្រងតាមលិក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៧

មាត្រា ៧៦.-

រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

អង្គការរៀបចំការបោះឆ្នោត បែបបទនិងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៨

មាត្រា ៣៤.-ថ្មី

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោតនិងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោតនិងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៤២.-

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណៈបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម ។

មាត្រា ៤៩.-

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

មាត្រា ៥៣.-

ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។ ព្រះរាជាណាចក្រកម្ពុជារួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក ។

ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង នៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក ។

ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀង យោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ។

ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតឲ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឲ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

ព្រះរាជាណាចក្រកម្ពុជារក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈយោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស ។

មាត្រា ១១៨.- ថ្មី (មាត្រា ៩៩ ចាស់)

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក ។

ប្រមូលផ្តុំវិសោធនកម្មតាមមាត្រា

វិសោធនកម្មច្បាប់ធម្មនុញ្ញបន្ថែម
សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

មាត្រា ៦.-

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណី ការបោះឆ្នោតជុំទីមួយមិនបានសំរេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

(ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤)

មាត្រា ៦ .-ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៦)

វិសោធនកម្មរដ្ឋធម្មនុញ្ញ

មាត្រា ១១.-

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតា ដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នោះប្រធានរដ្ឋសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គក្នុងហានៈជា "ព្រះរាជានុសិទ្ធ" ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស. ១៩៩៣)

មាត្រា ១១.-ថ្មី

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតាដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភានិងនាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គក្នុងហានៈជាព្រះរាជានុសិទ្ធិ ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងហានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ចនេះ ។

តំណែងជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងហានៈជាព្រះរាជានុសិទ្ធិនេះ អាចនឹងដូរតស្សរជនផ្សេងទៀត ក្នុងករណីដូចដែលបានចែងក្នុង

វាក្យខ័ណ្ឌខាងលើ តាមឋានានុក្រមដូចតទៅ :

ក- អនុប្រធានទី ១ ព្រឹទ្ធសភា

ខ- អនុប្រធានទី ១ រដ្ឋសភា

គ- អនុប្រធានទី ២ ព្រឹទ្ធសភា

ឃ- អនុប្រធានទី ២ រដ្ឋសភា

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១២.-

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធ នៃព្រះរាជាណាចក្រកម្ពុជា ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១២.-ថ្មី

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ក្នុងពេលព្រះអង្គចូលទីវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ថ្មី ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១៣.-

ក្នុងរយៈវេលាប្រាំពីរថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ
- អនុប្រធានទីមួយ និងអនុប្រធានទីពីរ នៃរដ្ឋសភា ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ នឹងមានកំណត់ក្នុងច្បាប់មួយ ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១៣.-ថ្មី

ក្នុងរយៈវេលា ៧ថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

-ប្រធានព្រឹទ្ធសភា

-ប្រធានរដ្ឋសភា

-នាយករដ្ឋមន្ត្រី

-សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ និងគណៈធម្ម
យុត្តិកនិកាយ

-អនុប្រធានទី ១ និងអនុប្រធានទី ២ ព្រឹទ្ធសភា

-អនុប្រធានទី ១ និងអនុប្រធានទី ២ រដ្ឋសភា

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិនឹងមានកំណត់ក្នុងច្បាប់មួយ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១៨.-

ព្រះមហាក្សត្រព្រះអង្គទ្រង់ទាក់ទងជាមួយរដ្ឋសភាដោយព្រះរាជសារ ។ ព្រះរាជសារនេះ រដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១៨.-ថ្មី

ព្រះមហាក្សត្រព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភានិងរដ្ឋសភាដោយព្រះរាជសារ ។

ព្រះរាជសារនេះ ព្រឹទ្ធសភានិងរដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១៩.-

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា ១០០ ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១៩ ថ្មី.-

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រីនិងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី ។

(ព្រះរាជក្រមលេខ នស/រកម/០៧០១/១១ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០១)

មាត្រា ២២.-

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិបិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ២២.-ថ្មី

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភានិងប្រធានព្រឹទ្ធសភា។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ២៤.-

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ២៤.-ថ្មី

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ២៦.-

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ២៦.-ថ្មី

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញានិងអនុសញ្ញាទាំងនេះក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភានិងព្រឹទ្ធសភា ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ១៩៩៩)

មាត្រា ២៨.-

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ២៨ ថ្មី .-

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួនហើយត្រូវព្យាបាលព្រះរោគ នៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយ ព្រះហស្តលេខានៅលើ ព្រះរាជក្រមឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋ ស្តីទីចុះហត្ថលេខាជំនួស ដោយព្រះរាជសារប្រគល់សិទ្ធិ ។

(ព្រះរាជក្រម ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤)

មាត្រា ២៨.-ថ្មី

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគ នៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយ ព្រះហស្តលេខានៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ២៩.-

ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈយោធា និងស៊ីវិល តាមច្បាប់កំណត់ ។

(ព្រះរាជក្រមចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ២៩ ថ្មី.-

ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិ ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធានិងស៊ីវិល តាមច្បាប់កំណត់ ។

(ព្រះរាជក្រមលេខ នស/រកម/០៧០១/១១ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០១)

មាត្រា ៣០.-

ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៣០.-ថ្មី

ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ពេលព្រះអង្គទ្រង់អវត្តមានការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ថ្មី ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ៣៥.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឲ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឲ្យគេបោះឆ្នោត ។

បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតត្រូវ ចែងក្នុងច្បាប់បោះឆ្នោត ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៣៤.-ថ្មី

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោតនិងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោតនិងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា៣៤.-ថ្មី (មួយ)

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។

បទប្បញ្ញត្តិដកសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់។

(ព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨)

មាត្រា ៤២.-

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណៈបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា៤២.- ថ្មី

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគមនិងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។

គណបក្សនយោបាយត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី

នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។

(ព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨)

មាត្រា ៤៩.-

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា៤៩.- ថ្មី

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់។

(ព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨)

មាត្រា ៥១.-

ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៥១.-ថ្មី

ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលនិងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ៥៣.-

ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។ ព្រះរាជាណាចក្រកម្ពុជារួមរស់

ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀត ទាំងអស់នៅលើសកលលោក ។

ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង នៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក ។

ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀង យោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ។

ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតឲ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឲ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

ព្រះរាជាណាចក្រកម្ពុជា រក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈ យោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធនិងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា៥៣.- ថ្មី

ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជារួមរស់ដោយ

សន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក។

ព្រះរាជាណាចក្រកម្ពុជាមិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក។

ព្រះរាជាណាចក្រកម្ពុជាប្រឆាំងដាច់ខាតការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ទោះបីក្រោមរូបភាពណាក៏ដោយ។

ព្រះរាជាណាចក្រកម្ពុជាមិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ។

ព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ។

ព្រះរាជាណាចក្រកម្ពុជារក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈយោធា អាវុធ គ្រាប់រំសែវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស។

(ព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨)

មាត្រា ៧៦.-

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

អង្គការរៀបចំការបោះឆ្នោត បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៧៦.- ថ្មី

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រ ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

(ព្រះរាជក្រមលេខ នស/រកម/១០១៤/០២២ ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៤)

មាត្រា ៨២.-

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធាន មុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៥ ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៨២ .- ថ្មី

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦)

មាត្រា ៨៨.-

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បាន តាមការសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៨៨ ថ្មី.-

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិករដ្ឋសភាទាំងមូល ។

ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀបឬយកមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

(ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥)

មាត្រា ៨៨ .-ថ្មី(ពីរ)

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភា នឹងយកជាការបានលុះត្រាតែមាន :

ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្តាល នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦)

មាត្រា ៩០.-

រដ្ឋសភាជាអង្គការតែមួយគត់ដែលមានអំណាចនីតិបញ្ញត្តិ ។ អំណាចនេះ រដ្ឋសភាមិនអាចប្រគល់ឲ្យទៅអង្គការ ឬបុគ្គលណាមួយបានឡើយ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឲ្យរដ្ឋខ្ចីប្រាក់ពីគេ ការឲ្យរដ្ឋឲ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឲ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៩០.-ថ្មី

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុនិងការបង្កើត កែប្រែឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រមឬលុបចោលសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ៩០ .-ថ្មី(ពីរ)

រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬ លុបចោលសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦)

មាត្រា ៩១.-

តំណាងរាស្ត្រ និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះ សំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកទៅលើប្រជាពលរដ្ឋ ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៩១.-ថ្មី

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភានិងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ៩៣.-

ច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល ១០ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឲ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល ២០ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឲ្យប្រើ ។

ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឲ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ ត្រូវចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយនៅទូទាំងប្រទេសឲ្យទាន់តាមពេលកំណត់ខាងលើ ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៩៣.-ថ្មី

ច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា

ប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថា ជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលកំណត់ខាងលើ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ៩៨.-

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោសតាមសម្លេងឆ្នោតពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងដូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៩៨ .- ថ្មី

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងដូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ២០០៦)

មាត្រា ១០៦.-ថ្មី

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗនិងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភានិងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១០៦ .-ថ្មី(មួយ)

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦)

មាត្រា ១១១.-ថ្មី

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការសុំពីប្រធានឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសម្លេងដែលតម្រូវសំរាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសំរាប់ព្រឹទ្ធសភាផងដែរ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១១១ ថ្មី (មួយ).-

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ- កូរ៉ុមប្រាំមួយភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយ

ប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

(ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥)

មាត្រា ១១១ .-ថ្មី(ពីរ)

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ-កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬ យកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦)

មាត្រា ១១៤.-ថ្មី

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រមដោយសម្លេងភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១១៤ .-ថ្មី(មួយ)

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦)

មាត្រា ៩៩.-

គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១១៨.-ថ្មី (មាត្រា ៩៩ ចាស់)

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយ

ឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ជាសមាជិក ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា១១៨.- ថ្មី (មួយ)

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយ ឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ជាសមាជិក។

(ព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨)

មាត្រា ១២៦.-

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជាខេត្ត និងក្រុង ។

ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។

ក្រុងចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់ ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១៤៥.-ថ្មី (មាត្រា ១២៦ ចាស់)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជាខេត្ត និងក្រុង ។

ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។

ក្រុងចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា១៤៥ .-ថ្មី (មួយ)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

(ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០០៨)

មាត្រា ១២៧.-

ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ និង សង្កាត់ ត្រូវគ្រប់គ្រងតាមលិក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១៤៦.-ថ្មី (មាត្រា ១២៧ ចាស់)

ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំនិងសង្កាត់ ត្រូវគ្រប់គ្រងតាមលិក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា១៤៦ .-ថ្មី (មួយ)

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលិក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ ។

(ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៨)

មាតិកា

១៥៥

មាតិកា

ព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣

បុព្វកថា ១

ជំពូកទី១: អំពី អធិបតេយ្យ ៣

ជំពូកទី២: អំពី ព្រះមហាក្សត្រ ៥

ជំពូកទី៣: អំពី សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ១២

ជំពូកទី៤: អំពី របបនយោបាយ ២០

ជំពូកទី៥: អំពី សេដ្ឋកិច្ច ២៣

ជំពូកទី៦: អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច ២៦

ជំពូកទី៧: អំពី រដ្ឋសភា ២៩

ជំពូកទី៨ ថ្មី: អំពី ព្រឹទ្ធសភា ៣៩

ជំពូកទី៩ ថ្មី: អំពី សមាជរដ្ឋសភា និងព្រឹទ្ធសភា ៤៧

ជំពូកទី១០ ថ្មី: អំពី រាជរដ្ឋាភិបាល ៤៨

ជំពូកទី១១ ថ្មី: អំពី អំណាចតុលាការ ៥១

ជំពូកទី១២ ថ្មី: អំពី ក្រុមប្រឹក្សាធម្មនុញ្ញ ៥៤

ជំពូកទី១៣ ថ្មី: អំពី ការគ្រប់គ្រងរដ្ឋបាល ៥៧

ជំពូកទី១៤ ថ្មី: អំពី សមាជជាតិ ៥៨

ជំពូកទី១៥ ថ្មី(ពីរ): អំពី អង្គការរៀបចំការបោះឆ្នោត ៥៩

ជំពូកទី១៦ ឬី(ពីរ): អំពីអានុភាព ការសើរើ និងវិសោធនកម្ម
រដ្ឋធម្មនុញ្ញ ៦២
ជំពូកទី១៧ ឬី: អំពីអន្តរប្បញ្ញត្តិ ៦៤
ឧបសម្ព័ន្ធទី១: ទង់ជាតិ ៦៧
ឧបសម្ព័ន្ធទី២: ភ្លេងជាតិ នគរវាជ ៦៩
ឧបសម្ព័ន្ធទី៣: សញ្ញាជាតិ ៧១
ឧបសម្ព័ន្ធទី៤: សច្ចាប្រណិធាននៃព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ៧៣
ឧបសម្ព័ន្ធ ៥: សច្ចាប្រណិធានសម្រាប់ប្រធាន អនុប្រធាន និង សមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ៧៥
ឧបសម្ព័ន្ធ ៦: សច្ចាប្រណិធានសម្រាប់នាយករដ្ឋមន្ត្រី និង សមាជិករាជរដ្ឋាភិបាល ៧៩
ឧបសម្ព័ន្ធទី៧: សច្ចាប្រណិធានសម្រាប់ប្រធាន អនុប្រធាន និង សមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ៨៣
គណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ ៨៧
ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ ៨៩
ព្រះរាជក្រម នស/ រកម/ ០៧០៤ / ០០១ ..... ៩១
កំណត់សម្គាល់ក្នុងការបោះពុម្ពផ្សាយ ៩៧
មាត្រាទាំងឡាយដែលត្រូវបានធ្វើវិសោធនកម្ម ៩៩
កំណត់សម្គាល់ ១០១
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី១ ..... ១០៥

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី២ ..... ១០៦
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៣ ..... ១១១
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៤ ..... ១១២
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៥ ..... ១១៣
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៦ ..... ១១៧
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៧ ..... ១១៨
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៨ ..... ១១៩
ប្រមូលផ្តុំវិសោធនកម្មតាមមាត្រា ១២៣
វិសោធនកម្មច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជា
ប្រក្រតីនៃស្ថាប័នជាតិ ១២៥
វិសោធនកម្មរដ្ឋធម្មនុញ្ញ ១២៦
មាតិកា ១៥៥



គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ
ក្រសួងអប់រំ យុវជន និងកីឡា



មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

បោះពុម្ពផ្សព្វផ្សាយ
ព.ស. ២៥៦៥ គ.ស. ២០២១